**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី៧)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

លោក ម៉ាត្ធូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក រ៉ូបឺត ពើទីត *(Mr.Robet PETIT)*

លោក យ៉េត ចរិយា

លោក វីលៀម ស្មីត

*(Mr. William SMITH)*

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ បេ៊ត

*(M.r Alexander BATES)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្កេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យុង ផានិត

កញ្ញា ទី ស្រ៊ីនណា

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃើស្ជួត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វែនណឺ *(Mr. Alain WERNER)*

លោក ហ្វីលីព កាណុន *(Mr. Philippe CANNONE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កួវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី** ៖ TC-1 ហ្វ្រង់ស្វ័រ ប៊ីហ្សូ

ស្តួរដោយលោក **យ៉េត ចរិយា** ផ្ដើមពី ..................... ទំព័រ ២

ស្តួរដោយលោក **រ៉ូប៊ឺត ពើទីត** ផ្ដើមពី ..................... ទំព័រ ៣

ស្តួរដោយលោក **អាឡាំង វ៉ែនណឺ** ផ្ដើមពី ..................... ទំព័រ ៩

ស្តួរដោយលោកស្រី **ស៊ីលឃី ស្ទូតហ្ស៊ីនស្គី** ផ្ដើមពី ..................... ទំព័រ ១៥

ស្តួរដោយលោក **ហ្វីលីព កាណុន** ផ្ដើមពី ..................... ទំព័រ ១៧

ស្តួរដោយកញ្ញា **ម៉ុច សុវណ្ណារី** ផ្ដើមពី ..................... ទំព័រ ២០

ស្តួរដោយលោក **ហុង គីមសួន** ផ្ដើមពី ..................... ទំព័រ ២២

ស្តួរដោយលោក **ហ្វ្រង់ស្វ័រ រូ** ផ្ដើមពី ..................... ទំព័រ ៣០

**សាក្សី** ៖ KW-30 អ៊ុច ស៊ន

ស្តួរដោយ**ប្រធានអង្គជំនុំ** ផ្ដើមពី ..................... ទំព័រ ៣០

ស្តួរដោយចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** ផ្ដើមពី ..................... ទំព័រ ៣៦

ស្តួរដោយលោក **យ៉េត ចរិយា** ផ្ដើមពី ..................... ទំព័រ ៦៣

ស្តួរដោយកញ្ញា **ទី ស្រ៊ីនណា** ផ្ដើមពី ..................... ទំព័រ ៦៦

ស្តួរដោយលោកស្រី **ស៊ីលឃី ស្ទូតហ្ស៊ីនស្គី** ផ្ដើមពី ..................... ទំព័រ ៧១

ស្តួរដោយលោក **គង់ ពិសី** ផ្ដើមពី ..................... ទំព័រ ៧៣

ស្តួរដោយលោក **ហ្វីលីព កាណុន** ផ្ដើមពី ..................... ទំព័រ ៧៧

ស្តួរដោយលោក **ហុង គីមសួន** ផ្ដើមពី ..................... ទំព័រ ៧៨

ស្តួរដោយលោក **លោក ការ សាវុត្ថ** ផ្ដើមពី ..................... ទំព័រ ៨០

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ | បារាំង |
| លោក ហ្វីលីព កាណុន | បារាំង |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| កញ្ញា ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក រ៉ូបឺត ពេទីត | អង់គ្លេស |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី ស៊ីលឃី ស្ទុតហ្ស៊ីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក អ៊ុំ ស៊ន | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | បារាំ |
| លោក យ៉េត ចរិយា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០២:០០]

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តសវនាការ ។ មន្ត្រីតុលាការអញ្ជើញសាក្សីហ្វ្រង់ស្វ័រ ប៊ីហ្សូ ចូលកាន់បន្ទប់សវនាការ ។

ជាកិច្ចបន្តនេះដំណើរការនឹងស្តាប់សក្ខីកម្មរបស់សាក្សី ហ្វ្រង់ស្វ័រ ប៊ីហ្សូ បន្តពី សក្ខីកម្មដែលគាត់បានផ្តល់ពីម្សិលមិញ ។ ហើយជាដំបូងនេះអង្គជំនុំជម្រះសួរទៅលោក លោកស្រីចៅក្រម នៃអង្គជំនុំជម្រះសាលាដំបូង ថាតើមានសំណួរអ្វី ត្រូវសួរដល់សាក្សី រូបនេះទេ? មិនមានទេ ។ គឺខ្ញុំមានសំណួរមួយ ។ លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ នៅក្នុងអំឡុង ពេលដែលលោកនៅក្នុងមន្ទីរសន្តិសុខ ម-១៣ ក្នុងអំឡុងពេលពីខែដប់ រហូតដល់ម្ភៃប្រាំ ខែដប់ពីរ ឆ្នាំ១៩៧១នោះ ។ តើលោកបានកត់សម្គាល់ ថានៅក្នុងមន្ទីរម-១៣ នោះ មាន កម្មាភិបាល បុគ្គលិក សរុបទាំងកងការពារផង ដែលលោកកត់សម្គាល់ឃើញ មាន ប្រហែលប៉ុន្មាននាក់ទៅ?

**សាក្សី TC-1៖**

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំៗ ក្រោយមកខ្ញុំព្យាយាមគិតខ្លួនឯង គឺមាន ឌុច ហើយនឹង អនុប្រធាន ហើយមានបុគ្គលិកមួយពីរ ដែលជាខ្មែរ ដែលគាត់ទទួលបន្ទុក ។ ជាការពិតណាស់នៅ-- គឺពីរនាក់នោះ គាត់ទទួលបន្ទុកថ្នាក់ក្រោម ហើយអ្នកយាម ឬក៏ អ្នកដែលត្រូវបានគេចាត់តាំងឲ្យតាមដានខ្ញុំ នៅពេលដែលខ្ញុំដើរ គឺឃើញមានបី ឬក៏ពីរ នាក់ទៀត ។ យើងឃើញមានប្រាំ ប្រាំមួយនាក់ អ្នកយាមគាត់ផ្លាស់ប្តូរគ្នា ប៉ុន្តែគឺមាន តិចណាស់ ប្រហែលជាដប់នាក់ ប៉ុន្តែខ្ញុំមិនប្រាកដចំពោះចំនួនតួលេខនេះទេ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកានេះ ជូនទៅសហព្រះរាជអាជ្ញាដើម្បី មានឱកាស

ក្នុងការសួរសំណួរដល់សាក្សីរូបនេះ ។ ប្រសិនបើមាន សូមអញ្ជើញសហព្រះរាជអាជ្ញា ។

**សួរដោយលោក យ៉េត ចរិយា៖**

**ស៖** លោកប៊ីហ្សូ សូមលោកបញ្ជាក់ម្តងទៀតមើល៎ អ្នកទោសខ្លះដែលលោកបាន ឃើញចូលមកម-១៣ មានកូនមកជាមួយ តើកូននោះគេយកទៅទីណា? លោកបាន ឃើញទេ?

[០៩:០៧:៣៥]

**សាក្សី TC-1៖**

**ឆ៖** ខ្ញុំអត់ដឹងថាឪពុករបស់កូនស្រីនោះ គេយកទៅណាទេ ។ ខ្ញុំមានអារម្មណ៍ថាគាត់ត្រូវបានយកទៅសម្លាប់ចោល ហើយកូនហ្នឹងគឺនៅក្នុងជំរំហ្នឹង ដូចដែលខ្ញុំជម្រាបលោកចៅក្រមកាលពីម្សិលមិញ ។ កូនហ្នឹងត្រូវបានអ្នកយាមយកចូលទៅក្នុង ហើយភ្លាមៗនោះក្មេងនោះ ឃើញអំពីមានការប្រជុំទិតៀន ដែលមានចំរៀងច្រៀងឡើងជាដើម។ ហើយខ្ញុំចាំថា ខ្ញុំឃើញ ឃើញកូនស្រីនោះគឺអត់មានធ្វើអីទេ គឺគាត់ច្រៀងជាមួយនឹងចម្រៀងបដិវត្តន៍នោះ ។ ហើយយើងឃើញមានការធ្វើស្វ័យទិតៀនពីមួយទៅមួយ ។ ហើយពីរអាទិត្យក្រោយមកខ្ញុំចាំឃើញថាក្មេងហ្នឹង ក្មេងតូចនោះគឺគាត់ចូលរួមជាមួយនឹងបដិវត្តន៍ ខ្ញុំអាចនិយាយអ៊ីចឹង ។ គឺគាត់ដើរតាមអ្នកយាម ដើរតាមអ្នកយាម ហើយខ្ញុំចាំអត់ច្បាស់ទេ ថានាងស្នាក់នៅជំរុំនោះ ឬក៏ត្រូវបានដោះលែង ខ្ញុំអត់អាចចាំ ហើយខ្ញុំក៏មិនផ្តល់ព័ត៌មានពិស្តារចំពោះបញ្ហានេះដែរ ។

**ស៖** ក្មេងតូចនោះ អាយុប្រហែលប៉ុន្មាន?

**ឆ៖** ប្រហែលជាប្រាំបួនឆ្នាំ ។ ដោយសារតែខ្ញុំសួរគាត់ គឺថាគាត់អាយុប្រាំបួនឆ្នាំ ក្មេងហ្នឹងអាយុប្រាំបួនឆ្នាំ ។

**ស៖** ខ្ញុំសូមសួរសំណួរមួយទៀត ។ សូមលោកបញ្ជាក់សាជាថ្មី ពេលដែលគេដោះលែងលោកចេញពី ម-១៣ តើសហការីរបស់លោកឈ្មោះ សុក និង ឡាយ ត្រូវគេដោះចេញដែរ ឬអត់?

**ឆ៖** អ្នកជំនួយការរបស់ខ្ញុំ អ្នកទាំងពីរនោះមិនត្រូវបានដោះលែងទេ គឺ ឌុច ប្រាប់ខ្ញុំថាគេត្រូវដោះលែង ប៉ុន្តែពួកគេនៅកន្លែងហ្នឹងដដែល ហើយពួកគេអត់មានត្រូវគេដាក់ខ្នោះទៀតទេ ។ ហើយពួកគេអាចចូលរួម ហើយពួកពីរនាក់ហ្នឹង គឺនឹងទៅចូលនៅក្នុងការងារនៅក្នុងជំរុំ ហើយពួកគេទាំងពីរនោះឲ្យមានសេរីភាពនៅក្នុងជំរុំ ។ គឺពួកគេមានសេរីភាពនៅក្នុងមន្ទីរហ្នឹង ហើយពួកគេស្ថិតនៅក្នុងតំបន់ដែលមានសេរីភាព គឺមានការពន្យល់ទៅលើបញ្ហាហ្នឹង ដោយសារតែខ្ញុំព្យាយាមធ្វើការអន្តរាគមន៍ចំពោះ

អ្នកទាំងពីរនោះ ។ គឺដើម្បីឲ្យវាមានភាពមិនស្របគ្នា គឺឲ្យវាច្បាស់លាស់ ខ្ញុំជាអ្នកស្លូតត្រង់ ហើយយើងមិនអាចពិចារណាថា អ្នកពីរនាក់ ជំនួយការរបស់ខ្ញុំនោះមិនមែន មិនត្រូវបានគេដោះលែងទេ គឺយើងត្រូវតែដោះលែង ។

ដូច្នេះ ខ្ញុំ គាត់គឺជាខ្មែរ ហើយខ្ញុំជាបរទេស ដូច្នេះគឺទីកន្លែងរបស់ខ្ញុំគឺមិនមែននៅក្នុងមន្ទីរនេះទេ ។ ប៉ុន្តែ ពួកគេត្រូវបានដោះលែងនៅក្នុងតំបន់រំដោះរបស់ខ្មែរក្រហម ។ គឺយ៉ាងហោច-- ប៉ុន្តែខ្ញុំអត់ដឹងថាមានបញ្ហាអីកើតឡើងទេ ប្រហែលជាពួកគេត្រូវបានសម្លាប់ចោល ។

[០៩:១២:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា ។

**សួរដោយលោក រ៉ូបឺត ពេទីត៖**

**ស៖** អរគុណលោកប្រធាន និងអរគុណលោក ប៊ីហ្ស ខ្ញុំមានសំណួរមួយចំនួន ។ ជាបឋម លោកបាននិយាយជាមួយយើងខ្ញុំប៉ុន្មានដង អំពីអនុប្រធាន ដែលលោកគិតថាជាអនុប្រធានរបស់ជនជាប់ចោទ ។ ដែលគាត់បានសួរចម្លើយលោក ទីមួយនៅក្នុងមន្ទីរនោះ ហើយគឺគាត់បានវ៉ៃលោក ហើយមិនជាមនុស្សល្អ ។ ហើយនៅពេលនោះ ថាតើគេបង្កើតអត្តសញ្ញាណ ឬក៏ដឹងថាតើគាត់ជាអនុប្រធានហ្នឹងយ៉ាងម៉េច? ថាតើឈ្មោះរបស់គាត់ ឈ្មោះអ្វី?

**សាក្សី TC-1៖**

**ឆ៖** គឺខ្ញុំអត់ចាំទេទៅលើបញ្ហាហ្នឹង ។ ខ្ញុំអត់ចាំឈ្មោះរបស់គាត់ទេ ប៉ុន្តែខ្ញុំដឹងថានៅពេលមួយនោះ ប៉ុន្តែខ្ញុំអត់ចាំទេនៅពេលនេះ ។

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** ខ្ញុំឃើញប្អូន ប្រាំដង-លើក ឃើញកម្មាភិបាលនេះប៉ុន្មានដងដែរ ដែលគាត់ជាមនុស្សសាហាវ ហើយគាត់គ្មានអារម្មណ៍អាណិតដល់អ្នកដទៃទេ ។ ហើយជាពិសេសយើងអាចកត់សម្គាល់ថា គាត់សាហាវខ្លាំងណាស់ ។ ប៉ុន្តែមិនយូរប៉ុន្មានទេ ដោយដឹងថា នេះគឺជាព័ត៌មានបន្ថែមដែលខ្ញុំប្រមូលបានគឺវាមិនមែនទាក់ទងទៅនឹងការចងចាំរបស់ ខ្ញុំនៅម-១៣ ទេ គឺខ្ញុំទទួលបានពីព័ត៌មានផ្សេងៗ ។ អនុប្រធានមួយរបស់ ឌុច នៅស-១២ ខ្ញុំអាចលើកអំពី ស-២១ គឺ ម៉ម ណៃ ខ្ញុំគិតថា ម៉ម ណៃ ។ ខ្ញុំបានគិតថាប្រហែល ម៉ម ណៃ នៅម-១៣ នោះជាគាត់ជាអនុប្រធានផងដែរ ។ ហើយនៅពេលដូចគ្នា នេះដែរ គឺ

ការពិពណ៌នាអំពីអនុប្រធាននោះ គឺជាអ្នកសម្លាប់ គឺគាត់ខ្ពស់ គឺគាត់មានសម្បុរជ្រះ ហើយ គឺវាមិនដូចទៅនឹងបុគ្គលដែលខ្ញុំចាំនៅម-១៣ នោះទេ ។

ដូច្នេះខ្ញុំ មិនច្បាស់ថា គាត់ដូចគ្នា ឬយ៉ាងម៉េចនោះទេ។

[០៩:១៥:៣៤]

**ស៖** អរគុណ។ម្យ៉ាងវិញទៀត លោកបាននិយាយកាលពីម្សិលមិញនៅក្នុងចម្លើយ របស់លោក លោកបាននិយាយថា នៅពេលដែលលោកត្រូវបានគេឃុំខ្លួន លោកអាចសង្កេតឃើញយ៉ាងហោចណាស់ម្តង ឃើញជនជាប់ចោទ សួរចម្លើយអ្នកទោស គឺឪពុករបស់ក្មេងស្រីនោះ បន្ទាប់ពីទទួលបានសំណុំរឿងពីអ្នកយាមដែលគាត់មកដើរអមជាមួយ នឹងអ្នកទសនោះ ។ អ្វីដែលខ្ញុំយល់ពីចម្លើយរបស់លោក គឺការ-- បញ្ហានេះគឺកើតឡើងនៅកន្លែងលំហមួយ គឺអាចអ្នកផ្សេងៗអាចមើលឃើញទាំងអស់ ។

ដូច្នេះ ថាតើលោកអាចសង្កេតឃើញស្ថានភាពធ្វើទារុណកម្ម ដូច្នោះដែរទៀត ឬទេ ដែលថា ជនជាប់ចោទគាត់ធ្វើការងារ គឺគាត់ធ្វើការសួរចម្លើយអ្នកទោសដទៃៗទៀត? ថាតើលោកឃើញមានការផ្លាស់ប្តូរសំណុំឯកសារទាក់ទងទៅនឹងការសួរចម្លើយទាំងអស់ នោះដែរ ឬទេ?

**ឆ៖** ដើម្បីជាសាក្សីទៅលើព្រឹត្តិការណ៍នេះ គឺវាចាំបាច់-- គឺ ឌុច មានតុចល័តមួយនៅខាងក្រៅ នៅក្រោមខ្ទមរបស់អ្នកទោស ។ ហើយគឺខ្ញុំបញ្ជាក់ទៅលើបញ្ហាហ្នឹង គឺយើងឃើញមានអង្រឹងនៅខាងក្រៅ ។

ដូច្នេះ អ្នកយាមគឺនៅក្នុងអង្រឹង ។ នៅពេលដែលអត់មានភ្លៀង គឺខ្ញុំអាចឃើញ ឌុច ធ្វើការនៅខាងក្រោយ ជនជាប់ចោទធ្វើការងារនៅខាងក្រោយតុនោះ ។ ប៉ុន្តែ អ្នក ផ្សេងៗមិនអាចមើលឃើញទេ ។ ដោយសារតែខ្ទមនេះ វានៅកៀកនឹងខ្ទមដទៃទៀត គឺអ្នកទោសមិនអាចមើលឃើញ ដោយងាយស្រួលនោះទេ ។ អ្នកទោសគឺដើរចុះដើរឡើងនៅតាមខ្ទម គឺយើងឃើញថា ខ្ទមនោះនៅខាងស្តាំនៃខ្ទមអ្នកយាម ហើយអ្នកទោសតែងតែក្រាបចុះ ឬក៏ដេកនៅលើដី គឺខ្ទមដែលនៅទល់មុខនឹងខ្ទមអ្នកទោស ។ គឺខ្ញុំអាចឃើញនូវអ្វីដែលកើតឡើងនៅជុំវិញខ្ទមសម្រាប់អ្នកយាម ប៉ុន្តែមិនមែនជាខ្ទមមួយដែលគេដាក់អ្នកទោសនោះទេ ។ ហើយនៅក្នុងករណីណាមួយក៏ដោយ គឺដោយសារតែវាមានភ្លៀងច្រើនពេលនោះ នៅពេលដែលខ្ញុំនៅទីនោះ ឌុច នៅក្នុងខ្ទមហ្នឹង ។ ខ្ញុំឆ្លើយតបទៅនឹងសំណួររបស់លោកចៅក្រម ការចងចាំដែលខ្ញុំមានអំពីបញ្ហាហ្នឹង ។ ខ្ញុំឃើញមានអ្នកចេញចូលភាគច្រើន ហើយខ្ញុំឃើញមនុស្សចូលទៅ ប៉ុន្តែខ្ញុំអត់ឃើញគេចេញមកវិញទេ ។ ហើយប្រសិនបើគេចេញមកវិញ គឺរយៈពេលយូរមែនទែន ។

ហើយខ្ញុំបានឃើញទាហានផងដែរ មកដល់នៅល្ងាចមួយ ហើយស្អែកឡើងចេញទៅវិញ គឺទាហាននៅក្នុងក្រុម ហើយឃើញច្រើន ហើយឃើញមានពាក់ស្បែកជើង ។ យើងឃើញ អ្នកយាមមិនគ្រប់គ្រាន់ក្នុងការយាមចំពោះការរត់គេចខ្លួនអីផ្សេងៗ ។ ដូច្នេះហើយមានទាហាន ។

**ស៖** អរគុណ ។ ចំពោះផ្នែកមួយទៀតនៃសំណួររបស់ខ្ញុំ លោកមានឃើញការផ្លាស់ប្តូរនូវសំណុំឯកសារផ្សេងៗដែរឬទេ? លើកលែងតែបង្ហាញដែលពាក់ព័ន្ធ សំណុំរឿងពាក់ព័ន្ធនឹងលោក សំណុំឯកសារទាក់ទងទៅនឹងការសួរចម្លើយ?

**ឆ៖** ខ្ញុំអត់ចាំទេ ។

[០៩:២០:៤៤]

**ស៖** អរគុណ ។ ឥឡូវនេះប្រហែលជា ប្រហែលជាមានបញ្ហាទាក់ទងនឹងការបកប្រែ។ កាលម្សិលមិញលោកបានជ្រាបយើងខ្ញុំនៅក្នុងការលើកឡើងមួយដែលថាអាហារ ចុងក្រោយមុនពេលដែលលោកត្រូវបានគេដោះលែង ហើយជាពិសេសសន្ទនា ដែលលោកសន្ទនាជាមួយនឹងជនជាប់ចោទដែលនៅពេលនោះគាត់សារភាពថា គាត់ខ្លួនឯងវាយអ្នកទោស ដើម្បីឲ្យអ្នកទោសឆ្លើយ ។ ប៉ុន្តែជាថ្មីម្តងទៀត ខ្ញុំសូមឲ្យមានការអនុគ្រោះ ពីលោក ប្រសិនបើមិនមានការបកប្រែត្រឹមត្រូវ ។ លោកហាក់ដូចជាលើកឡើងថា ឌុច បាននិយាយជាមួយលោក ការងារនេះ គឺពាក់ព័ន្ធនឹង-- គាត់ធ្វើឲ្យគាត់ធ្វើការងារនោះ ។ ហើយគឺខ្ញុំអានសៀវភៅរបស់លោក ហើយលោកបានសរសេរអំពីកំណត់ហេតុនៃការសួរចម្លើយ ហើយខ្ញុំអត់ដឹងថានៅកន្លែងណាទេនៅក្នុងសៀវភៅនោះ ។ ហើយនៅពេល នោះ គឺមានព្រឹត្តិការណ៍ដែលនៅពេលអាហារចុងក្រោយនោះ គឺជនជាប់ចោទបាន និយាយអំពីវិប្បដិសារីជូនលោក ហើយនិងការសោកស្តាយ ដែលពាក់ព័ន្ធទៅនឹងការងារ ហ្នឹង ។ ដូច្នេះសូមឲ្យលោកធ្វើការបំភ្លឺទៅលើបញ្ហាហ្នឹង ។

ថាតើលោកចាំទេនៅថ្ងៃហ្នឹងថា គឺនៅពេលនោះ គឺគាត់មានការសោកស្តាយក្នុងពេលញ៉ាំអាហារនោះ ឬក៏គ្រាន់តែវាជាការសង្ស័យមតែប៉ុណ្ណឹងដែរ ឬក៏ជាការចងចាំ ដែលលោកចាំទៅលើបញ្ហាហ្នឹង?

[០៩:២៣:០៥]

**ឆ៖** បាទ, លោកចៅក្រម ខ្ញុំមានការភ័ន្តច្រឡំ ជាការពិតណាស់ ទាក់ទងទៅនឹងចំណុចមួយនេះ ។ ហើយគឺនិយាយអំពីអ្វីដែលកើតឡើង គឺអ្វីដែលខ្ញុំបានឃើញ ហើយខ្ញុំសរសេរទៅលើចំណុចនេះ និងចំណុចផ្សេងៗ ។ ហើយភាពពិតប្រាកដនៃព្រឹត្តិការណ៍នោះ នៅលើអង្គហេតុដែលកើតឡើងនៅទីនោះ ហើយខ្ញុំបានសរសេរនៅក្នុងសៀវភៅរបស់ខ្ញុំ គឺវាមិនហួសពីអ្វីដែលខ្ញុំចងចាំពីព្រឹត្តិការណ៍ទាំងអស់

នោះទេ ។ ដូចដែលគេបានលើកឡើងប្រហែលជាអាចមានខុសទៅលើចំណុចហ្នឹង ខ្ញុំអត់ឃើញគ្រប់ព្រឹត្តិការណ៍ទាំងអស់ទេ ។ ហើយចំពោះករណីនេះ គឺខ្ញុំមិនអាចចងចាំទៅលើអារម្មណ៍របស់ខ្ញុំ ដែលខ្ញុំអាចរៀបរាប់សាមសិបឆ្នាំក្រោយ ថាមានអ្វីកើតឡើងទៅលើព្រឹត្តិការណ៍ទាំងអស់នោះទេ ដោយសារតែខ្ញុំ មិនអាចរៀបរាប់ដោយលក្ខណៈរស់រវើក ទៅលើបញ្ហាហ្នឹងទេ ។

នេះជាអ្វីទាក់ទងទៅនឹងអារម្មណ៍ ហើយវាផ្តល់ទៅលើបញ្ហាហ្នឹង អត្តនោម័តនូវអ្វីដែលកើតឡើងក្នុងរយៈពេលបីខែនៅទីនោះ ។ សាមសិបឆ្នាំក្រោយមក គឺជាអ្វីដែល-- គឺជារឿងរ៉ាវផ្សេង ដែលតម្រូវឱ្យខ្ញុំទាមទារឱ្យខ្ញុំប្រយ័ត្នក្នុងការនិយាយស្តី ។

ដូច្នេះ ក្នុងការឆ្លើយតបទៅនឹងសំណួររបស់លោក គឺខ្ញុំអត់មានបានឮ ជនជាប់ចោទ ឌុច បញ្ជាក់ឬបង្ហាញអំពីវិប្បដិសារីណាមួយនោះទេ ។

ខ្ញុំចាំ គឺខ្ញុំចាំ គឺការរៀនខ្លាសរបស់ ឌុច នៅពេលដែលគាត់ប្រាប់ខ្ញុំថា គាត់គឺបានវាយអ្នកទោសឬក៏ ហើយប្រសិនបើគាត់មិននិយាយជាមួយខ្ញុំនៅលើបញ្ហានេះ គឺខ្ញុំមិនចាំទេ ។ ហើយនៅពេលដែលគាត់ និយាយអ៊ីចឹង គឺខ្ញុំចាំទៅលើបញ្ហាហ្នឹង គាត់មិនមានលក្ខណៈងាយស្រួលក្នុងការនិយាយទេ ។ ហើយខ្ញុំចាំថា គឺវាមាន នៅពេលនោះ វាជាបញ្ហានិយាយមួយដ៏ស្មោះត្រង់ ហើយគឺគាត់មិន-- ហើយអ្វីដែលគាត់មិនបានធ្វើ ហើយគាត់បង្ខំនិយាយ ហើយនឹងលើកឡើងទៅលើបញ្ហាហ្នឹង ។ ហើយគាត់ត្រូវតែនិយាយថា វាជាកាតព្វកិច្ចរបស់គាត់ ។

ប្រសិនបើពាក្យកាលពីម្សិលមិញនោះ ខ្ញុំគិតថាខ្ញុំអត់ចាំទេ ហើយប្រហែលជាមិន ពាក្យដែលគាត់ប្រើនោះទេ ចំពោះពាក្យហ្នឹង ។

[០៩:២៦:៤៥]

**ស៖** លោកយល់ស្របជាមួយខ្ញុំ ថាមានភារកិច្ច គឺមិនមានន័យថា បង្ខំខ្លួនឯងឱ្យទទួល ឱ្យសម្រេចទៅលើភារកិច្ចទាំងអស់នោះទេ ។ លោកអាចកែប្រែខ្ញុំ ប្រសិនបើមានកំហុស ។ លោកបាននិយាយថា ក្នុងពេលឃុំខ្លួនលោក ជនជាប់ចោទ គឺបង្ហាញវិប្បដិសារីចំពោះលោក ។ ហើយក្នុងពេលការនិយាយជជែកគ្នានោះ ដែលលោកសរសេរ នៅក្នុងសៀវភៅ ហើយនៅក្នុងកំណត់ហេតុសួរចម្លើយរបស់លោក ហើយសាមសិបឆ្នាំក្រោយ វាជាការពិត ដែលថាយើងដឹងអំពីបញ្ហាទាំងអស់នេះ ។

ចម្លើយរបស់លោក គឺការឆ្លុះបញ្ចាំងអំពីកាលៈទេសៈទាំងអស់នោះ ប៉ុន្តែកាតព្វកិច្ចក្នុងការបំពេញការងារទាំងអស់នោះ គឺលោកមិនបានលើកឡើងនៅក្នុងចម្លើយរបស់លោក ឬក៏ក្នុងការឆ្លើយរបស់

លោក ។

ដូច្នេះ វាជាចំណុចល្អជាងហ្នឹងដែរឬទេ? គឺអ្វីទាំងអស់នោះ គឺលោកបានឃើញដោយខ្លួន ឬត្រឹមត្រូវដែរឬទេ?

**ឆ៖** គាត់បាននិយាយជាមួយខ្ញុំថា គឺគាត់មិនចូលចិត្តចំពោះភារកិច្ចនោះ ។ ខ្ញុំខ្លាច ថា ខ្ញុំបានសរសេរចំណុចមួយចំនួន ហើយវាដាក់ចេញនូវអ្វីដែលខ្ញុំចងចាំ ។ ហើយខ្ញុំមិនខ្លាចថា ខ្ញុំមិនចាំនូវការចងចាំរបស់ ខ្ញុំពិតនៅពេលដែលខ្ញុំសរសេរសៀវភៅប្រហែល ជាខ្ញុំអត់មាននូវការចងចាំ ។ ប៉ុន្តែខ្ញុំបានចាំថា ឌុច គាត់បានបង្ហាញករណី ដែលថាគាត់ធ្វើការងារហ្នឹង ជាកាតព្វកិច្ច ដោយមិនមានការសប្បាយចិត្តទេ ដោយសារអ្នកទោស គឺគេមិននិយាយការពិត ដោយខ្លួនគេផ្ទាល់ ។

**ស៖** អ៊ីចឹង គឺការសន្ទនានេះ គឺលោកធ្វើឡើងជាមួយឌុច ឬក៏យ៉ាងម៉េច?

**ឆ៖** អត់ទេ គឺនៅយប់ យប់មុនថ្ងៃខ្ញុំ-- គេត្រូវបានដោះលែង មិនមែនថ្ងៃទី២៤ទេ គឺថ្ងៃទី២៥ គឺមានការពន្យារបន្តិចនៅក្នុងការដោះលែងខ្ញុំ គឺនៅពេលវេលាមួយ នៅពេល រសៀលមួយ នៅពេលល្ងាចមួយដែល ឌុច ហើយខ្ញុំនៅទីហ្នឹង ។ ហើយខ្ញុំនៅកៀកក្បែរភ្លើងដែលខ្ញុំអង្គុយ ហើយគាត់អង្គុយនៅទីនុំង ហើយមានអ្នកយាមក្មេងមួយ ហើយគឺគាត់មក ហើយមានគាត់ច្រៀងចម្រៀងបដិវត្តន៍នៅពេលហ្នឹង ។ អរគុណលោក រ៉ូបឺត ពេទីត ។

[០៩:៣០:១៣]

**ស៖** នៅការស៊ើបអង្កេត ហើយលោកបាននិយាយថា លោកមិនមែនជាជនរងគ្រោះនៃការធ្វើទារុណកម្ម ។ ចុះពំពោះការធ្វើទារុណកម្មខាងស្មារតីវិញតើលោកទទួលរងដែរឬទេ? ហើយចំណុចជាក់លាក់ជាងហ្នឹងនៅក្នុងសៀវភៅរបស់លោក លោកបានលើកឡើងព្រឹត្តិការណ៍ពីរ ការកើតឡើងចំនួនពីរ ។

នៅក្នុងព្រឹត្តិការណ៍មួយក្នុងចំណោមពីរហ្នឹង ជនជាប់ចោទឲ្យលោកជឿថា គឺលោកត្រូវបានរកឃើញពិរុទ្ធភាព ហើយដូច្នេះហើយទើបលោកទទួលផលលំបាកបែបនុំង។ ហើយព្រឹត្តិការណ៍នោះ គឺវានាំឲ្យមានប្រតិកម្មនៅក្នុងអារម្មណ៍របស់លោក ហើយឃើញព្រឹត្តិការណ៍នុំង គឺ ឌុច បាននិយាយថា គាត់និយាយកំប្លែងទេ ។ គាត់សើចហាស់ៗ តើលោកបញ្ជាក់ថា ព្រឹត្តិការណ៍នោះពិតជាកើតឡើងដែរឬទេ? នៅក្នុងលក្ខណៈដែលខ្ញុំបានបញ្ជាក់ហ្នឹង ហើយសូមឲ្យមានការកែប្រែប្រសិនបើ កែប្រែទៅលើកំណត់ហេតុឲ្យបានជាក់លាក់ ប្រសិនបើមានលើសខុស ។

**ឆ៖** ប៊ីហ្ស គឺខ្ញុំសូមលើកឡើង បញ្ជាក់ទៅលើបញ្ហាហ្នឹង ហើយជនជាប់ចោទ នៅទីនុ៎ងខ្ញុំចាំ ។ គឺវាពិបាកក្នុងការចាំជាក់លាក់ថា ពាក្យគេប្រើយ៉ាងម៉េចជាក់លាក់នៅពេលនោះ? វាពិបាកក្នុងការរំឭកឡើងវិញ ពាក្យដែលប្រើនៅពេលនោះ ដោយគាត់ និង ខ្ញុំ ប៉ុន្តែនៅពេលមួយដែលកើតឡើង នៅពេលដែលខ្ញុំត្រឡប់ នៅពេលដែលគាត់ត្រឡប់ មកពីកិច្ចប្រជុំប្រចាំសប្តាហ៍ ។ ការធ្វើដំណើរប្រចាំសប្តាហ៍របស់គាត់ គឺវាជាចំណុចមួយដែលខ្ញុំចងចាំ ហើយខ្ញុំសូមបញ្ជាក់ទៅលើបញ្ហាហ្នឹង គឺមានកើតពិតប្រាកដមែន ហើយគឺមានការនិយាកំប្លែងលេងអ៊ីចឹងមែន ។ ហើយចំណុចចុងក្រោយនៃគោលបំណងហើយ គោលបំណងនៃការឃុំខ្លួនរបស់ខ្ញុំនោះ គឺត្រូវបានប្រើ-- គាត់ប្រើដោយ គាត់លើកឡើងថា ខ្ញុំត្រូវបានគេរកឃើញអ៊ីចឹងមែន ។ ហើយគាត់និយាយជាមួយខ្ញុំជាភាសាបារាំងនៅពេលនុ៎ង ហើយប្រតិកម្មរបស់ខ្ញុំ គឺមានលក្ខណៈតឹងតែងដែលខ្ញុំបានដឹងតាំងពី ថ្ងៃម្សិលមិញ ហើយគាត់បានចំណាយថ្ងៃបន្ទាប់មកពិភាក្សាបញ្ហាមួយចំនួនជាមួយនឹងមេរបស់គាត់ ហើយករណីរបស់ខ្ញុំ គឺនៅក្នុងរបៀបវារៈ ហើយខ្ញុំជាប់ឃុំបីខែ ហើយគឺថាការងារ នេះមិនអាច វាចំណាយពេលយូរក្នុងការពិភាក្សាទេ ។

ហើយការប្រកាសដោយលក្ខណៈសាកល្បងចំពោះខ្ញុំ ចំពោះបទចោទ ចំពោះខ្ញុំ នោះ ។ ខ្ញុំគឺបានសរសេរចេញមែន ហើយនោះជាចំណុចដែលខ្ញុំ-- គាត់លើកឡើង ហើយគាត់បានជម្រាបខ្ញុំថា គឺជាការធ្វើការប្រកាសអ៊ីចឹង ។

[០៩:៣៣:៥៩]

**ស៖** សហព្រះរាជអាជ្ញា តើលោកអាចប្រាប់ខ្ញុំបានដែរឬទេ? អំពីការកើតឡើង ដូចគ្នាដែរឬ--មួយនឹងដែរ នៅពេលដែលមួយនោះ ជនជាប់ចោទគឺទាញផលប្រយោជន៍ ពីទំនាក់ទំនងរបស់លោកជាមួយនិងមិត្តភក្តិរបស់លោកឈ្មោះ សុន ។

លោកជឿថា នឹងមានបញ្ហាមួយចំនួនកើតឡើង ហើយមានបញ្ហាមួយចំនួនទៅ លើករណីហ្នឹង ?

**ឆ៖** លោក ហ្វ្រង់ស្វ័រ ប៊ីហ្ស លោកយោងទៅអ្វីដែលកើតឡើង ចំពោះអ្នកជំនួយការរបស់ខ្ញុំពីរនាក់ ដែលគេត្រូវបានគេដោះខ្នោះ ហើយអាចដើរលេងជុំវិញមន្ទីរ ឬយ៉ាងម៉េច គឺវាអាចកើតឡើងនៅពេល ឌុច ឲ្យអ្នកទោស-- ឲ្យអ្នកយាមពីរនាក់ គាត់ដោះលែង សុន ហើយគាត់បានលើកឡើងទៅលើបញ្ហានឹងទៅ សុន ។ ប្រសិនបើខ្ញុំចាំត្រឹមត្រូវទៅលើចំណុចទាំងអស់នោះ គឺគាត់បានអានសៀវភៅ--ខ្ញុំគួរតែអានសៀវភៅខ្ញុំម្តងទៀតមុនពេលដែលខ្ញុំមកទីនេះ ។ គឺមានព្រឹត្តិការណ៍ដែល ឌុច គាត់និយាយលេងនិយាយជាមួយ សុន គឺថា គឺគាត់នឹងភរប្រហែលជា៥ឆ្នាំ ។

ឡាយ ដែលធ្វើការងារនៅកន្លែងថែរក្សា ហើយយើងធ្វើការងារប្រហែលជា ៦ខែ ហើយគឺខ្ញុំមិនសូវស្គាល់ជាមួយគាត់ប៉ុន្មានទេ ។ ហើយគឺខ្ញុំនិយាយជាមួយ ឡាយ ហើយ និងខ្ញុំ ហើយគឺគាត់មានបទពិសោធន៍ខ្ពស់ក្នុងការងារវិជ្ជាជីវៈ ហើយ សុន បាននិយាយថា ប៊ីហ្ស៊ូ គាត់នឹងចាកចេញហើយ ហើយគាត់នឹងមានជម្រើស គាត់អាចជ្រើសរើស សុន ឬក៏ជ្រើសរើស ឡាយ ហើយ ប៊ីហ្ស៊ូ គឺគាត់គិតថា ឡាយ គួរត្រូវដោះលែង ហើយឲ្យ សុន នៅទីនោះ ។ ហើយ ឡាយ បន្ទាប់មកត្រូវបានដោះលែងទៅៗកន្លែង-- ចាកចេញទៅជាមួយនិង ប៊ីហ្ស៊ូ ។ សុន គឺគាត់នៅស្ងៀម ហើយគាត់ថា លោកជឿខ្ញុំដែរឬទេ? តើវាអាចទៅរួចដែរឬទេ? គឺមានការឈឺចាប់ណាស់ នៅពេលដែលលោក សុន និយាយជាមួយខ្ញុំថា វាអាចទៅរួចចំពោះការនិយាយដូច្នេះ ។ ហើយ ឌុច បានលើកឡើងថា ហើយៗគឺគាត់សើចហើយគាត់ថា អរ! គឺគាត់ សុន នោះជឿខ្ញុំមែន ហើយគឺ សុន ហើយនិង ឡាយ ត្រូវបានគេដោះខ្នោះនៅពេលនោះជាមួយគ្នា ។

**លោក រ៉ូប៊ីត ពើទីត៖**

អរគុណលោកចៅក្រម ខ្ញុំសួរអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះ ប្រគល់វេទិកានេះទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការសួរសំណួរដល់សាក្សីរូបនេះ ។ ជាដំបូងនេះ សូមអញ្ជើញ មេធាវីក្រុម១ មុន ។

**សួរដោយលោក អាឡាំង វែនណឺ៖**

**ស៖** អរគុណលោក លោកស្រីចៅក្រម អរុណសួស្តីលោក ប៊ីហ្ស៊ូ! ខ្ញុំ អាឡាំង វែនណឺ ។

ខ្ញុំតំណាងដើមបណ្តឹងរដ្ឋប្បវេណី៣៨នាក់ នៅក្នុងកិច្ចដំណើរការនេះ ខ្ញុំមានសំណួរមួយចំនួនប៉ុណ្ណោះចំពោះលោក ។ សំណួរទី១ ការពីម្សិលមិញលោក និយាយអំពីបុព្វសិទ្ធិរបស់លោក ឬក៏ឋានៈរបស់លោកនៅម-១៣ ។ លោកទទួលបានបុព្វសិទ្ធិ ឬផលប្រយោជន៍ ឧទាហរណ៍ អាហារ ហើយលោកមិនត្រូវបានគេវាយ ។ អ្វីដែលលោកបានប្រាប់យើងកាលពីម្សិលមិញ នៅក្នុងសៀវភៅគឺវានិយាយច្បាស់ថា ជនជាប់ចោទ គឺផ្តល់ឲ្យលោកទៅលើកាលៈទេសៈដែលមានផលប្រយោជន៍បែបនេះ ។ លោកហ្វ្រង់ស្វ័រ ប៊ីហ្ស៊ូ តើលោកដឹងទេថា ឌុច គាត់បានទទួលការអនុញ្ញាតពីមេរបស់គាត់ដែរឬទេ ក្នុងការផ្តល់បុព្វសិទ្ធិឲ្យលោកដូច្នោះ?

[០៩:៣៩:១៣]

**សាក្សី TC-1៖**

**ឆ៖** ខ្ញុំអត់ដឹងទេ ។ ខ្ញុំគ្មានវិធីណាមួយដឹងទេ ។ ខ្ញុំអាចធ្វើការសន្និដ្ឋាន ហើយប៉ុន្តែខ្ញុំពិតជាអត់អាចឆ្លើយសំណួរនេះមែន ។

**ស៖** កាលពីម្សិលមិញលោកបានលើកឡើងថា ជនជាប់ចោទមិននិយាយច្រើន ទេ ហើយគាត់រវល់នឹងការងារ និងភារកិច្ចរបស់គាត់ ។ លោក ប៊ីហ្សូ ថាតើលោកបាន ឃើញ ហើយនិងឮអ្វីខ្លះដែលធ្វើឲ្យលោកយល់ដូច្នោះ?

**ឆ៖** គឺវាច្បាស់ណាស់ ពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទនៅពេលនោះ ហើយ គឺគាត់មានកេរ្តិ៍ឈ្មោះក្នុងចំណោមអ្នកយាមគឺអ្នកយាមក្មេងៗគឺគោរពគាត់ខ្លាំងណាស់។ ដោយសារតែការងារដែលគាត់បំពេញក្នុងរយៈពេលច្រើនម៉ោងទៅលើការងារសំណុំរឿង និងការងារទូទៅ គាត់ធ្វើការហ្នឹងច្រើនមែនទែន ។ ដូច្នេះហើយ គឺគាត់មានកេរ្តិ៍ឈ្មោះថា គាត់ល្បីថា គាត់អ្នកជាមួយដែលទទួលខុសត្រូវ ហើយដូច្នេះហើយ គឺគាត់ទទួលបាន ការគោរពក្នុងចំណោមអ្នកយាម ។ ហើយខ្លួនខ្ញុំផ្ទាល់អាចឃើញគឺចម្លើយរបស់ខ្ញុំផ្ទាល់ គឺវាស៊ីគ្នានូវអ្វីដែលខ្ញុំនិយាយមួយអាទិត្យ ឬក៏ពីរអាទិត្យមុន ។ ហើយគឺខ្ញុំធ្វើការប្រៀប ធៀបនូវអ្វីដែលខ្ញុំបាននិយាយ ហើយនិងបានសរសេរ គឺខ្ញុំពិនិត្យយ៉ាងហ្មត់ចត់ ឃើញ ថាមានការពិនិត្យយ៉ាងហ្មត់ចត់ ។ ហើយនៅថ្ងៃចុងក្រោយពីរថ្ងៃ គឺនៅពេលដែលមានការដោះឆ្នោះផ្សេងៗនៅពេលដែលខ្ញុំអាចនិយាយ ហើយនិងភរ សុន និយាយជាមួយ ឡាយ ហើយនិង សុន ។ គឺជាការសន្ទនាគ្នាលេងនៅពេលនោះ ។ និយាយប៉ុន្មានប្រយោគទេ ជាមួយនិងអ្នកដែលជាប់ឃុំជាមួយខ្ញុំ ហើយខ្ញុំឃើញមានអារម្មណ៍ដែលជនជាប់ចោទ គឺគាត់ប្តេជ្ញាជាមួយនឹងការងាររបស់គាត់ណាស់ ។ ហើយគាត់ធ្វើការងារគាត់ដោយទទួលខុសត្រូវមួយ ។

[០៩:៤២:០៥]

**ស៖** ខ្ញុំសូមបំភ្លឺទៅលើចំណុចមួយ កាលពីម្សិលមិញលោកបាននិយាយថា នៅពេលដែលបុគ្គលមួយត្រូវបានយកគេទៅសម្លាប់ចោល គឺគាត់មិនត្រូវបានគេជម្រាបពីបញ្ហាហ្នឹងទេ? ហើយនៅពេលដែលលោកឆ្លើយសំណួររបស់លោកចៅក្រម ឡាវែន៍ ខ្ញុំមានអារម្មណ៍ថា លោកមិនមែនជាសាក្សីអ្នកឃើញផ្ទាល់ភ្នែកចំពោះការសម្លាប់ទេ នៅពេលដែលលោកនិយាយថា គេនាំទៅសម្លាប់ពួកហ្នឹងចោល គឺពួកដែលត្រូវបានគេសម្លាប់ចោល គឺមិនដែលត្រូវបានគេប្រាប់ទេ ។

**ឆ៖** ខ្ញុំអាចនិយាយអំពីករណីរបស់ខ្ញុំខ្លួនឯងផ្ទាល់នៅក្នុងករណីនេះជាបឋមសិន ។ ជាការពិត

ណាស់ នៅថ្ងៃទី១ នៅពេលដែលចាប់ខ្លួន មុនពេលដែលមកដល់ ម-១៣ ខ្ញុំត្រូវបានគេចាត់ទុក ហើយធ្វើការវិនិច្ឆ័យ ។

ខ្ញុំត្រូវបានគេធ្វើការវិនិច្ឆ័យឲ្យទទួលទោសប្រហារជីវិត ហើយគឺខ្ញុំត្រូវបានគេរុំមុខ ហើយចងបណ្តើរទៅដោយមានអ្នកមួយចំនួនកាន់អាវុធ ហើយខ្ញុំសួរថា គេយកខ្ញុំទៅណា ហើយនិយាយប្រាប់ខ្ញុំថា អត់អីទេៗ ។ ហើយវាមានន័យថា អត់អីទេចំពោះភាសាហ្នឹង ហើយគេឲ្យខ្ញុំនៅឲ្យស្ងៀម អត់អីទេ ។ ហើយឃ្លាពាក្យហ្នឹង គឺនិយាយដដែលៗមកខ្ញុំ កន្លែងណាក៏ដោយដែលគេយកខ្ញុំទៅ គឺខ្ញុំមិនត្រូវបានគេសម្លាប់ទេ ហើយខ្ញុំមានអារម្មណ៍ខ្លាំងណាស់ថា ខ្ញុំនឹងត្រូវបានគេយកទៅសម្លាប់ ប៉ុន្តែគេនៅតែនិយាយថា អត់អីទេៗរហូត ។

[០៩:៤៣:៥៨]

ហើយជាថ្មីម្តងទៀតគឺ អត់មានអ្វីសង្ស័យទេ ។ គឺអ្វីដែលខ្ញុំជម្រាប និងជម្រាបលោក គឺវាទាក់ទងទៅនឹងព្រឹត្តិការណ៍ទៅលើអង្គហេតុ ហើយគឺពិតណាស់ គឺថាពាក្យថា “អត់អីទេនេះ” នេះគឺវាជាហេតុផលមួយមានន័យថា “កុំឲ្យព្រួយបារម្ភ នៅឲ្យស្ងៀមកុំឲ្យព្រួយបារម្ភ” ។ ពាក្យនេះគឺមានការនិយាយបញ្ជាក់ប្រាប់ខ្ញុំនៅពេលក្រោយមកទៀត។ នៅពេលដែលខ្ញុំត្រឡប់មកកម្ពុជាវិញ ហើយខ្ញុំនិយាយជាមួយប្រជាជនដែលរស់នៅជាមួយខ្មែរក្រហមរាប់-- ប៉ុន្មានឆ្នាំក្នុងអំឡុងពេល៧៥ ទៅដល់៧៩ គឺវាហាក់ដូចជាបង្ហាញថា បុគ្គលដែលនឹងត្រូវបានគេយកសម្លាប់ដោយការសំពង ដោយរំពងឫស្សី គឺអ្នកទាំងអស់នោះ មិនដែលត្រូវបានសម្លាប់ មិនដែលត្រូវគេប្រាប់ពីការសម្លាប់ ឬក៏អំពីអ្វីទាំងនោះទេ ។ ប៉ុន្តែ គឺយើងដឹងច្បាស់ថានៅក្រោយមក គាត់ទាំងអស់ហ្នឹង នឹងត្រូវបានគេទៅសម្លាប់ ។ ខ្ញុំសង្ឃឹមថា ខ្ញុំឆ្លើយចំពោះចម្លើយទាំងអស់នេះច្បាស់លាស់ ។

**ស៖** ខ្ញុំសូមបំភ្លឺ លោកនិយាយពីម្សិលមិញថា គឺបុគ្គលគាត់រាយការណ៍ គឺថាមានអ្នកស្លាប់នៅក្នុងមន្ទីរ ថាមានអ្នកស្លាប់នោះយ៉ាងម៉េច?

**ឆ៖** គឺគាត់ស្លាប់ដោយសារតែជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ ហើយគឺមានការអាណិតរវាងខ្ញុំ គឺគាត់មានការអនុញ្ញាតពី ឌុច ហើយគាត់បានមកនិយាយជាមួយខ្ញុំ ។ គាត់និយាយអំពីឪពុករបស់គាត់ គាត់មានការសោកស្តាយចំពោះអង្គហេតុដែលថា ឪពុករបស់គាត់នៅពេលខ្ញុំនៅម-១៣ នោះ គឺថាឪពុករបស់គាត់បានស្លាប់ ។ គាត់មិនអាចអនុគ្រោះឲ្យខ្លួនឯងនោះទេ ដែរថាគាត់អត់នៅទីនោះជាមួយនឹងឪពុករបស់គាត់ហើយគាត់សន្យាថា គាត់នឹងទៅជិតរបស់ឪពុក នៅថ្ងៃដែលឪពុកស្លាប់ ។ ហើយប្រហែលជា

គឺជាអារម្មណ៍មួយខ្លាំងក្លាចំពោះកាលៈទេសៈនោះ នៅថ្ងៃក្រោយៗមកទៀត ឬក៏ពេលណាមួយមកទៀត គឺគាត់ក៏ទទួលបទពិសោធន៍ ដូចអ្នកដទៃទៀត គឺថាមានជម្ងឺគ្រុនចាញ់ ហើយហ្នឹងគាត់ក៏ស្លាប់ដែរ ។ មុនពេលដែលស្លាប់នោះ គឺគាត់សុំឲ្យជួបជាមួយនឹងអ្នកបារាំងម្នាក់ ហើយបង្ហាញថាគាត់នៅឯណា? ហើយគាត់នៅក្នុងខ្ទម ហើយខ្ញុំអត់ដឹងថា គាត់នៅកន្លែងណាទេ ។ ប៉ុន្តែ អ្នកយាម គឺដោះខ្នោះ ហើយឲ្យខ្ញុំទៅជួប ។ ហើយពេលដែលខ្ញុំទៅដល់ ទៅកៀកគាត់ គាត់ស្គាល់ខ្ញុំ នៅពេលនោះគឺគាត់ស្លាប់ នៅពេលតែប៉ុន្មានសឹហ្គុងប៉ុណ្ណោះ ប៉ុន្មានវិនាទីប៉ុណ្ណោះ នៅពេលខ្ញុំទៅដល់ ។

[០៩:៤៧:៣៤]

ទាំងអស់នោះ គឺជាកាលៈទេសៈទាំងឡាយដែលពាក់ព័ន្ធទៅនឹងបុគ្គលហ្នឹង ហើយ ខ្ញុំមិនដឹងថា គាត់ជាអ្នករាយការណ៍ទៅអ្នកដទៃ ហើយគាត់និយាយថាគាត់មិនបានធ្វើអ្វីខុសទេ ហើយគាត់នៅទីនោះរាប់ឆ្នាំ ។ ហើយគាត់ត្រូវបាន-- គាត់បានមានការសោកស្ដាយ ហើយគឺគាត់សោកស្ដាយដែលថាគាត់មិនត្រូវបានគេដោះលែង មុនពេលដែលឪពុកគាត់ស្លាប់ ។ ហើយនៅពេលនោះ គឺខ្ញុំមិនអាចនិយាយថាបុគ្គលនោះគឺជាអ្នកផ្ដល់ព័ត៌មាន ឬក៏យ៉ាងម៉េចទេ? ហើយមានបុរសចាស់ម្នាក់គាត់ដើរមកកាន់ខ្ញុំ ហើយគាត់ចាស់នៅល្ងាចមួយគាត់ដើរមកកាន់ខ្ញុំ ។ ហើយគាត់បានឲ្យស្ករខ្ញុំកន្លះគីឡូ ហើយបុរសចាស់នេះនិយាយប្រាប់ខ្ញុំថា ខ្ញុំត្រូវបានគេព័ទ្ធនៅពេលដែលមានទាហាន-- មានជប៉ុន ហើយមានបុរសបារាំងព្យាយាមរត់គេចខ្លួន ប៉ុន្តែអត់មានការទទួលជោគជ័យក្នុងការរត់គេចខ្លួន ។ ហើយគាត់-- បុរសចាស់នោះ គាត់លើកទឹកចិត្តដល់ខ្ញុំ ហើយគឺគាត់ព្យាយាមកុំឲ្យខ្ញុំរត់ចេញក្រៅដោយសារតែវាគ្មានវិធីណាមួយអាចរត់ចេញ ។ ហើយគាត់ប្រាប់ថានេះ គឺស្ករវាល្អសម្រាប់ខ្ញុំញ៉ាំ។ ប៉ុន្តែគាត់ថា កុំឲ្យខ្ញុំរត់ ហើយខ្ញុំមានការភ្ញាក់ផ្អើលណាស់ ដែលអ្នកកសិករនោះគាត់មិនមែនជាអ្នកទោសនៅក្នុងមន្ទីរហ្នឹង ។ ហើយគឺ គាត់-- ខ្ញុំមានការភ្ញាក់ផ្អើលដែលថាគាត់ៗធ្វើអំពើមួយដែលគ្រោះថ្នាក់ ដែរថាគាត់មកយកស្ករឲ្យខ្ញុំ ហើយខ្ញុំអរគុណណាស់ ចំពោះស្ករនៅពេលនោះ ។ ហើយខ្ញុំឆ្ងល់ប្រហែលជាបុរសចាស់នោះត្រូវបានប្រាប់ឲ្យមកនិយាយជាមួយខ្ញុំ ហើយព្យាយាមជំរុញឲ្យខ្ញុំកុំឲ្យខ្ញុំរត់ ។ ហើយខ្ញុំត្រូវតែនិយាយថា ខ្ញុំពិតជាចង់រត់ណាស់ តាំងពីថ្ងៃទី១ ខែមករា ខ្ញុំសម្រេចចិត្តរត់ចេញពីនោះ ហើយដោយខ្ញុំគិតថា វាមិនមានវិធីណាមួយខ្ញុំត្រូវបានគេដោះលែង ។ ហើយប្រសិនបើខ្ញុំមិនត្រូវបានគេដោះលែងនៅចុងបីខែនោះទេ គឺខ្ញុំនឹងរត់ ។

**ស៖** ខ្ញុំមានសំណួរមួយចំនួនទៀត លោក លោកស្រីចៅក្រម ។

សំណួរមួយចំពោះការសួរចម្លើយ ខ្ញុំមិនអាចបង្ហាញភស្តុតាងថា ខ្ញុំមិនមានពិរុទ្ធ-ភាព ។ លោក ប៊ីហ្សូ បាននិយាយថា ការនៅមានពេលមួយនោះ លោកមិនអាចបង្ហាញ ថាលោកជាជនស្លូតត្រង់ ហើយឆ្លើយតបទៅនឹងសំណួរ ចំណុចលើកឡើងរបស់លោក រ៉ូប៊ីត ពើទីត លោកនិយាយអំពីការនិយាយរឿងកំប្លែង ។ លោក ប៊ីហ្សូ លោកគិតថា ប្រជាជនខ្មែរ អ្នកដែលមិនមានការទទួលការអប់រំដូចលោកៗ គិតថាប្រជាជនកម្ពុជាដែល រងការសួរចម្លើយដោយជនជាប់ចោទ។ តើពួកគេអាចបង្ហាញអំពីភាពស្លូតត្រង់របស់ពួកគេដូចលោកដែរឬទេ? ដែលលោកទទួលជោគជ័យក្នុងការបង្ហាញថាលោកជាជនស្លូតត្រង់ ។

**ឆ៖** ខ្ញុំគិតថា ដូចជាមិនអាចទេ គឺករណីនេះ មិនអាចទេ គឺខ្ញុំដឹងថា វាមិនអាចទៅ រួច ។ ជាអ្នកទោសដែលគេគ្មានការរត់គេចខ្លួនណាមួយ គឺពួកគេគ្មានជម្រើសអីផ្សេង ក្រៅពីមានទោស ។ ហើយខ្ញុំមានថាការប៉ុនប៉ងក្នុងការនិយាយថា បទចោទលើខ្លួន គឺ មិនត្រឹមត្រូវ ឬគ្មានមូលដ្ឋាននោះ គឺការនិយាយដូច្នោះ គឺធ្វើឱ្យមានលទ្ធផលចៀសមិន រួច គឺការស្លាប់តែម្តង ។ ហើយខ្ញុំមិនច្បាស់ទេ ថាខ្ញុំឱ្យជនជាប់ចោទជឿថាយ៉ាងម៉េច ថាខ្ញុំស្លូតត្រង់យ៉ាងម៉េច? គឺគាត់បង្កើត ហើយគាត់រកព័ត៌មានខ្លួនឯង ចំពោះព័ត៌មានដែលខ្ញុំនិយាយក្នុងពេលសួរចម្លើយ ។ អ្វីដែលខ្ញុំ ដែលគាត់យល់ពី ឡាយ និង សុន ចំពោះសកម្មភាពរបស់ខ្ញុំ គឺវាមានការឈឺចំពោះខ្ញុំនៅក្នុងការចង់ចាំ ហើយ ឡាយ ហើយនិង សុន នៅក្នុងមន្ទីរនោះ គឺជាអ្នកដែល-- ជាចំណុចមួយក្នុងការដោះលែងខ្ញុំ ។ ហើយខ្ញុំគ្មានឆ្លល់អ្វីទេ ហើយគឺថាជានិច្ចកាល គឺជាការបញ្ជាក់របស់ ឡាយ និង សុន នៅពេលដែលពួកគេបញ្ជាក់ទៅលើបញ្ហានៃការដោះលែងរបស់ខ្ញុំ ។

[០៩:៥៣:២១]

**ស៖** ចំណុចចុងក្រោយរបស់ខ្ញុំ នៅក្នុងការសម្ភាសន៍របស់លោក និងអ្នកកាសែត នៅក្នុងកាលពីឆ្នាំទៅមិញ គឺទាក់ទងទៅនឹងបញ្ហានៃបិសាច ដែលយកលោក ទាក់ទងទៅនឹងបញ្ហាមនុស្សធម៌ ហើយលោកទទួលបាននូវបញ្ហាមនុស្សធម៌ ។ ហើយជាការទទួលបានរបស់លោក ហើយគ្នាយើងទទួលស្គាល់ទៅលើបញ្ហាហ្នឹង ប៉ុន្តែលោកមិនជាជនរងគ្រោះរបស់ជនជាប់ចោទ ប៉ុន្តែ លោកត្រូវបានឃុំខ្លួនដោយអង្គការខ្មែរក្រហម ។ ហើយគឺលោកបាននិយាយថា ប្រទេសដែលស្រឡាញ់ ថានៅពេលនេះលោកយល់ឃើញដូចគ្នាទេ ដែរថាមើលឃើញបញ្ហានៅខាងក្រោយការសម្លាប់នោះ ហើយយើងឃើញថា មេខ្មែរក្រហមនៅទីនេះ នៅឃុំនៅទីនោះ ហើយលោកមិនដែលស្គាល់ទៅលើអ្នកទាំងហ្នឹង ។ ឧទាហរណ៍ថា លោក នួនជា ថាតើលោកយល់ដូច្នេះ ដូចលោក នួន ជា ដែរឬទេ? ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ, អ៊ីចឹងមែន ។ ខ្ញុំបញ្ចប់អ្វីដែលខ្ញុំចង់លើកឡើង គឺថាដើម្បីឲ្យយល់ពេញលេញ ហើយយល់ឲ្យស៊ីជម្រៅទៅលើអ្នកពេជ្ឈឃាដ អ្នកសម្លាប់ ដូចជាលោកលើកឡើងអំពី នួន ជា នោះ ។ ជា នួន ជា ឬក៏ជាជនជាប់ចោទនៅទីនេះ គឺថាវិធានការពេញលេញ វាទាក់ទងទៅនឹងការភ័យខ្លាច គឺអ្នកអាចធ្វើទៅបាននៅពេលដែលអ្នកយល់អំពីបញ្ហាមនុស្សធម៌របស់បុគ្គលមួយ ។ ហើយប្រសិនបើយើងឲ្យអ្នកទាំងអស់នោះក្លាយទៅជាបិសាច ក្លាយទៅជាអ្នកដែលមិនមែនជាមនុស្សនោះ គឺគាត់ យើងមិនអាចបញ្ជាក់កំណត់ថា ពួកគេជាមនុស្សទេ គឺដូច្នេះហើយ គឺយើងមិនអាចយល់អំពីអ្វីដែលពួកគេបានធ្វើ ហើយប្រសិនបើយើងព្យាយាមយល់អ្នកទាំងអស់នោះ នៅក្នុងស្ថានភាពណាមួយ យើងអាចដឹងអំពីបញ្ហានឹងឲ្យបានជ្រៅ ។ ប៉ុន្តែ យើងត្រូវការ-- មិនត្រូវការរើសអើងអំពីអ្នកដែលថា អាចសម្លាប់ និងអ្នកមិនអាចសម្លាប់ ហើយយើងហាក់ដូចជាមានការភ័យខ្លាច ចំពោះការយល់អំពីការសម្លាប់ នៅពេលដែលយើងមើលអំពីការសម្លាប់ ដែលថាវាធ្វើឡើងចំពោះមនុស្ស យើងព្យាយាមធ្វើយ៉ាងណាយល់ ។

ខ្ញុំគិតថា មិនមានការអត់ឱនទោសណាមួយបាននោះទេ ។ អ៊ីចឹង ប្រហែលជា យើងអាចអត់ទោសឲ្យខ្លួនឯងបាន ប៉ុន្តែ សម្រាប់ដែលស្លាប់ទាំងអស់នោះ គឺថាយើងមិនអាចធ្វើបានទេ ។ ហើយអំពើវន្ទត់ដែលបានកើតឡើងមកនោះ ដែលបានធ្វើនៅក្នុងប្រទេសកម្ពុជានោះ នេះគឺថាមិនគ្រាន់តែជាចំណុចមួយដែលកើឡើងនៅពេលតែមួយនោះទេ ប៉ុន្តែ គឺកើតនៅក្នុងប្រទេសទាំងមូល ។ សម្រែករបស់ជនរងគ្រោះហ្នឹងគឺថានឹងត្រូវបានគេឮ ហើយយើងត្រូវមិនអនុញ្ញាតខ្លួនយើង របស់យើងនោះគឺថាមិនត្រូវគិតថាវាមិនមែនឮខ្លាំងពេកនោះទេ ។ ប៉ុន្តែ អ្វីដែលយើងអាចថ្កោលទោសបានចំពោះជនជាប់ ចោទនោះ គឺថាមិនអាចថាវាធ្ងន់ធ្ងរពេក ឬក៏គ្រាន់នោះទេ ពីព្រោះនោះមិនជាចំណុចដែលយើងចង់លើកថា ត្រូវអភ័យទោសនូវអ្វីដែលកើតបាននោះទេ ។ ប៉ុន្តែ វិធីរបស់ខ្ញុំ គឺមិនមែនជាវិធីប្រហែលជាដែលជនរងគ្រោះគេនឹងជ្រើសនោះទេ ប៉ុន្តែ អ្វីដែលជាវិធី របស់ខ្ញុំ គឺខ្ញុំព្យាយាមអំពីអ្វីដែលបានកើតឡើងនៅក្នុងព្រៃរបស់ប្រទេសកម្ពុជា ហើយក៏ដូចជានៅក្នុងប្រទេសដទៃទៀត ឬក៏នៅក្នុងកាលៈទេសៈផ្សេងៗទៀតនៃប្រវត្តិសាស្ត្ររបស់យើង ព្រមទាំងប្រវត្តិសាស្ត្រក្នុងពេលថ្មីៗកន្លងមកនេះ ។

[០៩:៥៧:៥៦]

**លោក អាឡាំង វែនណើ៖**

សូមអរគុណ ដែលបានឆ្លើយសំណួររបស់ខ្ញុំនេះ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមអញ្ជើញ មេធាវីក្រុមបន្ទាប់ទៀត ក្រុមពីរ ។

សូមអញ្ជើញ មេធាវីក្រុមពីរ បើសិនជាមានសំណួរត្រូវសួរ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

សូមអរគុណ លោកប្រធាន ។

ខ្ញុំឈ្មោះ ស៊ីលឃីស្ទួត ហ្សីនស្គី ខ្ញុំជាសហមេធាវីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។

លោក ប៊ីហ្សូ ខ្ញុំនឹងរំឭកឡើងវិញអំពីទំនាក់ទំនងរវាងលោក ជាមួយនឹងជនជាប់ចោទនៅក្នុង អំឡុងបីខែ ដែលលោកនៅទីនោះ ដែលលោកបានរៀបរាប់ ។ ហើយនៅក្នុងការបកប្រែជាភាសាអង់គ្លេស ហ្នឹង គឺបាននិយាយថា គឺជាប្រភេទនៃការស្គាល់គ្នាមួយ ។

**ស៖** តើលោកអាចនិយាយប្រាប់បានទេ? តើមានភាពញឹកញាប់ ឬក៏បាននិយាយ គ្នាពីអ្វីខ្លះ? ដែលលោកបាននិយាយលេង ឬក៏និយាយទំនាក់ទំនងទៅតាមអ្វីដែលលោកបាននិយាយ ហើយដែលខ្ញុំបាន យល់កាលពីម្សិលមិញ ជាមួយនឹងជនជាប់ចោទនោះ ។

[០៩:៥៩:៤១]

**សាក្សី TC-1៖**

**ឆ៖** ខ្ញុំបានឃើញហើយលោកប្រធានជំរំ គឺលោក ឌុច ហ្នឹង ។ គឺខ្ញុំមិនអាចដើម្បីទប់នូវទឹកភ្នែក និងអ្វីៗដែលខ្ញុំបានទទួលរងនោះទេ ។ អំពីអយុត្តិធម៌ដែលខ្ញុំបាន ទទួលដែលខ្ញុំមានអារម្មណ៍នៅពេល នោះ ហើយនោះគឺជាអ្វីដែលកើតឡើងមាននៅក្នុង អារម្មណ៍របស់ខ្ញុំជាញឹកញាប់ដោយលាយឡំជាមួយ នឹងកំហឹងផងដែរ ។ កំហឹងរបស់ខ្ញុំ ពេលនោះ គឺមិនក្រៀតក្រោធពេកនោះទេ ប៉ុន្តែ គឺមានកំហឹង នៅក្នុងខ្លួនរបស់ខ្ញុំហើយនៅក្នុងអំឡុងពេលនៃការសួរចម្លើយ ឌុច បានសួរខ្ញុំ ។ ពេលនោះ គឺថាខ្ញុំបាន ស្វែងរកវិធីដើម្បីបញ្ចេញ ឬក៏បង្ហាញនូវអយុត្តិធម៌នៃការចោទប្រកាន់មកលើរូបខ្ញុំនោះ ។ ហើយជួន កាលខ្ញុំហាក់បីដូចជាមានអារម្មណ៍ធូរបន្តិចនៅពេលដែលខ្ញុំបានសួរសំណួរបក ទៅគាត់វិញ។ គឺថាធ្វើ ឲ្យខ្ញុំមានអារម្មណ៍ធូរស្រាលនៅពេលដែលខ្ញុំសួរទៅវិញ ។ ហើយខ្ញុំក៏ត្រូវនិយាយដែលថា បើគាត់ក៏បាន យល់ដូច្នេះដែរ គាត់និយាយអំពីបញ្ហារឿងរ៉ាវគ្រួសាររបស់គាត់ ហើយប្រហែលជា-- អ៊ីចឹងខ្ញុំអាចនឹង និយាយអំពីគ្រួសាររបស់ខ្ញុំផង ដែរ ។ យើងបាននិយាយអំពីអ្វីដែលគាត់ធ្លាប់បង្រៀន គឺគណិតវិទ្យា ។ ហេតុដូច្នេះ ខ្ញុំ ក៏បាននិយាយអំពីអ្វីដែលខ្ញុំនៅកំពុងនឹងធ្វើដែរ ។ ប៉ុន្តែ ចំណុចអស់ទាំងហ្នឹង គឺបាន

បង្កើតនូវស្ថានភាពមួយនៃភាពមិនសាមញ្ញរវាងទំនាក់ទំនងខ្ញុំជាមួយគាត់ ។ ហើយបានពិភាក្សាគ្នាអំពីមុន ជួនកាលចំណុចខ្លះគឺយើងមានមិនភាពដូចគ្នា ហើយបានឆ្លើយតបទៅអ្វីដែលគាត់បានសរសេរទុកនោះ ។ អ៊ីចឹង បញ្ហាអស់ទាំងហ្នឹងបានបង្កើតនូវបរិយាកាសមិនធម្មតាមួយ ដែលបានកកើតឡើង ។ ឧទាហរណ៍ថា តាមបទពិសោធន៍នៅក្នុងជំរំហ្នឹង គឺថាខ្ញុំមានភាពរន្ធត់ដែលខ្ញុំមិនអាចបំភ្លេចបាន ។ គឺត្រូវមើលឃើញនូវមនុស្សម្នាក់ដែលក្នុងចំណោមបរិវាររបស់គាត់ ។ ខ្ញុំគិតថា គាត់ហ្នឹងអ្វីដែលគាត់ធ្វើជាមួយខ្ញុំ គឺថាមិនមែនជាអ្វីដែលបរិវាររបស់គាត់ត្រូវធ្វើនោះទេ គឺថាខ្ញុំអាចឃើញមនុស្សម្នាក់របស់ គាត់នៅពីក្រោយគេញរបស់ពួកគាត់ ពីក្រោយអ្នកជាប់គុករបស់គាត់នៅទីនោះ ។ ហើយ នេះ ជាហេតុផលមួយហើយមើលទៅដែលអាចពន្យល់ថា ឌុច ចាត់ទុកករណីរបស់ខ្ញុំ ហ្នឹងជាករណីពិសេសមួយដែលត្រូវយកចិត្តទុកដាក់ ដែលផ្ទុយគ្នាទៅករណីផ្សេងៗទៀតរបស់អ្នកជាប់គុកនៅទីនោះ ពីព្រោះថា ការសួរចម្លើយនេះដែលថាមានរយៈពេលយូរហ្នឹង អាចបង្កើតបាននូវទំនាក់ទំនងមួយនៃទំនាក់ទំនងជាមនុស្សមួយរវាងគាត់ហើយ និងខ្ញុំ ។

ដូច្នេះហើយ គឺថាការសម្លាប់ខ្ញុំនឹងក្លាយទៅរឿងមួយដែលពិបាកសម្រាប់ឲ្យគាត់ធ្វើ ។ ហើយពិបាកជាងក្នុងការសម្លាប់អ្នកដទៃៗ ដែលអ្នកចាត់ទុកថា គេជាមនុស្សនោះ ។ ខ្ញុំមិនដឹងថា តើខ្ញុំឆ្លើយតបត្រឹមត្រូវទេចំពោះសំណួររបស់លោកស្រី?

[១០:០៣:៥២]

**ស៖** សូមអរគុណ ។ ខ្ញុំនឹងត្រឡប់មកវិញនូវផ្នែកមួយនៃសំណួររបស់ខ្ញុំ ។ តើខ្ញុំត្រឹមត្រូវទេក្នុងការនិយាយថា ពាក្យដែលហៅហ្នឹង គឺមិនមែនជាសំណួរ ឬក៏ត្រឡប់មក សំណួរអំពីគាត់វិញទេ ។ ប៉ុន្តែតើលោកមានបានពិភាក្សាជាមួយគាត់ទេ? ពិភាក្សាអំពី បញ្ហាផ្សេងៗ ឧទាហរណ៍ ដូចជាបញ្ហាព្រះពុទ្ធសាសនា គឺថាមិនមែនជាផ្នែកនៃការសួរ ចម្លើយ ប៉ុន្តែជារបៀបនៃការសន្ទនាគ្នា ការពិភាក្សាគ្នា ការប្តូរយោបល់គ្នានោះ បើមិន មែនជាការសួរចម្លើយនោះ ។

**ឆ៖** ខ្ញុំមិនគិតដូច្នេះទេ ខ្ញុំគិតថាការពិភាក្សាអស់ទាំងហ្នឹង គឺសម្រាប់គោលបំណងមួយដើម្បីបង្ហាញឲ្យបានច្បាស់លាស់បំផុតនោះ ។ គឺដើម្បីបានរុញខ្ញុំទៅចូលម្ខាងដើម្បី ឲ្យខ្ញុំហ្នឹងឯងនិយាយពីអ្វីផ្ទុយពីអ្វីដែលខ្ញុំនិយាយពីមុន ។ ខ្ញុំមិនបានដឹងហើយថាតើភាព រលូនរបស់ខ្ញុំនិងចម្លើយរបស់ខ្ញុំវាត្រឹមត្រូវឬទេ? វាធ្វើឲ្យគាត់ពេញចិត្តដែរឬទេ?

យ៉ាងណាមិញ សម្រាប់គាត់វិញ បើអ្វីមួយចំនួនធ្វើឲ្យគាត់ពេញចិត្ត ដូច្នេះធ្វើឲ្យ គាត់យល់ថា ខ្ញុំមិនមែនជាគេញរបស់*ស៊ីអាយអេ* (CIA) ទេ *សេអ៊ីអា*(CIA)ទេ ។ អ៊ីចឹង នេះគឺអ្វីដែលគាត់បានបង្ហាញទៅថ្នាក់លើរបស់គាត់នៅពេលក្រោយ ហើយខ្ញុំមិនគិតថា មានអ្វីផ្សេងលើកលែងតែថ្ងៃចុងក្រោយនៅពេលដែលខ្ញុំត្រូវបានដោះលែង ដែលដូចជាមានលក្ខណៈស្និទ្ធស្នាល ឬក៏ដោយសេរី ពីព្រោះអីអ្វីៗនៅពេលហ្នឹងស្ថានភាពដូចជា ឋានរកអីចឹង។ ប៉ុន្តែ នៅថ្ងៃចុងក្រោយ គឺយើងអាចនិយាយរបៀបលក្ខណៈទំនងបានរវាង អ្នកជាប់គុក ហើយនិងអ្នកនៅក្តោបក្តាប់ជំរំ ម-១៣ នោះ ។

[១០:០៦:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីក្រុមបី ។ បើមានសំណួរ ។

**សួរដោយលោក ហ្វីលីព កាណុន៖**

**ស៖** ខ្ញុំជាមេធាវីនៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ដែលមានសហសេវិករបស់ ខ្ញុំ គឺកញ្ញា ម៉ុច សុវណ្ណារី ដែលតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីចំនួន២០នាក់ ។ កញ្ញា នឹងសួរសំណួរលោកផងដែរ ប៉ុន្តែខ្ញុំមានសំណួរខ្លីចំនួនបួនដើម្បីសួរ ។ សំណួរទីមួយ គឺខ្ញុំចង់ដឹងថាលោក ប៊ីហ្សូ តើលោកបានដឹងនៅក្នុងអំឡុងពេលការឃុំខ្លួនរបស់ខ្លួន អំពីចំនួនអ្នកដែលត្រូវបានគេសម្លាប់នៅទីនោះ តើមានចំនួនប៉ុន្មានដែរ?

**សាក្សី TC-1៖**

**ឆ៖** ខ្ញុំចាប់អារម្មណ៍ថា ខ្ញុំគិតថាខ្ញុំប៉ាន់ស្មាននៅពេលនោះនៅក្នុងសៀវភៅ ហើយ អ្វីដែលខ្ញុំចាំនៅក្នុងការចងចាំរបស់ខ្ញុំនៅពេលនេះ ការសម្លាប់គឺពិបាកនឹងប្រាប់ណាស់ ពីព្រោះខ្ញុំនៅមានអារម្មណ៍ថា អ្នកដែលគេចាប់ខ្លួនទៅហ្នឹង គឺត្រូវបានគេយកទៅសម្លាប់។ បើសិនជាខ្ញុំនិយាយអំពីតួលេខជាក់លាក់ណាមួយគឺវាប្រហែលជាមិនពិតប្រាកដទេ ឬអាចប្រហែលជាដប់ប្រាំនាក់អាចស្លាប់ដោយសារជំងឺគ្រុនចាញ់។ អ៊ីចឹង ជាអកុសលខ្ញុំមិនអាចបញ្ជាក់ពីចំនួនដែលត្រូវបានគេសម្លាប់នៅក្នុងខណៈដែលខ្ញុំជាប់នៅ ម-១៣នោះ ទេ ។ ប៉ុន្តែ ខ្ញុំគ្រាន់តែមានអារម្មណ៍ថា អ្នកជាប់គុកទាំងអស់ដែលត្រូវបានគេបញ្ជូនទៅទីនោះដែលខ្ញុំបានឃើញ ហើយខ្ញុំគិតថា អ្នកជាប់គុកអស់ទាំងហ្នឹងប្រហែលជាស្លាប់អស់ទៅហើយ ។

**ស៖** ពីម្សិលមិញលោកបាននិយាយថាប្រាប់ពួកយើងថា លោកបានឃើញដោយផ្ទាល់ ដែលបានឃើញនូវចម្លើយសារភាពរបស់សាក្សី និងកិច្ចប្រជុំទិតៀន និងស្វ័យទិតៀនដែលធ្វើឡើងជាប្រចាំ ។

ហើយលោកបានចេះភាសាខ្មែរ និយាយភាសាខ្មែរ តើលោកអាចប្រាប់យើងបានទេថា តើធាតុដើមនៃសេចក្តីសារភាព ឬការប្រជុំទិតៀន ឬស្វ័យទិតៀនហ្នឹងមានអ្វីខ្លះ? និងនិយាយពីអ្វីខ្លះ?

**ឆ៖** ជាសង្ខេបនោះ គឺថាមានការ ជាការលត់ដំការរៀនសូត្រ ការបណ្តុះបណ្តាល នយោបាយដល់អ្នកយាមវ័យក្មេងទាំងនោះ ។ ហើយកម្រិតនៃការពិភាក្សារវាងអ្នកយាមក្មេងៗ និងគ្រូបង្រៀននោះគឺប្រហាក់ប្រហែលគ្នា ។ គឺថាមានអ្នកយាមពីដប់បួនទៅដប់ប្រាំបីឆ្នាំ ហើយអ្នកបង្រៀននោះ គឺថាអាចពិភាក្សាគ្នាបាន ។ ហើយពួកគេបាននិយាយអំពីកំហុសតូចតាចដែលពួកគេបានធ្វើ ដែលធ្វើឱ្យពួកគេអាចធ្វើស្វ័យទិតៀនបាន។ ក្នុងគោលបំណងដើម្បីកែប្រែកំហុសអស់ទាំងនោះ ។ ដូច្នេះ ពួកគេអាចកែប្រែអត្តចរិករបស់ខ្លួនគេបាន ។ ហើយដើម្បីរៀបខ្លួនឱ្យបានត្រឹមត្រូវ ដើម្បីធ្វើការងារបដិវត្តន៍នោះ ។ នេះបានប្រើពាក្យមួយដែលជាពុទ្ធសាសនាផងដែលនៅក្នុងការបង្រៀននោះ ។ គឺជាពាក្យដែលយើងបានប្រើសម្រាប់នៅពេលដែលយើងធ្វើការបន់ស្រន់ ហើយសម្រាប់ការបង្រៀនប្រពៃណីសាសនា ។ អ៊ីចឹងពាក្យអស់ទាំងនោះត្រូវបានគេប្រើរាល់ពេលបណ្តុះបណ្តាល ឬក៏បង្រៀននោះ ហើយឃ្លាដែលខ្មែរក្រហមប្រើពេលនោះ គឺថាបានដកចេញមកពីការបង្រៀនព្រះពុទ្ធសាសនា ឬក៏គម្ពីរសាសនាព្រះពុទ្ធនោះ ។ ហើយបើលោកសង្ឃរិញក៏ត្រូវឱ្យគេធ្វើស្វ័យទិតៀនផងដែរ ជាឧទាហរណ៍ ។ ហើយអ្នកដែលធ្វើបដិវត្តន៍វ័យក្មេងអស់ទាំងហ្នឹងជាឧទាហរណ៍ គឺថាប្រហែលជាពួកគេភ្លេចដើម្បីដូចថាយកខោអាវ ដែលហាលនិងប្រមូលខោអាវទុកវិញ ដោយថាពេលភ្លៀងនៅពេលយប់ហ្នឹង ។ អ៊ីចឹង ពេលនោះខោអាវទទឹកពួកគេភ្លេចសារខោអាវជាដើម ។ ហើយនីមួយៗហ្នឹង គឺគេធ្វើការបន្ទោសខ្លួនឯងចំពោះកិច្ចការតូចទេដែលពួកគេធ្វើកំហុសអស់ទាំងហ្នឹង ។

[១០:១១:៤០]

ហើយអ្វីដែលកើតឡើងជាសំខាន់ទៀតនោះ គឺនៅដំណាក់កាលទីពីនៃការបណ្តុះបណ្តាល ឬការប្រជុំនោះ ដែលអ្នកអង្គុយក្បែរខ្លួននៅអង្គប្រជុំនោះ មានអ្នកយាមវ័យក្មេងម្នាក់បានត្រូវគេហៅឱ្យជួយមិត្តរបស់ខ្លួនឯងលើកអំពីចំណុចដែលគាត់បានភ្លេចឱ្យលើកឡើង ។ ហើយពេលហ្នឹងក៏ចាប់ផ្តើមធ្វើការជជែកគ្នាចុះឡើងៗអំពីបញ្ហាហ្នឹង ។ គំនិតនៃការប្រជុំបែបហ្នឹង គឺការបង្កើតនូវជំហរសីលធម៌បដិវត្តន៍មួយសម្រាប់អ្នកយាមម្នាក់ៗ ឬអ្នកចូលរួមម្នាក់ៗនៅក្នុងវគ្គបែបនេះ ។

**សៈ** ខ្ញុំចង់និយាយពីអ្វីដែលលោកបាននិយាយឡើងវិញ លោក ប៊ីហ្ស អំពីការសួរចម្លើយលើខ្លួនលោកផ្ទាល់ ។ តើពេលហ្នឹងគេមានបានបង្ហាញឯកសារដោយបង្ខំ ឬក៏ក្លែងបន្លំអ្វីផ្សេងទៀត ដើម្បីធ្វើឲ្យលោកមានការភាន់ច្រឡំឲ្យយល់ពីពិរុទ្ធភាពរបស់ខ្លួនលោកនោះ?

**ឆៈ** អត់មានទេ។ មិនមានពេលណាមួយដែលមានរឿងហេតុបែបហ្នឹងកើតើឡើង ចំពោះខ្ញុំទេ ។

[១០:១៣:១៩]

**សៈ** បើអ៊ីចឹង យើងកុំនិយាយអំពីអង្គហេតុហ្នឹងទៀត យើងនិយាយពីចំណុច ផ្សេងម្តង ។ អ៊ីចឹងមានន័យថា ក្នុងករណីជំហររបស់លោកគឺថាលោកអាចឲ្យខ្ញុំសួរពី អារម្មណ៍ផ្ទាល់ខ្លួនលោកបានទេ អំពីអារម្មណ៍របស់ខ្លួនផ្ទាល់ក្រៅពីអង្គហេតុនៅកន្លែងនោះ? អ៊ីចឹង សំណួរចុងក្រោយរបស់ខ្ញុំគឺថា នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេត ឬកាឃុំឃាំងខ្លួនរបស់លោកដោយ ឌុច ពេលហ្នឹងគេឲ្យលោកជួបគាត់ ។ លោកបានស្នើជួបគាត់ ហើយលោកបានយល់ថា ហើយខ្ញុំក៏ឯកភាពដែរថា ខ្ញុំបានទៅជាមួយសហសេវិករបស់ខ្ញុំទាក់ទងទៅនឹងសេចក្តីសម្រេចនេះ ហើយខ្ញុំព្យាយាមយល់នូវភាពស្មុគ ស្មាញរបស់ ឌុច ។ អ៊ីចឹង ខ្ញុំមានសំណួរដែលខ្ញុំចង់សួរ តើវិប្បដិសារីដែលកើតឡើងមាន ទេក្នុងការបង្ហាញនៅពេលហ្នឹង ។ តើលោកបានជឿថា ឌុច មានអារម្មណ៍មានវិប្បដិសារី ដូចគាត់មានអារម្មណ៍ថ្ងៃនេះទេ? នេះគឺសំណួរទីមួយ ឯសំណួរទីពីរនោះគឺថា បាទ នៅពេលមានគេនិយាយថាកុំភ្លេចខ្ញុំណាសមមិត្ត ។ អ៊ីចឹង តើពួកអស់ទាំងហ្នឹង គេនឹង សង្ឃឹមថាចង់បានអ្វីពីលោក? តើលោកគិតថាតើដើមបណ្តឹងរដ្ឋប្បវេណីអាចសង្ឃឹមថា នឹងទទួលបានអ្វីពីសវនាការ ឌុច នេះ?

[១០:១៥:១៩]

**ឆៈ** ខ្ញុំមិនអាចឆ្លើយជំនួសឲ្យ ឡាយ និង សុន បានទេ ។ លើកលែងតែពីរនាក់នេះ គឺខ្ញុំមិនអាចឆ្លើយបានទេ ប៉ុន្តែថាខ្ញុំមិនថាខ្ញុំជាជនរងគ្រោះនោះទេ ។ បើសិនជាខ្ញុំចាត់ទុកថាខ្ញុំមានភាពដូចគ្នានឹងអ្នកដែលនៅរស់រានមានជីវិតនោះ ឬក៏អ្នកដែលបានស្លាប់ទៅនោះ ស្លាប់ដោយសារត្រូវបានគេធ្វើទារុណកម្ម ឬក៏ស្លាប់នៅពេលគេធ្វើទារុណកម្ម។ ខ្ញុំជឿថា បើសិនជាខ្ញុំវិញអ្វីដែលខ្ញុំនឹងត្រូវធ្វើដើម្បីធ្វើឲ្យជ្រះស្រឡះនូវភាពរងគ្រោះនៅក្នុងចិត្តរបស់ខ្ញុំ គឺមានអារម្មណ៍ដូចថាមានភាពស្មើគ្នា ។ គឺថាអាចនឹងមានលទ្ធភាពដើម្បីឲ្យមើលទៅឃើញនូវភាពឈឺចាប់នូវភាពរងគ្រោះនៅខាងក្នុងចិត្ត ដែលមានបន្តរហូតមកដល់បច្ចុប្បន្ននេះ ទៅលើជនជាប់ចោទ ។ ហើយខ្ញុំវិញសម្រាប់ខ្ញុំវិញគិតថា ឲ្យវាចប់ស្រឡះត្រឹមហ្នឹងចុះ ។

ខ្ញុំបានសួរខ្លួនឯងផងដែរ អំពីសំណួរថា តើខ្ញុំមានអារម្មណ៍ធូរស្រាលទេសម្រាប់ជនរងគ្រោះ? មកដល់ពេលហ្នឹង ខ្ញុំមិនដឹងថាតើអាចធ្វើបានឬក៏អត់ ។ ខ្ញុំមិនអាចស្រមៃបានទេទៅដល់រឿងនេះ បើសិនជាអាចធ្វើទៅបាននោះ ខ្ញុំនឹងមានអារម្មណ៍ថា ភាពធូរស្រាលហ្នឹង គឺថាខ្ញុំនឹងអាចមានប្រសិនបើខ្ញុំយល់ថារឿង ហ្នឹងឱ្យវាចប់ស្រឡះត្រឹមនេះចុះ ។ សម្រាប់មនុស្សម្នាក់ដែលទទួលរង ការរងគ្រោះ ឬក៏គេសម្លាប់ ឪពុករបស់ខ្ញុំ ឬកូនរបស់ខ្ញុំគឺថាភាពឈឺចាប់បែបហ្នឹងគឺវាធំទូលំទូលាយណាស់ ហើយប្រហែលជានេះ ហើយជាអ្វីដែលគាត់កំពុងមានអារម្មណ៍នោះ ។

**លោក ហ្វីលីព កាណុន៖**

សូមអរគុណលោក ប៊ីហ្ស បាទ សហសេវិករបស់ខ្ញុំនឹងបន្ត ។

**សួរដោយកញ្ញា ម៉ុច សុវណ្ណារី៖**

**ស៖** ជាដំបូងនាងខ្ញុំសូមគោរពទៅដល់លោកប្រធាន ហើយនិងអង្គជំនុំជម្រះទាំង មូល ហើយសូមជម្រាបសួរទៅដល់សាក្សី លោក ហ្វ្រង់ស្វ័រ ប៊ីហ្ស ។ នាងខ្ញុំមានសំណួរពីរដើម្បីសួរលោក ។ សំណួរទីមួយគឺនាងខ្ញុំសូមត្រឡប់ទៅដល់ហេតុការណ៍មួយដែលលោកបានឆ្លើយនៅចំពោះមុខចៅក្រមស៊ើប នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់លោក ។ គឺនៅពេលដែលគេចាប់លោកភ្លាមមុននឹងទៅដល់មន្ទីរម-១៣ គេបានយកលោកទៅទុកនៅផ្ទះមួយហើយគេបានសួរចម្លើយលោក ហើយនៅពេលនោះ លោកបានឆ្លើយប្រាប់ចៅក្រមស៊ើបអង្កេតថា បន្ទាប់មកគឺមានការបន្លំធ្វើជារៀបចំការសម្លាប់។ អ៊ីចឹង នាងខ្ញុំសូមលោកជួយបញ្ជាក់អំពីហេតុការណ៍ទាំងអស់ហ្នឹង ហើយប្រសិនបើលោកដឹងឬក៏លោកអាចចាំបាន តើលោកដឹងទេថាអ្នកណាជាអ្នកនៅពីក្រោយផែនការនោះ ហើយនៅក្នុងគោលបំណងអ្វីដែលគេធ្វើបែបនេះ?

[១០:១៨:៥៦]

**សាក្សី TC-1៖**

**ឆ៖** បាទ, ខ្ញុំជាអកុសលខ្ញុំមិនដឹងទេ ខ្ញុំមិនអាចផ្តល់នូវចម្លើយជាក់ច្បាស់ចំពោះសំណួរនេះទេ។ ខ្ញុំមិនប្រាកដថាតើកាលនោះ គឺគ្រាន់តែការគ្រាន់តែរៀបគម្រោងធ្វើការសម្លាប់លេងៗនោះទេ ។ ខ្ញុំត្រូវបានអ្នកយាមដែលមានកាន់កាំភ្លើងនាំទៅ ហើយគេចាប់ខ្ញុំឱ្យដាក់ក្នុងពិធីនេះ ឬក៏របៀបនេះ ឬក៏របៀបនោះ ខ្ញុំបានឮគេអាមេកាំភ្លើងហើយខ្ញុំបានឮស្នូរបាញ់ ប៉ុន្តែអត់មានអ្វីបានកើតឡើងទៀតទេ ។ ហើយជាក់ស្តែងបន្ទាប់មកគេបានបើកលើកខ្ញុំឡើង ហើយដាក់ខ្ញុំឱ្យនៅក្នុងស្ថានភាពមួយផ្សេងទៀត

ហើយពេលហ្នឹងគេនៅចងមុខខ្ញុំនៅឡើយទេ ។ គេបានយកខ្ញុំទៅតាមផ្លូវមួយ ប្រហែលជាផ្លូវដែលខ្ញុំធ្លាប់ដើរពីមុន គឺដើរតាមវាលស្រែ ។ អ៊ីចឹងកាលនោះគឺជាការប្រហារជីវិតគ្រាន់តែធ្វើឡើង ឬគ្រាន់តែជាការធ្វើត្រាប់នោះ ឬដើម្បីធ្វើឲ្យខ្ញុំមានការស្ពន់ស្លោ ឬក៏ខ្លាចខ្ញុំមិនដឹងទេ ។

**ស៖** សូមអរគុណ ។ សំណួរទីពីររបស់នាងខ្ញុំហើយក៏ជាសំណួរចុងក្រោយដែរ ។ គឺទាក់ទងទៅនឹងវិធីសាស្ត្រនៃការសួរចម្លើយដែលជនជាប់ចោទបានសួរចម្លើយទៅលើរូបលោក ។ លោកបានដឹងថា គ្រប់អ្នកទោសទាំងអស់ដែលអស់ អ្នកទោសដែលនៅម-១៣ គឺនៅពេលដែលសួរចម្លើយតែងតែទទួលរងនូវការធ្វើទារុណកម្ម ។ ចំណែកករណីរបស់លោកគឺជាករណីពិសេស ហើយលោកត្រូវបានសួរចម្លើយដោយផ្ទាល់អំពីជនជាប់ចោទ ។ មួយទៀត នៅពេលដែលសួរចម្លើយក្នុងរយៈពេលកំឡុងពេលនៃការសួរចម្លើយលោក គឺបានបង្កើតឲ្យមានភាពស្និតស្នាលមួយដែលលោកបានបញ្ជាក់ដល់យើងទាំងអស់គ្នាទាក់ទងទៅជាមួយនឹងទំនាក់ទំនងជិតស្និតមួយរវាងលោកជាមួយនឹងជនជាប់ចោទ ។ ហើយលោកបាននិយាយថា ជនជាប់ចោទបានប្រាប់លោកអំពីប្រវត្តិរបស់គាត់អំពីរឿងរបស់គាត់ ។ ហើយលោកគិតថាវាជារបៀបមួយដែលជនជាប់ចោទចង់ប្រាប់លោកថា នេះជាវិធីដែលលោកអាចផ្ដល់ព័ត៌មានត្រឡប់ទៅគាត់វិញ ។ អ៊ីចឹងនាងខ្ញុំចង់សួរលោកថា តើទាក់ទងទៅនឹងវិធីសាស្ត្រសួរចម្លើយបែបនេះតើលោកគិតយ៉ាងម៉េចដែរ? ហើយលោកមានអារម្មណ៍យល់ថា វាយ៉ាងម៉េចដែរ?

[១០:២១:១៦]

ឆ៖ សូមទោស ខ្ញុំអត់យល់សំណួររបស់កញ្ញាទេ ។ ប្រហែលជាមកពីបញ្ហាបកប្រែក៏អីខ្ញុំអត់យល់ ថាតើកញ្ញាចង់បានចម្លើយប្រភេទណានោះ?

**ស៖** លោកបានដឹងថា អ្នកទោសនៅមន្ទីរម-១១ នៅពេលដែលសួរចម្លើយគឺត្រូវទទួលរងនូវទារុណកម្មនៅម-១៣។ តែនៅក្នុងករណីរបស់លោក គឺពិសេសខុសពីករណីរបស់អ្នកទោសឯទៀតគឺលោកត្រូវបានសួរចម្លើយដោយផ្ទាល់ពី ឌុច ហើយមិនមានការធ្វើទារុណកម្មអ្វីទាំងអស់ ។ ហើយនៅក្នុងអំឡុងពេលនៃការសួរចម្លើយនោះ គឺបង្កើតឲ្យមានទំនាក់ទំនងថាជិតស្និតមួយរវាងលោកជាមួយនឹងជនជាប់ចោទ ឌុច ហើយគាត់បានរៀបរាប់ប្រាប់លោកអំពីជីវិតរបស់គាត់ អំពីរឿងរបស់គាត់ហើយលោកបានឆ្លើយមុននឹងបន្តិចលោកបានប្រាប់ថា ការដែលគាត់ធ្វើបែបនេះប្រហែលជាគាត់គិតថានេះ គឺគាត់ចង់ប្រាប់លោកថា ជារបៀបដែលគាត់ចង់ឲ្យលោករៀបរាប់អំពីរឿងរបស់លោកប្រាប់គាត់របៀបហ្នឹងដែរ ។ អ៊ីចឹងនាងខ្ញុំចង់សួរថា តើទាក់ទងនឹងវិធីសាស្ត្រសួរចម្លើយរបស់ ឌុច បែបនេះ

តើលោកមានអារម្មណ៍យ៉ាងម៉េចដែរ? លោកគិតឃើញយ៉ាងម៉េចដែរ ទស្សនៈផ្ទាល់ខ្លួនរបស់លោក?

**ឆ៖** អ្វីដែលខ្ញុំគិតថា ប្រហែលជាគាត់ព្យាយាមចង់បានចម្លើយពីខ្ញុំ រាល់ប្រភេទសំណួរដែលគាត់ចង់សួរដើម្បីឲ្យគាត់បានផ្គុំចូលគ្នានូវឯកសារមួយទាក់ទងទៅនឹងខ្លួនខ្ញុំផ្ទាល់ ។ ហើយនៅពេលដែលអ្នកជាប់ទោស ជាប់គុកដទៃៗទៀតត្រូវបានគេធ្វើទារុណកម្ម ហើយខ្ញុំមិនបានដឹងទេ ខ្ញុំគ្រាន់តែសង្ស័យដូច្នេះ ខ្ញុំគ្រាន់តែមានស្រមើស្រមៃដូច្នេះ ។ ដើម្បីទទួលយកបាននូវសេចក្ដីសារភាពនោះ ហើយអ្វីដែលគាត់ប្រើជាមួយខ្ញុំគឺវាផ្សេងពីគេ ។ ហើយអ្វីដែលខ្ញុំមានអារម្មណ៍អំពីរឿងនុ៎ង គឺខ្ញុំអត់មានអារម្មណ៍អីទេរឿងហ្នឹង ។ គឺថាខ្ញុំសប្បាយចិត្តណាស់ដែរថានៅចុងបញ្ចប់ហ្នឹង គឺថាសេចក្ដីសរុបទៅខ្ញុំមិនមែនជាគិញសេ.អ៊ី.អា ទេ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តដល់វេទិកាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទីបួន តើមេធាវីក្រុមទីបួនមាន សំណួរអ្វីចង់ត្រូវសួរដល់សាក្សីរូបនេះទេ? បើមានសូមអញ្ជើញ ។

[១០:២៤:៤៥]

**សួរដោយលោក ហុង គីមសួន៖**

**ស៖** សូមអរគុណលោកប្រធាន ។ ជាដំបូង ខ្ញុំសូមគោរពលោកប្រធានអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ជាទីគោរព និង លោក លោកស្រី ចៅក្រមនៅក្នុងអង្គជំនុំជម្រះព្រមទាំងអង្គសវនាការជាទីគោរព ។ ខ្ញុំបាទមេធាវី ហុង គីមសួន ដែលមានសហមេធាវីបរទេសឈ្មោះលោក ព្យែរអូលីវយ៉េ សួ ស្ថិតក្នុងក្រុមទីបួននេះ ។ ហើយក្នុងនេះខ្ញុំបាទមានសំណួរខ្លះៗសួរទាក់ទងទៅនឹង លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ ។ បើលោកស្ដាប់សំណួរខ្ញុំមិនច្បាស់សុំលោកសួរមកវិញដូចលោកមេធាវីមុនទៀតបាទ ។ រយៈពេលនៃការចាប់ខ្លួនលោកនៅឆ្នាំ១៩៧១ មកទល់ពេលនេះវាមានរយៈពេល ៣៨ឆ្នាំ ជាងហើយ អ៊ីចឹង បើប្រៀបធៀបពីមុនមកឥឡូវនេះការចងចាំរបស់លោក គឺលោកបានជម្រាបជូនលោកចៅក្រមច្រើនហើយថា ពេលខ្លះជាការកត់សម្គាល់នៅក្នុងសៀវភៅដែលលោកតាក់តែង អ៊ីចឹង ខ្ញុំសូមសួរលោកភ្ជាប់តែម្ដងថា ក្រៅពីលោក ឌុច ដែលជាប្រធានមន្ទីរម-១៣ ពេលនោះលោកត្រូវបានចាប់ខ្លួនទៅដាក់នៅទីនោះ ។ តើលោកបានស្គាល់ ឬចងចាំថាមានអ្នកដែលមានមុខងារប្រហាក់ប្រហែល លោក ឌុច ប៉ុន្មាននាក់ទៀត? នឹងឈ្មោះអ្វី? សូមលោកឆ្លើយទីមួយ ។

**សាក្សី TC-1៖**

**ឆ៖** ខ្ញុំអត់យល់ទេ ។ សូមលោកបញ្ជាក់ឡើងវិញនូវផ្នែកចុងក្រោយនៃសំណួររបស់លោក ។

**ស៖** ខ្ញុំចង់សួរថានៅម-១៣ ដែលលោកមានប្រសាសន៍មកនោះ គឺមានលោក ឌុច ជាប្រធាន ម-១៣ កន្លែងដែលគេឃុំឃាំងលោកនៅឆ្នាំ១៩៧១ ក្នុងរយៈពេលបីខែនោះណា ។ ក្រៅអំពីលោក ឌុច តើមាននរណាខ្លះទៀតដែលលោកចងចាំបាន ឬលោកស្គាល់ដែលមានមុខងារប្រហាក់ប្រហែលលោក ឌុច ហើយតើមានឈ្មោះអ្វី?

**ឆ៖** អ្នកដែលខ្ញុំចាំ ហើយអ្នកដែលថាមានភារកិច្ចខ្ពស់ដែលនោះ គឺអនុរបស់គាត់ ឬក៏ជំនួយការរបស់ ឌុច គាត់មានអាយុចាស់ជាង ឌុច ។ ខ្ញុំអត់ចាំអំពីឈ្មោះគាត់ទេ ឬក៏ឈ្មោះហៅក្រៅរបស់គាត់ទេ ។ ពេលនោះខ្ញុំចាំ តែឥឡូវខ្ញុំភ្លេចហើយ ។ ហើយខ្ញុំនៅចាំថា អ្នកនោះគឺជាមនុស្សដែលគួរឲ្យភ័យខ្លាចណាស់ ហើយខ្ញុំមិនបានឃើញជនជាប់ចោទមានអនុណាផ្សេងទៀតនៅក្នុងអំឡុងពេលបីខែដែលខ្ញុំត្រូវជាប់ឃុំឃាំងនៅម-១៣ នោះ ។

[១០:២៨:៣២]

**ស៖** សូមអរគុណ ។ ខ្ញុំសុំសួរលោកបន្តទៅទៀត។ ចំពោះពាក្យអម្បាញ់មិញលោកថា ក្រៅអំពីលោក ឌុច មានអនុគាត់ដែលមានចំណាស់ជាង ហើយដែលជាគួរឲ្យភ័យខ្លាច ។ តើពាក្យគួរឲ្យ "ភ័យខ្លាច" មានន័យយ៉ាងម៉េច?

**ឆ៖** គាត់គឺជាមនុស្សឃោរឃៅគួរឲ្យខ្លាច ហើយខ្ញុំមិនមែនជាមនុស្សតែម្នាក់ដែលខ្លាចគាត់នោះទេ ។ បើសិនជាគាត់ជាប្រធានទទួលបន្ទុកនៅជំរំនោះប្រហែលជាខ្ញុំមិនមានជីវិតរស់នៅមកដល់សព្វថ្ងៃនេះទេ ។ សំណាងហើយដែលខ្ញុំមិនស្ថិតនៅក្រោមបញ្ជា របស់គាត់ ។ ប៉ុន្តែ រយៈពេលប៉ុន្មានម៉ោង ដំបូងដែលខ្ញុំចំណាយពេលនៅក្នុងជំរំនុំង គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ ក្រោមវត្តមានរបស់គាត់ ។ ពេលនោះ គឺសម្រាប់ ខ្ញុំមានភាពលំបាកខ្លាំងណាស់ ។ សម្រាប់ហេតុផលហ្នឹងហើយដែលខ្ញុំភ័យខ្លាចគាត់យ៉ាង ខ្លាំង ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់នៅក្នុងអំឡុងពេលនៃការឃុំឃាំងនោះ។ ហើយមិនមែនមានតែខ្ញុំទេដែលមានអារម្មណ៍បែបនេះ សូម្បីតែអ្នកយាមហ្នឹង ក៏មានអារម្មណ៍អ៊ីចឹងដែរ ។ ហើយពួកគេបាននិយាយតិចតួចណាស់អំពីគាត់នោះ ហើយ គឺថាប្រុងប្រយ័ត្នណាស់នៅពេលដែលនិយាយអំពីគាត់ ។ ហើយនៅក្នុងហ្នឹង ខ្ញុំអាចនិយាយថាគ្មាននរណាមួយដែលថាចូលចិត្តគាត់ឬក៏ស្រលាញ់គាត់ទេ ប៉ុន្តែ គឺថានរណាគេក៏ដឹងដែរថា មនុស្សគាត់ហ្នឹងគឺជាមនុស្សកាច

ណាស់ ។

**ស៖** ខ្ញុំសុំសួរលោកបន្តទៅ ចំណុចនេះទៀត ។

កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨ លោកបាន ធ្វើការសម្ភាសជាមួយនឹងសហ ចៅក្រមស៊ើបអង្កេតលោក ម៉ាកសែល ឡឹម៉ុងដ៍ និងលោក យូ ប៊ុនឡេង ទាក់ទង ជាមួយនឹងបុគ្គលិកលក្ខណៈ នៅក្នុងឯកសារ ERN00163083 នៃឯកសារ D៤០ ។ នៅ ក្នុងសំណួររបស់លោកចៅក្រមពេលនោះលោកបានឆ្លើយថា ចំពោះបុគ្គលិកលក្ខណៈ ឌុច ដូចដែលលោកបញ្ជាក់ មនុស្សគួរឲ្យខ្លាចនេះ ដែលមិនដឹងថាអ្វីជាការយល់ច្រឡំនោះទេ គេមានតែគោលការណ៍ និងការជឿជាក់លើខ្លួនឯង ។ ហើយនៅក្នុងទំព័រទីពីរ គឺចុងកន្ទុយ ERN៨៤ ចម្លើយរបស់លោកថា ចំពោះអំណាចពិតប្រាកដរបស់ ឌុច លោកបានសរសេរអំណាចរបស់គេ គឺពេញលេញ អំណាចរបស់រូបគេលើអ្នកទោសគឺ គ្មានព្រំដែន នៅខ្សែភាពយន្តនៅខាងក្រៅទ្វារចូល *ខាត់ប៉ែឌីប៉ក់តែល* លោកសរសេរថា ឌុច ជាមនុស្សគួរឲ្យខ្លាច ។ រូបគេល្បីថា ជាមនុស្សដែលនិយាយអ្វីធ្វើហ្នឹង តើនេះជាអ្វីដែលលោកបានបញ្ជាក់ថា លោក ឌុច ជាអ្នកកាចសាហាវឃោរឃៅ ឬអ្នកដទៃ?

**ឆ៖** ប្រហែលជាខ្ញុំបានិយាយថា ឌុច ហ្នឹងជាមនុស្សឃោរឃៅ ប៉ុន្តែខ្ញុំមិនបានចាំនៅបរិបទដែលខ្ញុំនិយាយអំពីចំណុចនេះទេ ។ ហើយបើសិនជាខ្ញុំនិយាយអំពីខ្លួនខ្ញុំវិញ ឬក៏ពីសក្ខីកម្មរបស់ខ្ញុំនៅពេលនេះ ។ ខ្ញុំមិនអាចនិយាយនៅពេលនេះថា ខ្ញុំហ្នឹងជាអ្នកបានឃើញភាពឃោរឃៅអំពីអ្វីដែលគាត់ធ្វើនោះទេ ប៉ុន្តែបើសិនជាខ្ញុំអាចធ្វើការទស្សន៍-ទាយវិញនោះ ហើយតាមអ្វីដែលខ្ញុំបានដឹង គាត់បានវាយ ឬក៏បានសម្លាប់អ្នកទោស នោះ មានន័យថា គាត់ជាមនុស្សឃោរឃៅ ។ ប៉ុន្តែ ខ្ញុំមិនចាំថា តើខ្ញុំនឹងនិយាយនៅក្នុងបរិបទណាទេដែលថា គាត់ជាមនុស្សឃោរឃៅនោះដែលក៏គាត់គឺជាមនុស្សគួរឲ្យភ័យខ្លាច វាជារឿងមួយផ្សេង ។

[១០:៣៣:៤០]

ខ្ញុំមិនដឹងថាតើគេអាចមើលឃើញគាត់ជាអ្វីផ្សេងក្រៅពីនេះទេ ពីព្រោះគាត់ជាអ្នកទទួលបន្ទុកនៅក្នុងជំរំ ហើយដែលក្នុងជំរំហ្នឹង អ្នកទោសត្រូវបានគេនាំចូល ត្រូវបានគេសួរចម្លើយ ត្រូវបានគេវាយ ហើយត្រូវបានគេសម្លាប់ចោល ។ អ៊ីចឹងគឺថា ពិបាកនឹងថា អ្នកដទៃមានអារម្មណ៍ផ្សេងក្រៅពីនេះទេក្រៅពីនេះណាស់ ។ អរគុណ ។

**ស៖** សុំសួរលោកឡើងវិញថា កាលពីឆ្នាំ១៩៧១ នៅពេលដែលខ្មែរក្រហមចាប់លោកនោះ

តើលោកចេះនិយាយភាសាខ្មែរច្បាស់លាស់ទេ?

**ឆ៖** បាទ ។ ខ្ញុំមិននិយាយភាសាអ្វីផ្សេងក្រៅពីភាសានេះទេ នៅក្នុងអំឡុងពេលនៃការឃុំឃាំងនៅទីនោះ ។

**ស៖** សូមអរគុណ។ លោកបានជម្រាបលោកប្រធាន ក៏ដូចលោកចៅក្រមលោកស្រីចៅក្រមពីម្សិលមិញមកហើយ ទាក់ទងជាមួយនឹងនៅពេលដែលក្នុងការឃុំឃាំងលោកនៅក្នុងមន្ទីរម-១៣នោះ គឺស្តាប់ទៅហាក់ដូចជាលោកមានសេរីភាពជាងគេ រហូតអម្បាញ់មិញ ខ្ញុំបាទឮថា លោកមិនចាត់ទុកថាលោកហ្នឹង ជាជនរងគ្រោះទៅទៀត ។ មិនដឹងជាខ្ញុំស្តាប់ ដោយការបកប្រែច្រឡំ ឬយ៉ាងម៉េចទេ? ប៉ុន្តែខ្ញុំឮថាអ៊ីចឹង ។ ហើយលោកបានជម្រាបថា លោកជាអ្នកសិក្សាស្រាវជ្រាវ ទាក់ទងនឹងអភិរក្សអង្គរជាដើមនោះ ហើយលោករហូតបានធ្វើការបកប្រែសៀវភៅមួយដែលមានប្រហែលជា៣០ទំព័រក្រោយពេលដែលខ្មែរក្រហមដោះលែងលោកមកវិញ ។ លោកបានធ្វើការបកប្រែឯកសារនោះឲ្យស្ថានទូតបារាំងទៀត តើលោកចាំបានទេ ព្រោះម្សិលមិញ ខ្ញុំប្រហែលជាមិនច្បាស់ក្នុងការបកប្រែ ថាតើគោលនយោបាយដែលសរសេរនៅក្នុងឯកសារ ដែលផ្ញើមកនោះទាក់ទងនឹងអ្វីខ្លះ?

[១០:៣៦:២៧]

**ឆ៖** ខ្ញុំបានចេញពីម-១៣ បើដំបូងខ្ញុំដើរដោយជើង បើដោយជិះដំបូងជិះឡាន *ពីហ្សូ* ចាស់មួយក្រោយមកដើរ ហើយក្រោយមកជិះឡានក្រុង ។ ហើយខ្ញុំមានពុកមាត់ ពុកចង្កាវែងៗ ហើយក្រោយមកខ្ញុំបានត្រឡប់ទៅផ្ទះរបស់ខ្ញុំវិញ ជួបជុំគ្រួសាររបស់ខ្ញុំ បានជួបជុំគ្រួសារខ្ញុំវិញ ។ ពេលហ្នឹង គឺមានបរិយាកាសមួយ ដែលសប្បាយក្រៃលែងបំផុត ។ ហើយទាក់ទងនឹងឯកសារដែលខ្ញុំមានហ្នឹង គឺថាធ្វើឲ្យអារម្មណ៍រំជើបរំជួល សេចក្តីបារម្ភរបស់ខ្ញុំតែមួយនៅពេលហ្នឹង បន្ទាប់ពីត្រូវបានដោះលែងនោះ គឺដំបូង គឺការពិតដែលថា សហសេវិកពីរនាក់របស់ខ្ញុំនៅទីនោះនៅឡើយ ហើយខ្ញុំបានចាកចេញពីពួកគាត់ហើយទុកឲ្យពួកគាត់នៅខាងក្រោយ ។ ហើយនេះជាការពិត ដែលនៅតែជាបន្ទុកនៅលើខ្លួនខ្ញុំរហូតមកដល់សព្វថ្ងៃនេះ ។ ហើយទីពីរ គឺឯកសារផ្សេងៗដែលខ្ញុំមាននេះ ដែលអាចនឹងត្រូវបានបានប្រើប្រាស់បាននៅថ្ងៃមួយដើម្បីឲ្យខ្ញុំចាកចេញពីប្រទេសកម្ពុជាដោយរដ្ឋាភិបាល ប្រសិនបើពួកគេបានដឹងអំពីឯកសារដែលខ្ញុំមាននេះ ។ ហើយខ្ញុំអត់ចង់ចាកចេញពីប្រទេសកម្ពុជាទេ ខ្ញុំចង់រស់នៅក្នុងប្រទេសកម្ពុជាជាមួយនឹងគ្រួសារ របស់ខ្ញុំ ហើយបន្តធ្វើការងាររបស់ខ្ញុំទៅមុខទៀត ។ អ៊ីចឹងឯកសារអស់ទាំងហ្នឹងសម្រាប់ខ្ញុំវិញ គឺជាវត្ថុមួយដែលខ្ញុំព្យាយាមបោះបង់វាចោល ហើយពេលនោះខ្ញុំបានហុចឲ្យទៅ

ស្ថានទូតបារាំងភ្លាម ហើយគណៈស្ថានទូតបារាំង បានឲ្យធ្វើការបកប្រែភ្លាមៗ ។ ហើយ ពេលហ្នឹង ខ្ញុំអត់ទុកចិត្តទៅលើអ្នកប្រែជាផ្លូវការនៅក្នុងទូតបារាំងនោះទេ ហើយខ្ញុំបាន រាយការណ៍ទៅមន្ត្រីថ្នាក់លើដែលថា ឯកសារអស់ទាំងហ្នឹងមាន ហើយខ្ញុំបានយកវា ត្រឡប់មកវិញជាមួយខ្ញុំ ។ អ៊ីចឹង ខ្ញុំបានបកប្រែហ្នឹងដោយខ្លួនឯង ពីព្រោះពេលហ្នឹង ខ្ញុំអត់ចង់ឲ្យអ្នកដទៃពាក់ព័ន្ធនឹងឯកសារនោះទេ ឯកសារអស់ទាំងហ្នឹង គឺជាពាក្យថ្មីៗ ច្រើនណាស់នៅក្នុងហ្នឹង ដែលខ្ញុំមានបញ្ហាបំផុត នៅក្នុងការយល់ដឹងអំពីពាក្យពេចន៍ថ្មីៗ អស់ទាំងហ្នឹង ។ ហើយខ្ញុំបានប្រគល់ឯកសារបកប្រែហ្នឹង ទៅឲ្យស្ថានទូតបារាំង ហើយក្រោយមកអត្ថបទហ្នឹង បានបាត់បង់ទៅ ។ សម្រាប់ខ្ញុំវិញ ខ្ញុំគិតថា ឯកសារហ្នឹង ប្រហែលជាមិនត្រូវបានបង្ហាញទៅ បញ្ជូនទៅប្រទេសបារាំងទេ ប៉ុន្តែពេលហ្នឹង លេខា បានឲ្យ-- លេខាទូតនៅពេលហ្នឹងធ្វើសេចក្តីសង្ខេបនៅសេចក្តីបកប្រែរបស់ខ្ញុំ ។ ហើយ សេចក្តីសង្ខេបបកប្រែហ្នឹងហើយ ដែលត្រូវបានបញ្ជូនទៅប្រទេសបារាំងនោះ សេចក្តី សង្ខេបនោះ ពេលហ្នឹងខ្ញុំក៏បានទទួលច្បាប់ចម្លងមួយដែរនៅឯបណ្ណសារ ។ ហើយកាលពីម្សិលមិញ--

*(បញ្ហាបច្ចេកទេសមីក្រូហ្វូន)*

បាទ! អញ្ចឹងឯកសារហ្នឹងគឺ D២៧១៤ ។

[១០:៤០:៤១]

អ៊ីចឹង ខ្ញុំបន្តទៀត ។ ពេលនោះ គឺថាខ្ញុំមានអារម្មណ៍អត់សុខស្រួលសោះ នៅពេលដែលមានឯកសារនោះ អ៊ីចឹង ខ្ញុំអត់ចង់ទុកឯកសារហ្នឹង នៅនឹងខ្លួនជាមួយខ្ញុំទេ ។ ហើយខ្ញុំក៏មិនចង់ទុកនៅក្នុងផ្ទះរបស់ខ្ញុំដែរ ខ្ញុំចង់បើ-- ធ្វើម៉េចឲ្យឯកសារហ្នឹង ចេញពីខ្ញុំទៅ ។ ហើយពេលហ្នឹង ខ្ញុំបានធ្វើការបកប្រែហើយខ្ញុំមានបញ្ហាច្រើនណាស់ក្នុងការបកប្រែហ្នឹង គឺថាខ្ញុំព្យាយាមយ៉ាងអស់សមត្ថភាព ហើយមានសេចក្តីសង្ខេបនៃការបកប្រែនេះទេ ទើបបានបញ្ជូនទៅប្រទេសបារាំង ។ ហើយឯកសារដែលខ្ញុំបកប្រែពិតប្រាកដនោះ គឺមិនមែនមាននៅក្នុងបណ្ណដ្ឋាន របស់ក្រសួងការបរទេសបារាំងនោះទេ ។

ខ្ញុំបានឃើញ សេចក្តីសង្ខេបនៃការបកប្រែរបស់ខ្ញុំហ្នឹង មិនមានអ្វីគួរឲ្យចាប់អារម្មណ៍ ទេ អត់មានអ្វីជាសំខាន់ នៅក្នុងសេចក្តីសង្ខេបនោះទេ ។ អ៊ីចឹង នេះជាអ្វីដែលខ្ញុំនិយាយទាក់ទងទៅនឹងចំណុចនេះ ខ្ញុំមិនមានការចងចាំឲ្យបានច្បាស់លាស់អំពីអត្ថបទដែលមាន ឬក៏ខ្លឹមសារនៅក្នុងអត្ថបទនោះទេ លើកលែងពីអ្វីដែលខ្ញុំបាននិយាយកាលពីម្សិលមិញ។ ខ្ញុំមិនប្រើពាក្យជាក់លាក់ណាមួយទេ នៅពេលនេះ ពីព្រោះពាក្យអស់ហ្នឹង គឺកើតឡើងនៅពេលក្រោយ ដែលខ្ញុំទើបបានដឹង នៅពេលក្រោយៗនេះទេ ។

ប៉ុន្តែ បទពិសោធន៍របស់ខ្ញុំ ពាក្យពេចន៍ប្រើនៅពេលហ្នឹង គឺវាផ្សេងគ្នាពីអ្វីដែលមាននៅពេលនេះ ។ គឺថាឧត្តមគតិហើយនិងការយល់ដឹងនៅពេលនុ៎ងឯង គឺវាធ្វើឡើង បង្កើតឡើងដោយខ្មែរក្រហម ។ ហើយអ៊ីចឹង ខ្ញុំមិនចង់បញ្ជាក់ឲ្យជាក់លាក់ អំពីខ្លឹមសារនៅក្នុងអត្ថបទនោះទេ គឺថាមានតែសេចក្តីសង្ខេបតែប៉ុណ្ណោះដែលខ្ញុំមាន ។

**ស៖** បន្តិចទៀត ទាំងនេះបកមកក្រោយវិញបន្តិចថា ដោយសារនៅក្នុងមន្ទីរម-១៣ នោះលោកបានឆ្លើយជាមួយនឹងលោកសហចៅក្រមស៊ើបអង្កេត ទាក់ទងជាមួយនឹង តាម៉ុក ។ អ៊ីចឹង ប្រហែលជាលោកស្គាល់ឈ្មោះ តាម៉ុក ឬស្គាល់តាម៉ុកផងដែរ ឬមួយលោកសិក្សាក្រោយមកទៀតក៏មិនដឹងទេថាឌុច ខ្លាចតាម៉ុក ។ អ៊ីចឹង លោកដែលជួប តាម៉ុក ទេនៅម-១៣?

[១០:៤៣:០៧]

**ឆ៖** អត់ទេ ខ្ញុំអត់មានបានជួប តាម៉ុក នៅម-១៣ ទេ យ៉ាងណាមិញ ខ្ញុំបានជួបគាត់នៅក្នុងភូមិមួយ នៅតាមផ្លូវទៅម-១៣ នៅក្នុងផ្ទះមួយ ដែលខ្ញុំត្រូវបានគេឃុំគេដាក់ច្រវាក់ខ្ញុំ ប្រហែលជាពីរម៉ោងនោះ គឺនៅពេលដែលខ្ញុំ គេឃុំខ្លួន មុនពេលដែលខ្ញុំត្រូវបានគេបញ្ជូនទៅម-១៣នោះ ។ គឺមានភូមិចាស់មួយ ពេលនោះគាត់បាននិយាយធម្មតា ជាមួយខ្ញុំ ហើយគាត់បានប្រាប់ខ្ញុំថា ជនជាតិខ្មែរ ដែលជាអ្នកទទួលបន្ទុកខុសត្រូវនេះ ដែលខ្ញុំទើបឃើញ ដែលគាត់ទើបចេញពីផ្ទះនោះ ។ ហើយក្រោយមកគេបានចងខ្ញុំទៅបង្គោលក្នុងផ្ទះមួយនោះ ។ អ៊ីចឹង គឺថាឈ្មោះហ្នឹង នៅជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំ ការចងចាំរបស់ខ្ញុំ ហើយក្រោយមកទៀត ខ្ញុំមិនដឹងថា នៅពេលណាទៀតទេ ។ ហើយឌុច ក៏មិនដែលនិយាយឈ្មោះ តាម៉ុក ជាមួយខ្ញុំដែរ ឬមួយក៏គាត់និយាយ ប៉ុន្តែខ្ញុំអត់ចាំ ។ បាទ, អស់ប៉ុណ្ណឹងហើយ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ដល់ម៉ោងដប់មួយដប់ប្រាំនាទីចូលវិញ ។ ហើយលោកហុង គីមសួន បើមានសំណួរអ្វីត្រូវសួរទៀតចាំចូលមកវិញ ដោយហេតុក្រុមនេះគឺមានបញ្ហាខាងហ្វីលដែលត្រូវអស់ផង ។

ហើយមន្ត្រីតុលាការ សូមអញ្ជើញសាក្សីទៅកាន់បន្ទប់រង់ចាំ ហើយសូមអញ្ជើញគាត់ត្រឡប់មកវិញ នៅពេលម៉ោងដប់មួយប្រាំនាទី ដើមបន្តផ្តល់សក្ខីកម្មបញ្ចប់ព្រឹកនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញ ក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:៤៥នាទី ដល់ម៉ោង ១១:១០នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ!

**ប្រធានអង្គជំនុំ៖**

អង្គជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការដេញដោល លើសាក្សី ហ្វ្រង់ស្វ័រ ប៊ីហ្សូ តទៅទៀត ។ ហើយមុននឹងបន្តកិច្ចដំណើរការ ខ្ញុំសូមជម្រាបភាគីដែលពាក់ព័ន្ធ ដែលមានសិទ្ធិក្នុងការតាំងសំណួរ ដល់សាក្សីក្តី ដល់ជនជាប់ចោទក្តី ដល់ដើមបណ្តឹងរដ្ឋប្បវេណីក្តី ដល់អ្នកជំនាញក្តី ។

ទីមួយ សូមរំឭកឡើងវិញថា ជៀសវាងនូវការតាំងសំណួរច្រំដែល ក្នុងករណីដែលមានការតគ្នាផ្លាស់ប្តូរវេនក្នុងចូលរួមក្នុងសវនាការ ត្រូវទទួលព័ត៌មានពីអ្នកមុនឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការតាំងសំណួរច្រំដែល ។

ទីពីរ សូមរំឭកឡើងវិញថា កុំតាំងសំណួរឯណាដែលមិនពាក់ព័ន្ធនឹងអង្គហេតុ ឬក៏ពាក់ព័ន្ធតិចតួច បំផុត ដើម្បីដំណើរប្រព្រឹត្តទៅឲ្យច្បាស់ ឲ្យបានចំ ។ ហើយមួយទៀត យើងកត់សម្គាល់ឃើញថា សំណួរមួយចំនួនមិនបានព្រៀងទុកទេ ។ សំណួរនិយាយយ៉ាងច្រើន៥មីនុតទៅ១០មីនុតទៅបានដល់សំណួរជាក់លាក់ ។ អ៊ីចឹងសូមរៀបចំសំណួរ ឲ្យបានច្បាស់លាស់ ដើម្បីដល់សាក្សី ឬក៏ជនជាប់ចោទ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកក្រោយទៅ-- អ្នកជំនាញ គាត់ងាយយល់សំណួរ ហើយអាចឆ្លើយតប និងសំណួរនោះបានត្រឹមត្រូវ ។

លោក ហុង គឹមសួន មានសំណួរអ្វីទៀតទេ ឬក៏អស់ហើយ? សូមលោកបញ្ជាក់សំណួរណា គឺឲ្យចំបញ្ហាហើយខ្លី ដើម្បីឲ្យមុខសញ្ញាដែលត្រូវឆ្លើយហ្នឹង គាត់អាចក្តាប់នឹងសំណួរលោកបាន ហើយអាចឆ្លើយបានដោយស្រួលទីមួយ ។ ទីពីរ ការដែលគាត់ឆ្លើយ គឺតាមលទ្ធភាព ពីព្រោះហេតុវាមាន៣៨ឆ្នាំ ប្រហែលជាអស់លោក លោកស្រីទាំងអស់ក៏ប្រហែលជាមិនចងចាំបាននូវអ្វីដែលកើតឡើង៣០,៤០ឆ្នាំកន្លងមកហើយនោះដែរ គ្រាន់តែកម្រិតមួយដែលទទួលព័ត៌មាន ដើម្បីបុព្វបន្តទៅអង្គហេតុដែលយើងនឹងធ្វើសវនាការនាពេលខាងមុខ ។

[១១:១៣:២៥]

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** សូមអរគុណលោកប្រធាន ។ ខ្ញុំបាទក៏សូមអរគុណផងដែរ ដែលលោកប្រធានបានដាស់តឿនដល់យើងខ្ញុំ ព្រោះយើងខ្ញុំបានជម្រាបហើយថា ជួនកាលការស្តាប់ការបកប្រែមិនស៊ីចង្វាក់គ្នា ។

អ៊ីចឹងខ្ញុំបាទសួរសំណួរបីទៀតទៅលោក ហ្រ្វង់ស្វ័រ ប៊ីហ្សូ ។ លើកនេះដោយសារអម្បាញ់មិញ គឺមុនសម្រាកគាត់បាននិយាយថា ស្គាល់ ឬក៏ដឹងឈ្មោះ តាម៉ុក នោះនៅពេលចាប់ខ្លួន ឃុំគាត់ហ្នឹងនៅផ្ទះប្រហែលពីរម៉ោង ។ ខ្ញុំសូមសួរទៅលោក ហ្រ្វង់ស្វ័រ ប៊ីហ្សូ ទៀតថា ក្រៅពីឈ្មោះ តាម៉ុក ដែលលោកបានលើកឡើងនៅក្នុងមុននេះបន្តិចទាក់ទងនឹងសាក្សី ដែលត្រូវបានប្រើជាសម្ងាត់ តែគាត់និយាយចំឈ្មោះ តើខ្ញុំបាទគួរយកឈ្មោះដដែលមកនិយាយវិញ ឬក៏ប្រើពាក្យសម្ងាត់ អ៊ីចឹងខ្ញុំបាទគិតថា ខ្ញុំមិនចាំបាច់ទេ ព្រោះគាត់និយាយហើយថា តើក្រៅពីអ្នកដែលលោកសន្និដ្ឋានថា មនុស្សដែលមានរាងខ្ពស់រាងសនោះ ជាសមាជិកក្នុងកម្រិតលោក ឌុច ដែរទេនៅក្នុងម-១៣?

**សាក្សី TC-1៖**

**ឆ៖** ប្រសិនបើខ្ញុំយល់សំណួររបស់លោកត្រឹមត្រូវនោះ លោកបានសួរខ្ញុំអំពីបុគ្គល មួយរូប ។ ខ្ញុំលើកឡើងជាក់លាក់ចំពោះថា បុគ្គលនោះថា បុគ្គលនោះមិនមែនជាអនុប្រធានរបស់ជនជាប់ចោទនោះទេ ។ ហើយខ្ញុំលើកឡើងទៅបុគ្គលហ្នឹង ប៉ុន្តែ គឺរូបរាងរបស់បុគ្គលនោះ គឺវាឆ្លើយតបនៅក្នុងករណីហ្នឹង ប៉ុន្តែខ្ញុំគិតថា មានតែជនជាប់ចោទ គឺគាត់អាចឆ្លើយសំណួរហ្នឹង ច្បាស់លាស់ ខ្ញុំមិនអាចនិយាយអ្វីក្រៅពីហ្នឹងទេ ។

**ស៖** សូមអរគុណ ។ ឥឡូវនេះសំណួរទីពីរ ទាក់ទងជាមួយនឹងសហការីរបស់លោក ដែលឈ្មោះ សុន មួយ ឈ្មោះ ឡាយ មួយ ។ លោកថា លោក ឌុច សម្រេចថានឹងដោះលែងនៅពេលដែលគេដោះលែងលោក តែមិនបានដោះលែងដំណាលលោកទេ ។ តើលោកបានដឹងថា តើសហការីលោកឈ្មោះ សុន និង ឡាយ នោះត្រូវបានសម្លាប់ ឬក៏ត្រូវបានដោះលែងដែរទេ រយៈពេលដែលក្រោយពីដោះលែងលោកមក?

**ឆ៖** វាពិបាកចំពោះខ្ញុំក្នុងការឆ្លើយសំណួរនេះឲ្យបានជាក់លាក់ ។ ពួកគេត្រូវបានដោះច្រវាក់នៅពេលជាមួយខ្ញុំដែរ ខ្ញុំគិតថា ខ្ញុំបានឆ្លើយតបសំណួរហើយនៅពេលដែលខ្ញុំបានលើកឡើងថា ពួកគេត្រូវនឹងទទួលបានសេរីភាព និងទទួលបានសេរីភាពនៅក្នុងតំបន់រំដោះ ។ ទទួលបានសេរីភាពក្នុងតំបន់រំដោះហើយនេះ គឺជាករណីនេះ ។ ហើយខ្ញុំមិនដឹងច្បាស់លាស់ទេ ហើយប៉ុន្តែ ពួកគេត្រូវបានគេសម្លាប់ចោល

បន្តិចក្រោយមក ប្រហែលជាមួយឆ្នាំក្រោយមក ឬក៏មិនច្រើនជាងហ្នឹងទេ ប៉ុន្តែខ្ញុំមិនអាចបញ្ជាក់ថា តើពួកគេត្រូវបានគេដាក់ច្រវាក់ ដាក់ខ្នោះ ឬក៏ដាក់ មិនដាក់ ខ្ញុំអត់អាចបញ្ជាក់ទេ នេះគឺជាអ្វីដែលលោកបានសួរខ្ញុំទៅសំណួរហ្នឹង ។

[១១:១៧:៤៣]

**ស៖** សូមអរគុណ ។ តើក្រោយពេលដោះលែងលោកពីម-១៣ លោកនៅមានទំនាក់ទំនងទៅជាមួយលោក ឌុច ទៀតដែរឬទេ?

**ឆ៖** អត់ទេ ។ មូលហេតុសាមញ្ញ ខ្ញុំគិតថា គាត់បានស្លាប់ទៅហើយ ដូចអ្នកបដិវត្តន៍ ផ្សេងទៀតដែលថាត្រូវបានគេចាប់ខ្លួន ។ ខ្ញុំបានដឹង ហើយខ្ញុំបានគិតដឹងថា គាត់បានរស់ នៅរស់ ហើយគាត់ត្រូវបានឃុំខ្លួន ហើយគាត់នៅឋិតនៅក្នុងគុកឃោធា ដែលគាត់ត្រូវបានគេឃុំខ្លួន ។

**ស៖** អរគុណ ជាសំណួរចុងក្រោយ ។ លោកបានថ្លែងការណ៍ជូនលោកសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃ២២ មករា ២០០៨ នេះ នៅក្នុងទំព័រលេខ៦ នៃឯកសារ D៤០ លោកបានថ្លែងថា ប៉ុន្តែក្រោយមកបទបញ្ជាមកថ្នាក់លើថាឲ្យសម្លាប់ពួកគេ ពួកគេនេះ ខ្ញុំចង់និយាយ ឡាយ និង សុន ប្រហែលជាមួយឆ្នាំ ឬពីរឆ្នាំក្រោយមក ។ អ៊ីចឹងបើលោកគ្មានទំនងជាមួយលោក ឌុច ទេ លោកបានដឹងអំពីការស្លាប់ របស់អ្នកទាំងពីរដូចម្តេច? សូមអរគុណ ។

**ឆ៖** ដោយសារតែ ឌុច គាត់បានលាតត្រដាងបញ្ហានេះជូនខ្ញុំ ដូច្នេះហើយខ្ញុំអាចដឹងនៅពេលខ្ញុំទៅ ជួបគាត់នៅគុកឃោធា ហើយគាត់បានប្រាប់ខ្ញុំទៅលើបញ្ហាហ្នឹង ។

**លោក ហុង គឹមសួន៖**

អស់សំណួរហើយ សូមអរគុណបាទ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត សូមជូនវេទិកានេះទៅ មេធាវីការពារជនជាប់ចោទ ដើម្បីមានឱកាសក្នុងការសួរសំណួរដល់សាក្សី ហ្វ្រង់ស្វ័រ ប៊ីហ្សូ ។ បើសិនមានសូមអញ្ជើញ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

**ស៖** អរគុណលោកប្រធាន។ លោក ប៊ីហ្សូ ចំណុចជាច្រើនបានលើកឡើង ហើយខ្ញុំមិនសំណួរសាកសួរលោកច្រើនទេ ប៉ុន្តែ ខ្ញុំមានសំណួរជាក់លាក់ពាក់ព័ន្ធទៅនឹងអនុរបស់ ឌុច ។ ប្រសិនបើខ្ញុំផ្តល់ឈ្មោះ ហូ គឹមអៀង ហៅ ស៊ុំ ថាតើគាត់គឺជាអនុប្រធាន ឬយ៉ាងម៉េច?

[១១:២០:៤៣]

**សាក្សី TC-1៖**

**ឆ៖ ហូ គឹមអៀង** គឺអត់មានន័យអីចំពោះខ្ញុំ ។ ខ្ញុំមិនអាចនិយាយបានទេ ។

**ស៖** ដូច្នេះខ្ញុំសួរលោក នៅសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងយោបល់របស់លោក នៅក្នុងចម្លើយកាលពីមុន ដែលលោកបានលើកឡើង ជាពិសេសនៅចំពោះមុខចៅក្រម ស៊ើបអង្កេត ដែលគាត់បានសួរយកចម្លើយរបស់លោកទាក់ទងទៅនឹងសៀវភៅរបស់លោក ។ ដូច្នេះ ខ្ញុំសូមឲ្យលោកផ្តល់យោបល់ទៅលើបញ្ហានេះ ។ នៅក្នុងសៀវភៅរបស់លោក នៅក្នុងទំព័រ១១៥-១១៦ ក្នុងឯកសារបារាំងលោកបានលើកឡើងថា ឌុច គឺគាត់អនុវត្តសេចក្តីសម្រេចរបស់អង្គការ ហើយនៅក្នុងវិធីដូចគ្នាដែរ សហចៅក្រមស៊ើបអង្កេត គាត់សុំឲ្យលោកបញ្ជាក់ទៅលើចំណុចនេះ ។ ហើយលោកបានបញ្ជាក់នៅក្នុងចំណុច ២៤០ គឺថាចំណុចនេះវាថ្មីហើយជនជាប់ចោទ គឺគ្មានអ្វីក្រៅពីការសួរចម្លើយពីបុគ្គលដែល ត្រូវបានគេចាប់ខ្លួនហើយពាក់ព័ន្ធនឹងគាត់ គឺគាត់សរសេររបាយការណ៍ ។ បុគ្គលទាំងអស់នោះត្រូវបានគេចោទទោសតាំងពីចាប់ផ្តើម ។ ចំណុចសំខាន់គឺថាឲ្យពួកគាត់និយាយ មុនពេលយកទៅសម្លាប់ចោល ដើម្បីបញ្ជាក់អំពីការចាប់ខ្លួនរបស់គេថា ត្រឹមត្រូវ ។

ដូច្នេះហើយថា ខ្ញុំចង់សួរលោក លោកចង់មានចំណុចណាមួយចង់បន្ថែមទៅលើចំណុចនេះដែរឬទេ? ជាថ្មីម្តងទៀតនៅក្នុងចំណុចចុងក្រោយ នៅក្នុងចម្លើយរបស់លោក នៅចៅក្រមស៊ើបអង្កេតគឺលោកមានការសង្កេតសន្និដ្ឋានមួយចំនួន ។ ហើយខ្ញុំនិយាយថា របបខ្មែរក្រហម គឺរបបដ៏សាហាវ គួរឲ្យភ័យខ្លាច ហើយវាពិបាកចំពោះបុគ្គលទាំងឡាយដែលគាត់មានតួនាទីនៅក្នុងរបបនោះ ដើម្បីដកខ្លួនថយចេញពីរបបនេះ ។ ថាតើលោកមានយោបល់ណាមួយចង់លើកឡើងទាក់ទងចំណុចនេះដែរឬទេ?

**ឆ៖** ខ្ញុំអត់មានចំណុចចង់លើកឡើងបញ្ជាក់ទៅលើអ្វី ដែលខ្ញុំបានលើកឡើងនៅពេលនោះទេ ។ ក្នុងពេលការសួរយកចម្លើយ នៅចំពោះសហចៅក្រមស៊ើបអង្កេត ខ្ញុំជឿថា ខ្ញុំមិនចំបានបង្ហាញអំពីរបបខ្មែរក្រហមទេ គឺជារបបមួយមានការភ័យខ្លាច ហើយចំពោះខ្លួនខ្ញុំ ហើយចំពោះការដោះលែងខ្ញុំ ។ ខ្ញុំមិនដែលឃើញ ខ្ញុំមិនដែលយល់ឃើញថា សេចក្តីសម្រេចនោះ គឺសម្រេចដោយ ឌុច ទេ គឺត្រូវបានសម្រេចដោយថ្នាក់លើ ។

[១១:២៥:០០]

**ស៖** អរគុណ។ ដូច្នេះ យើងបន្តសំណួរយើងទៅទៀតទាក់ទងទៅនឹងការភ័យខ្លាច សំណួរ

ទាក់ទងទៅនឹងការភ័យខ្លាច ។ លោកបាននិយាយជាក់លាក់អំពី ឌុច ខ្លួនឯង នៅក្នុងសៀវភៅរបស់លោក ហើយក៏និយាយនៅមុខសហចៅក្រមស៊ើបអង្កេតផងដែរ។ លោកបាននិយាយនៅពេលនោះថា ខ្ញុំសូមទៅដល់គោលគំនិតដែលថាជនជាប់ចោទ គាត់ស្ថិតនៅក្នុងយន្តការរបបនោះ ។ ហើយគឺលោកសរសេរនៅក្នុងសៀវភៅរបស់លោកក្នុងទំព័រ១៨៦ គឺមានការភ័យខ្លាចនៅក្នុងខ្លួនគាត់ ហើយនៅកន្លែងផ្សេងទៀត ។ ហើយ គឺក៏ត្រូវតែធ្វើការនៅក្នុងជួរខ្មែរយោធា ហើយគឺវាត្រូវអនុវត្តនៅកន្លែងផ្សេងៗទៀត ។ ហើយនៅក្នុងសៀវភៅដែលលើកឡើងដោយចៅក្រម ឡាវែន៍ គឺទំព័រ១៨៥ គឺខ្ញុំសូមចូលទៅដល់ទំព័រហ្នឹងម្តងទៀត ។ លោកបានសរសេរថា អ្វីដែលលោកពេញចិត្តគាត់ គឺភាពស្លូតត្រង់ និងចិត្តល្អរបស់គាត់ ហើយវាទាក់ទងទៅនឹងការឈឺចាប់ផ្សេងៗជាហូរហែ ។ ហើយវាបានកំណត់ទៅលើលក្ខណៈរបស់គាត់ លោកនិយាយអំពីការភ័យខ្លាច លោកនិយាយអំពីការឈឺជាហូរហែ ។ លោកនិយាយអំពីបញ្ហានេះម្តងទៀត នៅពេលដែលលោកបានឆ្លើយជាមួយនឹងចៅក្រមស៊ើបអង្កេត នៅក្នុងទំព័រទី៥ នៃឯកសារD៤០ ។ ហើយលោកបាននិយាយថា លោកចង់បញ្ជាក់ថាប្រសិនបើអ្នកយាម គឺមានការភ័យខ្លាច ហើយស្ថិតនៅក្រោមការភ័យខ្លាចនោះ គឺឌុច ក៏ជាមនុស្សស្ថិតក្រោមការភ័យខ្លាចផងដែរ ។ ហើយនៅក្នុងចំណុចនេះខ្ញុំជឿថា ការអះអាងរបស់គាត់ជាមួយនឹង តាម៉ុក នោះគឺវាកើតឡើងដេញ-- នៅតាមគាត់ជារៀង-- រយៈពេលប៉ុន្មានឆ្នាំ?

ដូច្នេះហើយ គឺជាអ្វីដែលលោកបានបញ្ជាក់ទៅលើចំណុចទាំងអស់នេះ ។ ខ្ញុំសូម ឲ្យលោកលើកឡើងបញ្ជាក់អំពីការឈឺចាប់និងការភ័យខ្លាច ដែលលោកបានលើកឡើង ថា លោកបានឃើញ?

**ស៖** ខ្ញុំមិនអាចព្យាយាមចងចាំ ដើម្បីរំឭកទៅលើរូបភាពផ្សេងៗដែលវានៅចំពោះមុខខ្ញុំនៅពេលដែលខ្ញុំព្យាយាមចងចាំម-១៣ ។ បរិយាកាសទាំងអស់នោះ គឺបរិយាកាស គួរឲ្យភ័យខ្លាច ហើយវាជាបរិយាយកាសដែលនាំឲ្យយើងមានការភ័យខ្លាចអំពីការស្លាប់។ ហើយខ្ញុំមិនអាចធ្វើដូច្នេះក្នុងការរំឭកឡើងអំពីបរិយាកាសភ័យខ្លាចដែលវាកើតឡើងទៅលើជនជាប់ចោទ ។ ការភ័យខ្លាច គឺវានៅអន្ទោលគ្រប់កន្លែង ហើយនៅគ្រប់បុគ្គលទាំងអស់ ហើយវាមិនងាយអាចធ្វើការប្រមើលមើល ថាវាមានអ្វីក្រៅពីនោះទេ ។ ហើយនៅពេលដែល ឌុច គាត់ប្រជុំហើយត្រឡប់មកវិញ មុខរបស់គាត់ ឬការបង្ហាញរបស់គាត់ គឺបង្ហាញច្បាស់អំពីការឈឺចាប់ ដែលខ្ញុំមិនអាចផ្តាច់ចេញពីបរិបទដែលគាត់លើកឡើងអំពីមេរបស់គាត់នៅក្នុងកិច្ចប្រជុំនោះ ។

ខ្ញុំយល់យ៉ាងច្បាស់ថា វាជាបញ្ហាចោទទៅលើការសម្រេច នៅពេល-- ទៅលើការផែនការ

ឬកម្មវិធីនៃការសម្លាប់ ។ ហើយ គ្មានពេលណាមួយដែលវាទាក់ទងទៅនឹងបញ្ហាអាយុជីវិត ។

ដូច្នេះហើយ អវត្តមានជាហូរហែនៃការសម្លាប់ ការសម្លាប់ជាហូរហែ និងការធ្វើទារុណកម្មទាំងអស់នោះ វាមិនអាចមានផលប៉ះពាល់ ហើយដែលយើងមិនអាចមិនថា មិនមើលឃើញនៅក្នុងការបង្ហាញរបស់គាត់នោះទេ ។

[១១:៣០:៣៤]

**ស៖** អរគុណ ។ ឥឡូវនេះខ្ញុំសូមចូលទៅដល់ការដោះលែងលោក ហើយនិងការគ្រោះថ្នាក់ដែលឌុច បានធ្វើឡើងដើម្បីដោះលែងលោក ។ នៅក្នុងឯកសារទំព័រ១៤០ នៃឯកសារបារាំង លោកក៏បានលើកចំណុចនេះទៅសហចៅក្រមស៊ើបអង្កេតផងដែរ ។ ខ្ញុំក៏សូមលើកឡើងចំពោះដំណាកស្រង់មួយនេះ ខ្ញុំមិនដឹងថា តើគាត់ជឿអំពីការស្មោះត្រង់របស់លោក ឬក៏ភាពមិនដឹង ភាពមិនមានទោសរបស់លោកយ៉ាងម៉េច? ក្នុងនាមនៃគោលការណ៍បដិវត្តន៍ ដែលគាត់មានការប្តេជ្ញាក្នុងការបង្ហាញអំពីកាលដែលគាត់ចង់ភ្ជាប់ជាមួយនឹងភាពយុត្តិធម៌ ។ ខ្ញុំយល់អំពីគ្រោះថ្នាក់ដែលគាត់បានប្រថុយ ហើយគាត់លេងល្បែងជាមួយនឹងការដោះលែងរបស់ខ្ញុំ ។ ហើយការអាណិតអាសូរដែលគាត់មានចំពោះខ្ញុំ គឺការអាណិតអាសូរអំពីភាពត្រឹមត្រូវ ដែលវាស្រដៀងទៅនឹងករណីដែលថា ឌុច គឺជាអ្នកដែលមានគំនិតល្អ ដែលគាត់ព្យាយាមស្វែងរកការពិតទៅលើគ្រប់ករណី ទាំងអស់ ។ ហើយលោកបកប្រែសាជាថ្មីនៅក្នុងស្ថានស្មារតីរបស់លោក នៅក្នុងកិច្ចសន្ទនា ដែលលោកបានលើកឡើង ក្នុងពេលដែលលោកត្រូវបានគេដោះលែង ។ គាត់បានសួរលោក ថាតើលោកប្រាកដហើយ ឬយ៉ាងម៉េច? ហើយខ្ញុំបានបញ្ជាក់ថា ជាការពិត ហើយគឺវាមាននៅក្នុងទំព័រ២២៦ ។ ហើយជាការពិតលោកកម្មាភិបាល ខ្ញុំជំពាក់គុណលោកទៅលើបញ្ហានេះ ។ ហើយខ្ញុំបានមានការយល់ព្រមជាមួយនឹងការដឹង-- ស្មារតីដឹងឮរបស់ខ្ញុំ ។ ហើយខ្ញុំធ្វើឡើងដោយភាពប្រាកដប្រជាទៅបញ្ហានោះ ហើយគាត់សួរថា ខ្ញុំគ្រាន់តែផ្តល់យោបល់ដើម្បីទាមទារយកលទ្ធផលចុងក្រោយទៅលើករណីនេះ ។

អ្វីដែលលោកបានបកប្រែនៅទីនេះ លោក ប៊ីហ្សូ ថាតើចំណុចទាំងអស់នេះ វាឆ្លើយតបទៅនឹងអ្វីដែលលោកបានឆ្លងកាត់នៅពេលនោះដែរឬទេ? តើលោកអាចបញ្ជាក់ ទៅលើអត្ថបទនោះដែរ ឬទេ? ថាវាផ្ទុះបញ្ចាំងពីអ្វីដែលលោកបានបឆ្លងកាត់នៅពេលនេះ? លោក ប៊ីហ្សូ?

[១១:៣៤:០៥]

**ផ៖** គឺខ្ញុំ គឺមិនមែនជាអារម្មណ៍របស់ខ្ញុំទេ គឺខ្ញុំចង់ចាំទៅលើបញ្ហាហ្នឹង ដែលថាគាត់មានការភ័យ

ខ្លាចយ៉ាងខ្លាំង ហើយមានការភ័យខ្លាចមានការវាយធ្នាក់ ។ វិធីដែលខ្ញុំត្រូវបានគេដោះលែង គឺខ្ញុំត្រូវបានគេដាក់នៅអមលាំង គឺវាមានឡាន *ពុយហ្សូ* រង់ចាំខ្ញុំ ដើម្បីដឹកខ្ញុំទៅកន្លែងផ្សេង ដឹកខ្ញុំចេញទៅ ។ ឌុចគឺមានការព្រួយបារម្ភ ហើយគឺគាត់មានការភ័យខ្លាចអំពីការវាយធ្នាក់ពីមេរបស់គាត់ ។ គឺជាការពិតគេមិនមានការគាំទ្រចំពោះការដោះលែងខ្ញុំទេ ។ ខ្ញុំបានចាំច្បាស់ណាស់ថា គឺគាត់មិនបានគាំទ្រចំពោះការដោះលែងខ្ញុំនោះទេ ។

ដូច្នេះហើយ បញ្ហានេះមិនទាន់បង្ហាញថ្នាក់របស់គាត់នោះទេ គឺមិនមានការគាំទ្រទៅលើបញ្ហានោះឡើយ ។

**ស៖** លោក ប៊ីហ្សូ នៅពេលលោកឆ្លើយតបទៅលើបញ្ហាចោទ ពាក់ព័ន្ធមួយចំនួនរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ជាពិសេសនៅក្នុងសំណួរចុងក្រោយដែលបានលើកឡើងដោយលោក កាណុន ។ លោកលើកអំពីការបង្ហាញអំពីការអាណិតអាសូរ ក្នុងលក្ខណៈមនុស្សធម៌ដល់ជនរងគ្រោះ ។ ហើយនៅក្នុងការដេញដោលនេះ គឺលោកបានអំពីនិយាយ លោកបាននិយាយអំពីអារម្មណ៍មនុស្សធម៌របស់ ឌុច ។

ដោយក្នុងនាមជាមេធាវីការពារក្ដី ខ្ញុំសូមអរគុណ ចំពោះការចូលចំណែកដែលបានផ្ដល់នៅទីនេះដើម្បីការងារក្នុងការស្វែងរកយុត្តិធម៌ ។ ខ្ញុំសូមអរគុណច្រើនចំពោះករណីនេះ ។

[១១:៣៧:១០]

**ប្រធានអង្គជំនុំ៖**

លោកអត់មានទេ?

អរគុណ លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ ដែលអញ្ជើញបានមកធ្វើសក្ខីកម្ម តាមការកោះហៅរបស់អង្គជំនុំជម្រះ ។ ឥឡូវនេះ អង្គជំនុំជម្រះអស់សំណួរត្រូវសួរដល់លោកទៀតហើយ ។ អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកអាចទៅអង្គុយនៅកន្លែងសម្រាប់សាធារណជនបាន ឬក៏លោកចាកចេញពីសវនាការ និងធ្វើដំណើរទៅទីកន្លែង ឬគោលដៅណាដែលលោកចង់ទៅបានហើយ ។ ហើយបង្គាប់ឲ្យមន្ត្រីតុលាការរៀបចំអញ្ជើញគាត់ចាកចេញពីសាលសវនាការ ហើយនឹងអញ្ជើញសាក្សីមួយរូបទៀត KW-30 ចូលសាលសវនាការ ។

[១១:៤០:៣៨]

**ប្រធានអង្គជំនុំ៖**

**ស៖** អ៊ំឈ្មោះ អ៊ុច ស៊ន អ៊ីចឹងមែនទេ?

**សាក្សី KW-30 ៖**

ឆ៖ បាទ ខ្ញុំឈ្មោះ អ៊ុស ស៊ន មែន ។

ស៖ ដល់ឆ្នាំនេះ អ៊ំ អាយុប៉ុន្មានហើយ?

ឆ៖ ឥឡូវហ្នឹង ៧២ហើយ ចូលឆ្នាំថ្មីនេះ៧៣ ។

ស៖ អ៊ំមានមុខរបរសព្វថ្ងៃធ្វើអ្វីដែលអ៊ំ?

តើអ៊ំមានជាប់ញាតិសន្តាន ញាតិលោហិត ញាតិពន្ធ ជាមួយនឹងសហព័ន្ធ ជាសហព័ទ្ធ ឬជាមួយភាគីក្នុងរឿងនេះទេ ជាមួយជនជាប់ចោទ ឬក៏ភាគីផ្សេងទៀតក្នុងរឿង នេះដែរ ឬទេ?

ឆ៖ អត់មានទេ អត់មានជាប់ពាក់ព័ន្ធជាមួយទេ ។

ស៖ នៅក្នុងឱកាសនេះ អង្គជំនុំជម្រះអញ្ជើញអ៊ំមកផ្តល់ចម្លើយ ផ្តល់សក្ខីកម្ម ដែលអ៊ំធ្លាប់បានឃើញ បានដឹង បានឮនៅក្នុងមន្ទីរសន្តិសុខ ម-១៣ ដែលមានទីតាំងស្ថិតនៅអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ នៅក្នុងអំឡុងពេល មុនឆ្នាំ១៩៧៥ ។ សំណួរសួរថា អ៊ំមានបានដែលស្គាល់មន្ទីរសន្តិសុខ ម-១៣ ស្ថិត នៅអមលាំងដែរ ឬទេ? ហើយបើអ៊ំស្គាល់ អ៊ំស្គាល់ចាប់ពីពេលណា?

ស៖ កាលពីមុនឡើយពី ខ្ញុំអត់ដែលស្គាល់ទេ អត់ដែលឮឈ្មោះហ្នឹងទេ មិនដឹងថាមានមន្ទីរម-១៣ ហ្នឹងអត់ដឹងទេ ។ ទាល់ដល់ក្នុងឆ្នាំ១៩៧៣ បានមានគេចាប់ខ្ញុំយកមកដាក់ ម-១៣ ហ្នឹង ទើបបានខ្ញុំដឹង ថាមានមន្ទីរឃុំឃាំងនៅកន្លែងហ្នឹង ។

ស៖ អ៊ំត្រូវគេយកមកដាក់នៅក្នុងមន្ទីរឃុំឃាំងហ្នឹង ម-១៣ នៅអមលាំងហ្នឹង រយៈ ពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំទៅ? ហើយចាប់ពីពេលណា រហូតដល់ពេលណា ទើបអ៊ំបានចេញវិញ?

[១១:៤៣:០២]

ឆ៖ ខ្ញុំនៅធ្វើស្រែហ្នឹងបាន គេធ្វើស្រែប្រហែល១ឆ្នាំ ហើយគេខ្ញុំឆ្នាំ១៩៧៣ ខែចេត្រ ២កើត ខែចេត្រ ខ្ញុំអត់ដឹង អត់ចាំខែបារាំងទេ ដឹងតែថា ថ្ងៃ២កើត ខែចេត្រ គេចាប់ខ្ញុំមកដាក់ ម-១៣ ។

ស៖ អ៊ំរស់នៅទីនោះប្រហែលជាប៉ុន្មានទៅ មួយឆ្នាំ មួយឆ្នាំកន្លះ ឬក៏ពីរឆ្នាំបានគេដោះលែងអ៊ំវិញ?

ឆ៖ ខ្ញុំនៅហ្នឹង បើតាមខ្ញុំចាំ ប្រហែលជាមួយឆ្នាំប៉ុណ្ណឹងទេ ហើយគេលែងខ្ញុំឲ្យទៅពោធិ៍សាត់ បាត់ ទៅនៅក្នុងឆ្នាំ១៩៧៤ ។

**ស៖** តើអ៊ំអាចនិយាយប្រាប់ដល់អង្គសវនាការអំពីអ្វីដែលអ៊ំបានឃើញ បានដឹង បានឮនៅក្នុងអំឡុងពេលដែលអ៊ំបានទៅរស់នៅទីនោះ នូវអ្វីដែលអ៊ំបានចងចាំបានទេ? សូមអញ្ជើញ ។

**ឆ៖** ខ្ញុំនៅជាប់គុកកន្លែងហ្នឹង គឺបានឃើញតែធ្វើទារុណកម្ម ធ្វើបាបអ្នកទោសនោះគ្រប់បែបយ៉ាង មិនអាចរៀបរាប់អស់ទេ ច្រើនណាស់ ដែលការឃើញនោះ គ្រប់បែប ធ្វើទាំងផ្លូវកាយ ផ្លូវចិត្ត និងធ្វើទារុណកម្ម បង្អាត់បាយ អ្នកទោសហ្នឹងក្នុងមួយថ្ងៃៗ ឃើញតែស្លាប់យកទៅអត់ដែរ អត់ដែរអត់មួយថ្ងៃណា អត់ដែលអត់មានទេ គឺមានថ្ងៃណា ព្រឹកឡើងដឹងតែមានយកខ្មោចទៅកប់ហើយ ស្លាប់រាល់ថ្ងៃ ។

[១១:៤៥:១៧]

**ស៖** អ៊ំឃើញទីកន្លែងជាមន្ទីរសន្តិសុខហ្នឹងធំទេ? ប្រហែលជាដីប៉ុន្មានហិតាទៅ?

**ឆ៖** ដីមិនអាចស្មានត្រូវទេ ប៉ុន្តែធំដែរ ប្រហែលតែមួយរយម៉ែត្របួនជ្រុងអីទៅ អានេះដែលក្នុងមន្ទីរឃុំឃាំង កន្លែងដាក់គុកហ្នឹង ហើយជីករណ្តៅ៤ជ្រុងៗ ជម្រៅ៣ម៉ែត្រហ្នឹង ប្រាំ ប្រាំមួយ ប្រាំពីររណ្តៅ ហើយប្រក់ស្លឹកត្នោតពីលើ ដាក់អ្នកទោសនៅក្នុងគុកហ្នឹងទាំងអស់ នៅក្នុងរណ្តៅគុកហ្នឹងទាំងគេទាំងខ្ញុំ គឺជាប់នៅក្នុងហ្នឹង ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រមមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះទេ ? បើមានសូមអញ្ជើញសូមអញ្ជើញលោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ថាតើយើងអាចសូមឲ្យជនជាប់ចោទ ជាដំបូងធ្វើការឈរ ក្រោកឈរសិនបានដែរឬទេ? លោកប្រធាន? ថាតើយើងអាចសុំឲ្យជនជាប់ចោទ ធ្វើការក្រោកឈរឡើងបានដែរ ឬទេ?

យើងនិយាយជាមួយសាក្សី ។ អ៊ុច ស៊ន លោកឮខ្ញុំបានដែរឬទេ? លោកស្តាប់ខ្ញុំបានដែរ ឬទេ?

**សាក្សី KW-30៖**

**ឆ៖** បាន ។

**ស៖** ខ្ញុំសូមឲ្យលោកមើលសម្លឹងទៅកាន់ជនជាប់ចោទ ថាតើលោកស្គាល់ និងឃើញជនជាប់ចោទដែរឬទេ?

**ឆ៖** ខ្ញុំមើលទៅឆ្ងាយអត់ឃើញទេសព្វថ្ងៃ ឥឡូវងងឹតភ្នែកខ្លាំងណាស់ ឃើញស្មុងៗ មើលគេ

ឯងគ្រប់គ្នាហ្នឹង មើលឃើញស្មង់ៗ ងងឹតភ្នែក មើលទៅឆ្ងាយអត់បាន ។

**ស៖** ជាមួយនឹងកាមេរ៉ា សូមឲ្យធ្វើការចាប់យករូបភាពជិត ដើម្បីឲ្យសាក្សីគាត់អាចមើលឃើញជនជាប់ចោទឲ្យកៀកនឹងអេក្រង់ ។ ថាតើយើងអាចចាប់យករូបភាពឲ្យជិតដែរឬទេ ដោយយើងប្រើប្រាស់ ម៉ាស៊ីនកាមេរ៉ារបស់យើង?

ឥឡូវខ្ញុំចង់សួរសាក្សី ថាតើលោកបានឃើញរូបភាពនៅលើអេក្រង់ ឬឃើញបុរសណាមួយនៅលើអេក្រង់ដែរឬទេ? ថាតើលោកអាចមើលឃើញបានដែរ ឬទេ?

**ឆ៖** ឃើញ មើលឃើញ ។

[១១:៤៨:៣០]

**ស៖** លោកអាចធ្វើការបញ្ជាក់ឲ្យច្បាស់លាស់ទៅលើរូបរាងបាន ដែរឬទេ? ឬក៏ពិបាកចំពោះលោក ក្នុងការមើលទៅលើរូបភាពបញ្ជាក់ឲ្យបានច្បាស់?

ប្រាប់យើងខ្ញុំ ប្រសិនបើលោកមិនអាចមើលឃើញច្បាស់លាស់ ចំពោះរូបភាពបុគ្គលនៅទីនោះ សូមលោកជម្រាប បើសិនជាមើលមិនឃើញច្បាស់?

**ឆ៖** បាទ, មើលឃើញច្បាស់ហើយ ។

**ស៖** អ៊ីចឹងលោកឃើញរូបភាព ដូច្នេះលោកស្គាល់ជនជាប់ចោទដែរឬទេ? លោកអាចស្គាល់ថាបុគ្គលនេះ គឺជាប្រធាន ម-១៣ដែរ ឬទេ?

**ឆ៖** ស្គាល់ពិត ហ្នឹងហើយជាប្រធាន ម-១៣ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ថាតើជនជាប់ចោទអាចជម្រាបយើងខ្ញុំ ថាតើជនជាប់ចោទស្គាល់សាក្សីដែរ ឬទេ?

**ជនជាប់ចោទ៖**

**ឆ៖** សូមជម្រាបលោកចៅក្រមថា ខ្ញុំចំណាំមុខអត់បានទេ ខ្ញុំសូមអនុញ្ញាតលោកចៅក្រមៗសួរទៅសាក្សីមួយម៉ាត់ អំពីឈ្មោះ សួរតែអំពីឈ្មោះគាត់ ឈ្មោះហៅក្រៅរបស់គាត់ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកអ៊ុច ស៊ន តើលោកមានឈ្មោះហៅក្រៅដែរ ឬទេ?

**សាក្សី KW-30 ៖**

មានតែមួយហ្នឹង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ឌុច សូមឲ្យលោក លោកអាចអង្គុយចុះហើយពេលនេះ ។ គឺកាលៈទេសៈ ដែលលោកត្រូវបានចាប់ខ្លួន ហើយមូលហេតុអ្វីបានជាលោកត្រូវបានគេចាប់ខ្លួន?

**សាក្សី KW-30 ៖**

**ឆ៖** ដែលគេចាប់ខ្លួនខ្ញុំបាទហ្នឹង ខ្ញុំទៅរកទិញជ្រូក នៅបឹងខ្នារអំបឹស ណោះ ហើយ យកមកដើម្បីគិតធ្វើបុណ្យ ហើយទៅពេលហ្នឹងស្រាប់តែពួកនៅឯកន្លែងស្រែបឹងខ្នាអំបឹស ហ្នឹង ប្រធានភូមិគេចាប់ខ្ញុំមកយកមកដាក់ម-១៣ ហ្នឹង ។

[១១:៥២:១២]

**ស៖** តើគេប្រាប់លោកថាគេចោទលោកពីបទអ្វី?

**ឆ៖** គេចោទថាខ្ញុំហ្នឹងគិញ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំមានសំណួរសម្រាប់ជនជាប់ចោទ ។ ខ្ញុំសូមនិយាយសាជាថ្មី អ៊ុច ស៊ន គឺ គាត់បានផ្តល់សក្ខីកម្មជាសាធារណៈ ។ កាលពីមុន គឺគាត់ហៅថា KW-30 កាលពីម្សិលមិញ លោកបានឆ្លើយអំពីមូលហេតុ ដែលសាក្សី KW-30 ត្រូវបានគេនាំទៅម-១៣ តើលោកចាំអំពីការលោកលើកឡើងដូច្នេះដែរឬទេ?

**ជនជាប់ចោទ៖**

**ឆ៖** លោកចៅក្រមជាទីគោរព! នៅពេលដែលឃើញឈ្មោះ អ៊ុច ស៊ន នេះ ហើយនៅភូមិស្នួល ខ្ញុំនឹកដល់បុគ្គលម្នាក់ទៀត ឈ្មោះ អ៊ុច ស៊ន ហៅ សុង ដែលគេបញ្ជូនទៅ ម-១៣ របស់ខ្ញុំ ប្រហែលជានៅក្នុងខែប្រាំបួន ឆ្នាំ១៩៧១ ។ ហើយដល់ក្រោយមក ខ្ញុំក៏បានសុំអនុញ្ញាតខាងលើ ដោះលែងទៅផ្ទះវិញ ដល់ឆ្នាំ១៩៧៣ ខ្ញុំទៅអញ្ជើញគាត់មកធ្វើជាកងការពារខ្ញុំ ដូច្នេះហើយបានខ្ញុំសូមអនុញ្ញាតលោកចៅក្រម សុំសួរឈ្មោះបុគ្គលសាក្សីរូបនេះ ។ ដូច្នេះ រឿងហេតុ វាមិនមែនបង ស៊ន, អ៊ុច ស៊ន ហៅបង សុង ដែល ខ្ញុំស្គាល់នោះទេ ហើយរឿងហេតុដែលគាត់រាយការណ៍ជូនលោកចៅក្រមក៏ប្លែក ។ ដូច្នេះ គាត់អាចជាជនជាប់ទោសម្នាក់ ជនរងគ្រោះម្នាក់ដែលគេបញ្ជូនទៅជាប់ទោសនៅទីនោះ។

ដូច្នេះ សូមលោកចៅក្រមសួរគាត់តាមជាក់ស្តែងចុះ ឯចំណែកខ្ញុំ ខ្ញុំច្រឡំទេ សក្ខីកម្មខ្ញុំទាំងប៉ុន្មានដែលរាយការណ៍ជូនលោកចៅក្រម ។

[១១:៥៤:២៥]

**ស៖** ខ្ញុំចង់ឲ្យលោករំឭកអង្គជំនុំជម្រះអំពីមូលហេតុ ដែលលោកបានលើកឡើង អំពីមូលហេតុ ដែល KW-30 គាត់បញ្ជូនទៅម-១៣ ។ ម្សិលមិញលោកនិយាយជាក់លាក់ អំពីបញ្ហាហ្នឹង?

**ឆ៖** ខ្ញុំច្រឡំនឹងបុគ្គលម្នាក់ទៀតៗ នៅភូមិស្ពួលដូចគ្នា ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** តើសាក្សីប្រាប់យើងខ្ញុំបានទេ ថាលោកនៅភូមិស្ពួល?

**សាក្សី KW-30៖**

**ឆ៖** ខ្ញុំនៅភូមិស្ពួល ។

**ស៖** ថាតើមានបុគ្គលផ្សេង ដែលមានឈ្មោះ ដូចគ្នានៅក្នុងភូមិស្ពួលដែរ ឬទេ?

**ឆ៖** មានឈ្មោះ សុង ហ្នឹងនៅភូមិស្ពួលមែន តែអត់ឈ្មោះ ដូចខ្ញុំទេ ឈ្មោះ សុង ដូចគាត់និយាអំមិញអ៊ីចឹង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកបានប្រាប់យើងថា បុគ្គលដែលលោកចង្អុលពីម្សិលមិញនោះ គឺមិនមែនដូចបុគ្គលគ្នានឹងសាក្សីនៅទីនេះទេ ។

**ជនជាប់ចោទ៖**

**ឆ៖** មែន ។

**ស៖** ខ្ញុំសូមបញ្ជាក់ឡើងវិញ លោកកាលម្សិលមិញលោកបញ្ជាក់ ចង្អុលអំពីបុគ្គល មួយដែលថាបុគ្គលនោះត្រូវបាននាំយកទៅម-១៣ ដោយមូលហេតុជាក់លាក់ ។ តើលោកបានចាំដែរឬទេ?

**ឆ៖** បុគ្គលបង សុង ដេត ដែលខ្ញុំបានជម្រាបលោកចៅក្រម គឺពិតជាមានបញ្ហាដូច្នេះមែន ដែលគេនាំមកឲ្យខ្ញុំ ហើយខ្ញុំពិតជាបានដោះលែង ។ ហើយដល់ក្រោយមកខ្ញុំពិតជាបានអញ្ជើញគាត់មកជួយធ្វើជាកងការពារ ។

**ស៖** លោកបាននិយាយថា អំពីមូលហេតុជាក់លាក់ដែលបុគ្គលនោះ នាំមកម-១៣ តើលោកចាំដែរ ឬទេ?

**ឆ៖** បាទ, ខ្ញុំចាំ ។

**ស៖** តើមានមូលហេតុអ្វីបានជាបុគ្គលនេះ ត្រូវបានគេនាំមក ម-១៣?

**ឆ៖** សូមបញ្ជាក់លោកចៅក្រមថា ដែលលោកចៅក្រមចង់មានប្រសាសន៍នឹងគឺ ពីរឿងគេនាំបង សុង មកដំបូង ឬក៏ដែលខ្ញុំទៅសុំគាត់មក-- អញ្ជើញគាត់មកធ្វើកងការពារ ។ បើថា បង សុង មកដំបូង អាហ្នឹងខ្ញុំនូវតែរក្សា សេចក្តីបញ្ជាក់របស់ខ្ញុំដដែល ។

**ស៖** ប្រហែលខ្ញុំស្តាប់អត់ឮកាលពីម្សិលមិញ ។ ស្តាប់អត់ឮបានត្រឹមត្រូវ កាលពីម្សិលមិញខ្ញុំឮលោកនិយាយថា បុគ្គលនោះត្រូវបាននាំមក ម-១៣ បន្ទាប់ពីមានបញ្ហាអំពីបុគ្គលិកលក្ខណៈរបស់បុគ្គលនោះ ។ ហើយបន្ទាប់មកគឺ មានការកាត់ករបុគ្គលនោះ ដោយកាំបិត ។

[១១:៥៨:២០]

**ឆ៖** សម្រាប់បុគ្គលនោះបង សុង ដែលនៅឯភូមិ ឯផ្ទះនុ៎ងទេ មិនមែនត្រូវសម្រាប់ បង ស៊ិននៅទីនេះទេ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ដូច្នេះខ្ញុំយល់ហើយនៅពេលនេះ ។ ខ្ញុំសុមសួរសាក្សីថា តើលោកដែលមានកាត់ក្បាលនរណាម្នាក់ដោយកាំបិតដែរឬទេ?

**សាក្សី KW-30៖**

**ឆ៖** ខ្ញុំអត់មានទេ ។ មានតែ សុង ហ្នឹងទេ កាប់ក្បាលគេ អ្នកដែលកាប់ហ្នឹង-- អ្នកដែលរងគ្រោះហ្នឹង គឺឈ្មោះ យ៉ែម សព្វនៅរស់ឡើយទេ ។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ? ថាតើបញ្ហាអនាមយយ៉ាងម៉េចនៅទីនោះ? នៅមន្ទីរម-១៣ ។ ថាអនាម័យយ៉ាងម៉េចនៅពេលដែលអ្នកទោសរស់នៅ តើគេបានងូតទឹក ហើយគេទៅបត់ដៃ បត់ជើងយ៉ាងម៉េច? ហើយគេអាចងូតទឹកបានដែរឬ ទេ?

**ឆ៖** នៅពេលនុ៎ងបាន គេជាប់ដែលនៅក្នុងរណ្តៅហ្នឹង គេដោះខ្នោះជើងអ៊ីចឹងមក ហើយគេឲ្យដាក់ជណ្តើរឲ្យឡើងមក គេឲ្យទៅងូតទឹករបស់មន្ទីរម-១៣ហ្នឹង វានៅជាប់មាត់ស្ទឹងពីខាងត្បូងស្ទឹងពីខាងកើតត្រពាំងច្រាប ពីខាងជើងត្រពាំងច្រាប ។ អ៊ីចឹងទេ អាចមកងូតទឹកបាន គេដោះលែងជាប់ចំណងដៃ តែគេឲ្យមកងូតទឹកបាន ។

[១២:០០:៣០]

**ស៖** តើលោកអាចនិយាយប្រាប់យើងអំពីចំនួនដែលអ្នកទោសគេឃុំនៅទីនោះ នៅម-១៣ បានដែរឬទេ?

**ឆ៖** ខ្ញុំមិនអាចស្មានត្រូវទេ ព្រោះខ្ញុំវាជាអ្នកទោសដែរ ។ ខ្ញុំនៅក្នុងរណ្តៅគុកដែរ តែមិនដឹងជា-- តែតាមដែលខ្ញុំស្មានទៅមនុស្សមិនតិចទេយ៉ាងតិចក៏ពីរ-បីពាន់នាក់ដែរ។

**ស៖** ពីរទៅបីពាន់ គឺគាត់នៅពេលតែមួយឬក៏យ៉ាងម៉េច? ឬក៏វានៅក្នុងអំឡុងពេល លោកត្រូវបានគេឃុំខ្លួននៅទីនុ៎ង ។

**ឆ៖** ដែលខ្ញុំទៅឃើញហ្នឹង ឃើញនៅក្នុងរណ្តៅគុក ពីព្រោះគុកវា-- តែខ្ញុំមិនបានចាំ មិនដឹងប៉ុន្មានរណ្តៅទេ ខ្ញុំភ្លេចទៅ តែវានៅពេញៗរណ្តៅហ្នឹង ទាំងគេទាំងខ្ញុំហ្នឹង ។ ខ្ញុំនិយាយតាមស្មានទេ ព្រោះខ្ញុំវានៅជាអ្នកទោសដែរ មិននឹងបានចេញមកមើលឲ្យច្បាស់លាស់ ។ ពេលដែលបានឃើញហ្នឹង ពេលដែលគេចេញមកឲ្យងូតទឹក ឬក៏ឈើបត់ជើង ឡើងមកមួយពេលទេៗ ។ ងាកភ្នែកទៅមើល តែនិយាយការស្មានមិនបានរាប់ឲ្យដឹងចំនួនថា មនុស្សវាមានប៉ុន្មានៗមិនដឹង ។

**ស៖** គឺខ្ញុំអត់ដឹងថា លោកយល់សំណួររបស់ខ្ញុំដែរឬទេ? ថាតើលោកឃើញពីរពាន់បីនាក់ហ្នឹងនៅពេលណាមួយ? ឬក៏ឃើញនៅពេលតែជាមួយគ្នា? បានន័យថា ពីរ-បីពាន់ហ្នឹងក្នុងពេល-- មួយអំឡុងពេលគេឃុំអ្នកទោសនោះ ឬយ៉ាងម៉េច?

**ឆ៖** ឃើញនៅពេលដែលទៅដល់កន្លែងគុកហ្នឹងហើយ ឃើញនូវអ្នកទោសនៅជាប់ឃុំឃាំងហ្នឹងតែម្តង ទាំងអស់ហ្នឹង ។ ហើយខ្ញុំស្មាននឹងថា មនុស្សបើយ៉ាងតិចក៏ត្រឹមប៉ុណ្ណឹងដែរ ។ បើតិច ។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំដែរ ឬទេ ថាជាស្ត្រី បុរស ឬក៏ក្មេង?

**ឆ៖** ជាប់ឃុំនៅកន្លែងនុ៎ង គឺមានទាំងស្ត្រីក៏មាន បុរសក៏មានបាទ ចាស់ក៏មាន ក្មេងក៏មាន ។

[១២:០៣:៤៣]

**ស៖** ថាតើមានក្មេងច្រើនដែរ ឬទេ?

**ឆ៖** បាទ, មានមិនច្រើនប្រមាណទេ ប្រហែលខ្ទង់ សាមសែសិបនាក់ប៉ុណ្ណឹងទេ ក្មេង ច្រើនតែមនុស្សចាស់ ក៏ដែលចាស់ៗខ្លាំងមែនទែនក៏មានតិចដែរ ច្រើនពេញវ័យកណ្តាលហ្នឹង បានច្រើន ។ ហើយអ្នកទោសហ្នឹងមិនមែនជាប់គុកតែពួកកងទ័ព-- ខ្មែរក្រហមក៏មានជាប់គុកនៅនុ៎ងដែរ ។

**ស៖** ដូច្នេះមានទាហានខ្មែរក្រហម ថាតើមានសមាមាត្រទៅនឹងចំនួនក្មេងក្រហម ដែរឬទេ?

**ឆ៖** ទាហានខ្មែរក្រហមនឹងមូលហេតុមកពីវាបាក់ទ័ពនៅសមរភូមិមុខ គេយកមកដាក់នៅកន្លែងហ្នឹង ។

**ស៖** លោកច្បាស់ទេថា គេជាទាហានខ្មែរក្រហម ឬក៏គេជាទាហានខ្មែរក្រហមរបស់ លន់នល់ ថា ពួកគេជាអ្នកមកពីមកសាធារណរដ្ឋ លន់ នល់ ឬយ៉ាងម៉េច?

**ឆ៖** គេៗ អ្នកទោសហ្នឹងវា ពេលដែលបញ្ចេញមកឈឺបត់ជើង ទៅង្វូតទឹកអីខ្ញុំជាអ្នកទោសអីដូចគ្នាហ្នឹងលួចស្នួរអីចឹងទៅ ។ គេប្រាប់ថា ខ្ញុំនឹងធ្វើទ័ព ហើយដល់ពេលទៅវ៉ៃទាហាន លន់ នល់ វាបាក់ ។ បាក់ទ័ពអីចឹងទៅវាបាក់ស្មារតីអីចឹងគេយកមកដាក់នៅកន្លែងឃុំឃាំងហ្នឹង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

*(មិនឮសំឡេងនិយាយ)*

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលត្រូវពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសសម្រាក់ដើម្បីពិសាអាហារថ្ងៃត្រង់ រហូតដល់ម៉ោង១ និង៣០នាទីរសៀលបន្ត សវនាការទៀត ។

ហើយអនុមន្ទីរឃុំឃាំងនាំជនជាប់ចោទត្រឡប់ទៅបន្ទប់រងចាំ និងនាំគាត់មកវិញ មកកាន់សាលសវនាការឲ្យមុនម៉ោង ១ និង៣០នាទីរសៀលនេះជាកំណត់ ។

មន្ត្រីតុលាការ សូមសម្រួលរៀបចំអញ្ជើញសាក្សីទៅកាន់បន្ទប់រងចាំ រៀបចំម្ហូបអាហារជូនគាត់ ហើយនិងអញ្ជើញគាត់ត្រឡប់មកវិញឲ្យបាននៅម៉ោង១ និង៣០នាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១២:០៦នាទីដល់ម៉ោង ១:៣៥នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការតទៅទៀត ។ ហើយជាកិច្ចបន្តនេះ សូមប្រគល់វេទិកានៃការតាំងសំណួរដល់សាក្សីរូបនេះ ទៅដល់លោកចៅក្រម ហ្សង់ម៉ាក ដើម្បីដំណើរការ សូមអញ្ជើញ លោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** តើសាក្សីឮខ្ញុំដែរឬទេ? តើលោកសាក្សីឮខ្ញុំដែរឬទេ? តើលោកសាក្សីឮដែរ ទេ?

បាទ ។ ថាតើលោកមានបញ្ហាស្តាប់អត់ឮ ឬក៏លោកមានបញ្ហាមើលអត់ឃើញផងដែរ?

**សាក្សី KW-30៖**

**ឆ៖** បាទ, ឮហើយ ។

**ស៖** ព្រឹកមិញនេះ គឺលោកមានបញ្ហា លោកមិនអាចមើលឃើញជុំវិញខ្លួន ថាតើលោកមើលអត់ឃើញហ្នឹងយូរហើយឬនៅ?

**ឆ៖** មើលអត់ឃើញហ្នឹង យូរហើយ ។

**ស៖** នៅពេលដែលគេលោកឃុំនៅម-១៣ ថាតើលោកមើលអត់ឃើញដែរឬក៏យ៉ាងម៉េច?

**ឆ៖** កាលគេឃុំនៅខ្ញុំនៅម-១៣នេះ ខ្ញុំនៅក្មេងនៅឡើយ តាំងពីឆ្នាំ៧៣ណោះ ។

**ស៖** នៅពេលនោះ គឺលោកមើលឃើញភ្នែកលោកមានការមើលឃើញធម្មតា ឬក៏យ៉ាងម៉េច?

**ឆ៖** មើលឃើញធម្មតា នៅក្មេងនៅឡើយកាលនុ៎ង ប្រហែលជាអាយុខ្ញុំប្រហែលជា ៤០ នៅឡើយ ។

**ស៖** ថាលោកបានទៅរៀនដែរ ឬទេ? តើលោកទទួលការអប់រំផ្លូវការដែរឬទេ? លោកអានអាចសរសេរ អាចរាប់លេខអីបានដែរឬទេ?

**ឆ៖** ខ្ញុំចេះអក្សរខ្មែរ អានបានបន្តិចបន្តួច ។ រៀនអត់សូវបានជ្រៅជ្រះប៉ុន្មានទេ គឺជាអ្នកល្ងង់ដែរទេ។

**ស៖** តើលោកអាចចេះរាប់ដែរ ឬទេ?

**ឆ៖** ចេះរាប់ ចេះ ។

**ស៖** ព្រឹកមិញ យើងនិយាយអំពីអ្នកទោសដែលនៅម-១៣ ។ លោកនិយាយជាមួយខ្ញុំអំពីទាហាន ថាពួកគេ គឺជាទាហានខ្មែរក្រហម ។ លោកប្រាប់ខ្ញុំថា គេត្រូវបានទទួលការ រងការបាក់ទ័ពដោយសារសង្គ្រាមរបស់សាធារណរដ្ឋ ។

ថាតើនេះជាចំណុច ដែលលោកបានលើកឡើងដែរ ឬទេ? ហើយវាជាការពិតដែរ ឬទេ?

**ឆ៖** អារឿងហ្នឹង ដែលខ្ញុំបានដឹងហ្នឹង ដោយសារតែអ្នកដែលរងគ្រោះនោះទេ ដែលទៅមុជទឹកជាមួយខ្ញុំ ហើយក៏លួចខ្សឹបសួរទៅ គេប្រាប់ថាខ្ញុំបាក់ទ័ពពីសមរភូមិមុខមក មកដល់ក្នុងភូមិឃុំ គេចាប់យកមកដាក់ម-១៣ ទៅ ។

**ស៖** ថាតើសំលៀកបំពាក់ពួកគេស្លៀកពាក់យ៉ាងម៉េច?

[១៣:៤១:៤៨]

**ឆ៖** ន៎ែ! ចាប់យកមកហ្នឹង ស្លៀកពាក់ស៊ីវិលធម្មតាហើយ លែងស្លៀក-- មិនមែនខ្មៅសុទ្ធទេ ស្លៀកដូចជាប្រជាជនទូទៅហើយ ដែលគេចាប់មក យកមកដាក់គុកហ្នឹង ។

**ស៖** ខ្ញុំអត់យល់ទេ ថាពួកគេស្លៀកពាក់ខោអាវពណ៌ខ្មៅ ឬក៏អត់ស្លៀកពាក់ខោអាវពណ៌ខ្មៅទេ?

**ឆ៖** បាទ ធម្មជាតិ ធម្មតា ដូចយើងស៊ីវិលមានខ្មៅ មានអាវសអីចឹងទៅ ខោខ្មៅអីចឹងទៅ ។ ហើយព្រោះមកដល់ក្នុងភូមិឃុំហ្នឹង គេចាប់យកមកពង្រឹងស្មារតីក៏មិនដឹង អីមិនដឹង យកមកដាក់ម-១៣ ហ្នឹងខ្ញុំឃើញអីចឹង ដល់ពេលថ្ងៃមួយ ដែលគេបញ្ចេញទៅងូតទឹកហ្នឹង ខ្ញុំក៏បានសួរគេ ក៏គេប្រាប់ថា ខ្ញុំធ្វើទ័ព ហើយគេជជែកគ្នាពីរឿងវាយតានេះ តានោះ បាក់ទ័ពតានេះ បាក់ទ័ពតានោះ ហ្នឹងខ្ញុំឮដោយសារតែពាក្យ អ្នកគ្នារងគ្រោះនោះទេ និយាយនោះ ។

**ស៖** លោកក៏បានប្រាប់ព្រឹកមិញថា គេត្រូវបានឃុំលោកនៅក្នុងរណ្តៅ ។ តើលោក អាចពិពណ៌នាឲ្យបានច្រើនជាងនេះដែរឬទេ? ថាលោកអាចពិពណ៌នា និងរៀបរាប់ឲ្យបានច្រើនជាងនេះ អំពីរណ្តៅនុ៎ង ថាតើរណ្តៅនុ៎ងវាយ៉ាងម៉េចដែរ?

**ឆ៖** រណ្តៅនុ៎ងជម្រៅ៣ម៉ែត្រ ។ នៅជាប់គុកហ្នឹងយូរណាស់ អត់មានកន្ទេលដេក ទេ ដេកផ្ទាល់ហ្នឹងដី ។ ពេលណាឈឺបត់ជើងតូច បត់ជើងធំ បានគេដាក់ជណ្តើរឲ្យឡើងមក តែដៃនៅជាប់ចំណងទេ គេអត់លែងទេ លែងតែខ្នោះជើង ។ ហ្នឹងដែលនៅក្នុងហ្នឹង ។

**ស៖** ថាតើមានចំនួនមនុស្សប៉ុន្មាននៅក្នុងរណ្តៅនីមួយៗ?

**ឆ៖** នៅក្នុងរណ្តៅនីមួយៗ បើខ្ញុំស្មានទៅ និយាយស្មានទេ ក្នុងពេលហ្នឹងវាអត់បានរាប់បានអីទេ តែបើថាយ៉ាងតិចណាស់ ក៏២០ ទៅ ៣០នាក់ដែរ ក្នុងមួយរណ្តៅ ។

[១៣:៤៤:៥២]

**ស៖** ថាតើមានរណ្តៅប៉ុន្មាននៅទីនោះ?

**ឆ៖** រណ្តៅ អត់ចាំផង ទាល់តែស្មានប្រហែលយ៉ាង ប្រហែលតែ ៦, ៧ មិនដល់ប៉ុណ្ណឹង ។

**ស៖** ថាតើរណ្តៅនោះមានទំហំប៉ុនគ្នាដែរ ឬទេ? ឬក៏លោកនៅរណ្តៅធំជាង ហើយឬក៏នៅរណ្តៅតូចជាងគេ តើលោកអាចពន្យល់បានទេ?

**ឆ៖** រណ្តៅហ្នឹង បើតាមខ្ញុំស្មាន ដែលមើលទៅទំហំបែបប៉ុនគ្នាៗ អត់មានអ្នកណាតូចជាងអ្នកណាទេ ប៉ុនគ្នាៗ។

**ស៖** លោកបានប្រាប់យើងថា លោកត្រូវបានគេដាក់ខ្នោះ ។ ថាតើគេដាក់ខ្នោះ លោកយ៉ាងម៉េច?

**ឆ៖** គេដាក់ខ្នោះជើង មានរនងដែកពីក្រោម កង គេធ្វើកងយកអាររនងដែកពីក្រោមទៅ គេដាក់ខ្នោះជាប់គ្នាកងជើងហ្នឹង ។ ក្នុងម៉ាររនងៗ ៥ ទៅ ៦នាក់ ក្នុងម៉ាររនងៗដែក ។

**ស៖** ថាតើមានបញ្ហាកើតឡើងទេ នៅពេលដែលមានភ្លៀងធ្លាក់?

**ឆ៖** មានពេល-- ពេលដែលមានភ្លៀងធ្លាក់ហ្នឹង គឺជោគអស់ហើយ ។ ដំបូលហ្នឹងវាទទៀលពេក ប៉ុន្តែវាធំ វាអត់បាននេះ-- វាលិចជោគអស់ ។

**ស៖** ថាតើលោកមានរងគ្រោះ ដោយសារលិចទឹកដែរឬទេ? នៅក្នុងរណ្តៅហ្នឹង។

**ឆ៖** កាលដែលនៅខ្ញុំជាប់ហ្នឹង អត់ទាន់មានរងគ្រោះទេ តែគ្រាន់តែជោគ ហើយក៏អត់មានបន្លាស់ផ្លាស់ប្តូរខោអាវ ទទឹកហ្នឹង ស្ងួតហ្នឹង តែខោមួយបន្លាស់ហ្នឹង ។

[១៣:៤៨:០១]

**ស៖** អ៊ីចឹង លោកអាចមានលទ្ធភាពប្តូរខោអាវទេ នៅពេលដែលខោអាវសើម?

**ឆ៖** បាទ អត់មានខោអាវផ្លាស់ ។ ខោ-- គេចាប់ទៅ ឧបមាថា អាវមួយ ខោមួយ ក្រមាមួយ មានតែប៉ុណ្ណឹង ។ អត់មានខោអាវអីផ្លាស់ទៀតទេ ។

**ស៖** ថាតើអ្នកទោសទាំងអស់នោះ គឺស្លៀកតែ*ស្លីភេ*ទ ឬក៏គេមានខោអាវស្លៀកពេញលេញដែរ?

**ឆ៖** តាមខ្ញុំមើលទៅអ្នកទាំងអស់ ដូចជាប់គុកខ្ញុំដែរ អត់មានៗខោអាវអីផ្លាស់ប្តូរទេ ។ អ្នកទោសខ្លះហ្នឹង គេចងភ្ជាប់នឹង-- បុះបង្គោលជួរអ៊ីចឹងៗ គេចងម្នាក់ៗមួយហ្នឹង ស្រាតខ្លួនទទេ ខ្ទៀវខ្ទីង ។

**ស៖** គឺថាពួកគេខ្លួនទទេសោះតែម្តងអត់មានខោអាវទេ ឬយ៉ាងម៉េច?

**ឆ៖** កាលដែលចាប់ទៅ មានខោអាវ តែដល់ពេលគេចងភ្ជាប់នឹងបង្គោល គេជីកបង្គោល-- សង់ជួរអ៊ីចឹង ដូចបង្គោលរបងអ៊ីចឹង គេចងមនុស្សម្នាក់មួយៗ សម្រាតខ្លួនទទេ ទាំងអស់ អត់មានខោអាវអីទេ គេស្រាតចោលអស់ហើយ ។

[១៣:៥០:០០]

**សៈ** ថាតើលោកបានឃើញអ្នកទោសណាមួយឈឺដែរឬទេ?

**ឆៈ** អ្នកទោសនោះ តិចណាស់អ្នកជា ពីព្រោះគេឲ្យហូបបាយហូបបបរតែមួយវែក ។ ខ្លះក៏បានជាប់បួនដប់ថ្ងៃទៅ ខ្លះក៏ជាប់បានកន្លះខែទៅ ស្លាប់អស់ ស្លាប់ដោយសារ ដាច់បាយហ្នឹង ដាច់ស្បៀងហ្នឹង ។

**សៈ** ថាតើលោកត្រូវបានគេឲ្យញ៉ាំរាល់ថ្ងៃ ឬក៏គេឲ្យ-- ហើយគេឲ្យញ៉ាំអីខ្លះ?

**ឆៈ** រាល់ថ្ងៃហ្នឹង បានបបរព្រឹកមួយវែក ល្ងាចមួយវែក ហើយហូបមិនគ្រប់គ្រាន់ អ្នកខ្លះក៏គ្នាស្លាប់អស់ទៅ ។ នេះខ្ញុំហ្នឹងដែលបានរួចខ្លួន មានរស់រានមានជីវិតហ្នឹង ខ្ញុំជាប់តាំងពីទល់គ្នាខែកត្តិក ខែដប់មួយ គេឲ្យខ្ញុំ--លោកឌុច ហ្នឹងលោកដោះខ្ញុំលែងចេញ មក គាត់បញ្ជូនខ្ញុំទៅពោធិសាត់នៅឆ្នាំ១៩៧៤ បាត់ទៅ ខ្ញុំទៅនៅខេត្តពោធិសាត់បាត់ រួចក្រោយពីហ្នឹងមកខ្ញុំលែងបានដឹងអីទៀតហើយ ខ្ញុំដឹងតែកាលដែលខ្ញុំនៅក្នុងគុកតែប៉ុណ្ណឹងទេ ។

**សៈ** ថាលោកចាំទេ ថាលោកត្រូវបានសម្ភាសដោយអ្នកស៊ើបអង្កេតមកពីតុលាការ តើលោកចាំទេថា អ្នកស៊ើបអង្កេតពីតុលាការនេះគេទៅសម្ភាសនលោក?

**ឆៈ** បាទ ចាំ ។

**សៈ** នៅក្នុងសំណុំរឿង យើងមានកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់លោក គឺមានលេខ D៧៨ នៅទំព័រទី៣ ភាសាអង់គ្លេសគឺលេខ ERN0095537។ ឯកសារ បារាំងលោកបានិយាយថា "អ្នកទោសស្លាប់ដោយសារតែអត់ឃ្លាន គឺមានច្រើន ហើយ អ្នកដែលស្លាប់ខ្លះដោយសារទារុណកម្មរៀងរាល់ថ្ងៃមានអ្នកទោសប្រហែលដប់ទៅដប់ ប្រាំនាក់ស្លាប់ដោយសារអត់អាហារ" ។

តើលោកអាចបញ្ជាក់នូវអ្វី ដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះទេ ថាវាឆ្លើយ តបនឹងការសម្ភាសន៍យកចម្លើយលោកជាមួយនឹងអ្នកស៊ើបអង្កេត ពិតមែនដែរឬទេ?

**ឆៈ** បាទុ,ពិត ។ ស្លាប់ដោយសារនឹងអត់អាហារហ្នឹងមួយថ្ងៃយ៉ាងតិចក៏ដប់ទៅ ប្រាំទៅដប់នាក់ជារៀងរាល់ថ្ងៃ ។ ដែលការស្លាប់ដោយធ្វើទារុណកម្ម ខ្ញុំបានឃើញគេចងមនុស្សបួននាក់ប្រាំនាក់ គេបោះបង្គោលជាបួន បោះបង្គោលជាបួនៗ អ៊ីចឹងហើយគេបោះបង្គោលកណ្ដាលមួយ ហើយគេចងអាបួននាក់ហ្នឹង បង្គោលបួនហ្នឹងចងម្នាក់មួយៗ អ្នកកណ្ដាលគេចងអាអ្នកនៅកណ្ដាលគេហ្នឹង គេបាញ់អាហ្នឹង គេបាញ់អាអ្នកកណ្ដាលហ្នឹងបាញ់ឲ្យងាប់ហ្នឹង ។ តែដឹងបាញ់ហ្នឹង ដើម្បីបំបាក់ស្មារតី

ឲ្យអ្នកប្អូនទាក់ហ្នឹងឆ្លើយ គឺដើម្បីគេយកសំណួរក៏មិនដឹងអីមិនដឹង ព្រោះខ្ញុំជាអ្នកទោសគ្រាន់តែក្រឡេកឃើញ មើលឃើញ គឺពិតអ៊ីចឹង អត់មាននិយាយដោយភរកុហក គឺឃើញពិតនឹងភ្នែក ។

[១៣:៥៤:៤៩]

**ស៖** ដូច្នេះ លោកបញ្ជាក់ថា រៀងរាល់ថ្ងៃ គឺមានអ្នកទោសច្រើនដែលស្លាប់ដោយសារអត់ឃ្លាន ។

**ឆ៖** បាទ, អ្នកទោសច្រើនស្លាប់តែរាល់ថ្ងៃ មិនដែលថ្ងៃណាមួយថា អត់ទេ បើតិចណាស់ក៏នៅពីរបីនាក់មួយថ្ងៃ ពីរ-បីនាក់ទៅប្រាំនាក់ទៅដប់នាក់ ជួនតិចជួនច្រើនរាល់ថ្ងៃ ។ អ្នកស្លាប់ដោយទារុណកម្មហ្នឹង ខ្ញុំបានឃើញតែពីរនាក់ទេ ដែលធ្វើបាញ់ដូចខ្ញុំនិយាយអំមិញហ្នឹង បាញ់ទៅកណ្តាលមន្ទីរហ្នឹង គឺអ៊ីចឹង តែដល់ស្លាប់ដោយវាយ ដោយអី គ្រប់ទីគ្រប់កន្លែងផង វាគ្រប់ច្រកល្ហក គេមិនឲ្យយើងឃើញប៉ុន្មានទេ ព្រោះយើងជាអ្នកទោស ។ ពេលណាយើងដើរទៅជួនក៏ឃើញទៅ ហើយក៏មិនហ៊ានឈរមើលគេដែរ ព្រោះខ្លាចខ្លួនដល់ថ្ងៃណាមួយខ្លួនស្លាប់ដែរ ស្លាប់ដូចគេដែរ នៅមានថ្ងៃណាមួយទេ ស្លាប់នឹងគេដែរ នៅមានថ្ងៃណាមួយទេ ។

**ស៖** ដូច្នេះលោកបានពន្យល់មុនហ្នឹងថា គេចាប់លោក ហើយគេដាក់នៅក្នុងរណ្តៅនៅទីនោះ ហើយបន្ទាប់មកគេអនុញ្ញាតឲ្យលោកចេញក្រៅរណ្តៅនៅពេលថ្ងៃ ហើយគឺថានៅពេលថ្ងៃដែលគេឲ្យចេញមកនោះ ក៏លោកអត់ត្រូវបានគេដាក់ខ្នោះទេ?

**ឆ៖** ពេលដែលឲ្យខ្ញុំចេញថ្ងៃហ្នឹង មកបោសវាលថែទាំកន្លែង ហើយគេឲ្យធ្វើការពលកម្មហ្នឹង គេអត់ដោះខ្នោះទេ តែគេដាក់ច្រវាក់កជាប់ ។ ដល់យូរៗទៅបានគេលែង គេលែងដាក់ទាំងខ្នោះជើង លែងទាំងដាក់ច្រវាក់ក រួចគេឲ្យខ្ញុំទៅពោធិសាត់ទៅ ។

**ស៖** ថាលោកធ្វើការប្រភេទណាខ្លះ?

[១៣:៥៧:៣១]

**ឆ៖** ដល់ចេញមកហ្នឹង គេឲ្យធ្វើជីករណ្តៅគុកថែមទៀត ហើយគេឲ្យសែងឈើយកមកធ្វើត្រង់សេការពារកប៉ាល់ហោះ ទម្លាក់គ្រាប់បែក ហ្នឹងដែលធ្វើការនៅមន្ទីររាល់ថ្ងៃ ។

**ស៖** ថាគោលបំណងដែលគេជីករណ្តៅនោះ គេដើម្បីធ្វើអី? តើគេប្រើរណ្តៅសម្រាប់អ្វី?

**ឆ៖** ដែលជីករណ្តៅនោះ គឺជីករណ្តៅត្រង់សេការពារកប៉ាល់ហោះទម្លាប់ ហើយមួយចំណែកទៀតជីករណ្តៅគុកបន្ថែមតទៅទៀត ហ្នឹងដែលខ្ញុំចេញរួចមក គេលែងដាក់ខ្នោះដាក់អីហើយនោះ ។

**ស៖** ថាតើលោកឃើញគេ-- ឃើញ-- គឺលោកឃើញគេប្រើរណ្ដៅនេះសម្រាប់ដាក់អ្នកទោស ឬក៏ប្រើរណ្ដៅនេះសម្រាប់ធ្វើអីផ្សេងទៀត?

**ឆ៖** ឃើញតែធ្វើដាក់សម្រាប់អ្នកទោស ។ បាទ ជីករណ្ដៅហ្នឹងសម្រាប់អ្នកទោស ហើយនិងធ្វើត្រង់សេតែប៉ុណ្ណឹងទេ ។ ធ្វើត្រង់សេនេះ គឺសុទ្ធតែកាប់ឈើប៉ុនៗហ្នឹងមកយកមកច្រោះអ៊ីចឹង យកមកច្រោះ ត្រង់សេច្រោះការពារកប៉ាល់ហោះទម្លាក់ចំ ។

**ស៖** លោកបានពន្យល់យើងខ្ញុំមុនហ្នឹងថា លោកឃើញមនុស្សត្រូវបានគេចងទៅនឹងបង្គោល ហើយខ្ញុំយល់ឃើញថា មានបួននាក់ត្រូវបានគេចងទៅនឹងបង្គោលហ្នឹង ។ ថាតើត្រឹមត្រូវដែរឬទេ? ថាបុគ្គលបួននាក់ត្រូវបានគេចងនឹងបង្គោលហ្នឹង?

[១៤:០០:០៧]

**ឆ៖** ខ្ញុំឆ្លើយថា ធ្វើនេះ ធ្វើដោយមិនត្រឹមត្រូវ ធ្វើនេះឃោរឃៅជាទីបំផុត កាប់សម្លាប់គ្មានត្រាប្រណីជនជាតិខ្មែរដូចគ្នា ចាញ់សាសន៍គេដទៃផង គេស្រលាញ់ជាតិគេ ឯងជាខ្មែរទៅធ្វើបាបខ្មែរនោះហួសនិស្ស័យ លើសពីសត្វធាតុទៅទៀត នេះយោបល់របស់ខ្ញុំ មើលឃើញតែប៉ុណ្ណឹង ។

**ស៖** តើលោបញ្ជាក់ជូនខ្ញុំដែរឬទេ ថាមានមនុស្សបួននាក់ត្រូវបានគេចងនឹងបង្គោល?

**ឆ៖** ខ្ញុំបញ្ជាក់ថា គេចងនឹងបង្គោលហ្នឹងបួននាក់ ទាំងអស់វាប្រាំនាក់ គេបាញ់ម្នាក់នៅសល់បួន គេបាញ់អាបង្គោលកណ្ដាល គេបាញ់អាហ្នឹង គេចងអាកណ្ដាលហ្នឹង ឲ្យអាបួននាក់ខាង ពីរនាក់ខាងនេះ ពីរនាក់ហ្នឹងឲ្យមើលអាកណ្ដាលហ្នឹង ហ្នឹងខ្ញុំឃើញអ៊ីចឹង ។

ស៖ ថាតើបុគ្គលនេះត្រូវបានគេសម្លាប់យ៉ាងម៉េច? ថាតើគេបាញ់សម្លាប់គាត់ ហើយនរណាគេប្រើកាំភ្លើងសម្រាប់បាញ់គាត់ហ្នឹង?

**ឆ៖** អ្នកដែលបាញ់ហ្នឹង ឈ្មោះតា ចាន់ តាចាន់ហ្នឹង គាត់កើតឃ្លង់ គាត់អ្នកបាញ់ តែខ្ញុំឃើញតាចាន់ហ្នឹង ដែលបាញ់នៅកណ្ដាលមន្ទីរហ្នឹង ឃើញបាញ់ពីរដង ដែលធ្វើអ៊ីចឹង ធ្វើដូចខ្ញុំនិយាយអម្បាញ់មិញបាញ់ពីរដង ហ្នឹងខ្ញុំឃើញផ្ទាល់ភ្នែកតែម្ដង ។

**ស៖** ថាតើអ្នកដែលបាញ់គេហ្នឹង អាយុប៉ុន្មាន?

**ឆ៖** តាចាន់ ហ្នឹង ខ្ញុំឮលោក ឌុច ហ្នឹង ហៅគាត់បង បង ចាន់ៗ តែមិនដឹងគាត់អាយុប៉ុន្មានទេ ។

**ស៖** ថាតើបុគ្គលដែលបាញ់គេនោះ ជាក្មេង ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស់ហើយ ប្រហែជាអាយុពីជំនាន់ហ្នឹង ប្រហែល៣០ ឬ៤៥ឆ្នាំ អីទៅ ឡើងទៅលើ បើតាមស្មាន មនុស្សចាស់ហើយ គាត់មានកូនក្រមុំ កម្លោះហើយ ។

**ស៖** ថាតើគាត់បាញ់ត្រូវកន្លែងណា បាញ់ត្រូវលើជនរងគ្រោះហ្នឹងត្រង់កន្លែងណា?

**ឆ៖** បាញ់ចំក្បាល ។ ខ្ញុំជាអ្នកទោសហ្នឹង ដែលខ្ញុំដើរបោសហ្នឹង ខ្ញុំបានចូកប្រមូលឈាម ប្រមូលលលាដ៍ក្បាលអី យកទៅកប់ ។

**ស៖** ថាតើឌុចមាននៅទីនោះដែរឬទេ? ថាតើលោកឃើញគាត់ចេញបញ្ជាយ៉ាងម៉េចដែរឬទេ?

**ឆ៖** បាទ, អត់ឃើញទេ ។ ខ្ញុំអត់ឃើញតាឌុចទេ ឃើញតែតាចាន់ ចេញមកបាញ់តែម្តង តែដឹងតាឌុច គាត់នៅកន្លែងណា ខ្ញុំអត់ដឹងផង ។

**ស៖** លោកបានឃើញដែរឬទេ លោកឃើញអ្នកទោសផ្សេងៗ ត្រូវបានឲ្យរងអំពើហឹង្សាណាមួយដែរឬទេ? តើលោកបានឃើញអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ, បានឃើញ គេវាយនឹងត្បូងចប វាយដំបងគល់ខ្ចីហ្នឹង ខ្ញុំបាទបានឃើញ ។ ហើយគេបានយកខ្ញុំហ្នឹង ជាអ្នកដែលគេឲ្យដើរបោសវាលហ្នឹង គេឲ្យខ្ញុំនឹងទៅជីករណ្តៅឲ្យគេៗទៀត។ ហើយខ្ញុំខ្លាចគេ គេប្រើទៅខ្ញុំទៅជីកឲ្យគេហើយគេវាយសម្លាប់ចោល កប់ហ្នឹងទៅ ។

[១៤:០៥:១៩]

**ស៖** ដូច្នេះលោកបានឃើញអ្នកទោសត្រូវបានគេវាយ តើគេវាយអ្នកទោសដោយប្រើអ្វី?

**ឆ៖** វាយ នឹងដំបងគល់ឫស្សី ហើយនឹងត្បូងចប ។

**ស៖** លោកអាចនិយាយម្តងទៀតបាន ឬទេ? សូមលោករៀបរាប់ថា គេប្រើអ្វី ដើម្បីវាយអ្នកទោស? ខ្ញុំឮថាដំបង ហើយនិង ចប? តើមែនដែរ ឬទេ?

**ឆ៖** បាទ វាយនឹងត្បូងចប ចបកាប់យើងហ្នឹង ។ វាយមែន ខ្ញុំឃើញច្បាស់ណាស់ ព្រោះខ្ញុំជាអ្នកទៅជីករណ្តៅឲ្យគេទៀត ព្រោះគេហៅខ្ញុំទៅអាកងការពារគុកហ្នឹងហៅខ្ញុំទៅ ។ ខ្ញុំនៅកំពុងបោសវាលៗ នៅមន្ទីរហ្នឹង គេហៅខ្ញុំទៅឲ្យទៅជីករណ្តៅហ្នឹង ។ ឃ្លាតពីមន្ទីរប្រហែលតែកប់ខ្មោចហ្នឹង វាចង់ក្បែរដើមមន្ទីរ ។ ជួនកាលថ្ងៃណាមួយហ្នឹង-- ជួនកាលឃើញឆ្កែពាំឆ្អឹង ពាំលលាដ៍ក្បាលមកដល់ចង្ក្រានបាយហ្នឹង ។ កាលខ្ញុំបោសវាលហ្នឹង ខ្ញុំបានឃើញច្បាស់ណាស់ឆ្កែពាំមកខ្មោច ដែលកប់វាចោលជុំវិញមន្ទីរអស់ហើយ។ រួចប្រើតែអ្នកទោសដូចគ្នាហ្នឹង ។ គ្រាន់តែមុខខ្ញុំម្នាក់ហ្នឹង ខ្ញុំថាស្មានយ៉ាងតិចក៏ទៅពីរយ ទៅបីរយនាក់ដែរ គ្រាន់តែគេប្រើខ្ញុំឲ្យយកខ្មោចគ្នាឯងងាប់ៗពីក្នុង-- មួយថ្ងៃៗកប់រាល់តែថ្ងៃ ។

**ស៖** លោកបានឃើញមានប្រភេទនៃអំពើកំរោលផ្សេងទៀតបានអនុវត្តដែរ ឬទេ? ជាពិសេស លោក បានឃើញគេយកអ្នកទោសជ្រមុជចូលទឹកដែរ ឬទេ?

**ឆ៖** បាទ, ឃើញ ។ គេចាប់អ្នកទោសនោះទៅ គេចងដៃចងជើង ហើយគេជ្រមុជក្នុងទឹកត្រពាំងច្រាប ជ្រមុជហើយគេលើកយកមកសួរចម្លើយ តែខ្ញុំគ្រាន់តែក្រឡេកឃើញ ខ្ញុំខ្លាចខ្ញុំពេក ខ្ញុំគេចចេញមក ខ្ញុំអត់ប៊ានទៅជិតទេ ខ្ញុំដើរចេញមក អត់ប៊ានមើលគេទេ ។ ឃើញតែគេធ្វើបាបអ៊ីចឹង ។

**ស៖** ថា ឌុច ជាជនជាប់ចោទនុ៎ង គាត់នៅកន្លែងដែលអ្នកទោសត្រូវបានគេជ្រមុជ ទឹក តើឌុចនៅ ឬក៏អត់? ហើយនៅពេលដែលគេសួរចម្លើយតើ ឌុច មាននៅកន្លែងនោះ ឬអត់?

[១៤:០៨:៥០]

**ឆ៖** អត់ៗមានទេ ។ មានតែអ្នកដែលទៅសួរចម្លើយហ្នឹងឈ្មោះ មាស ដែលអ្នកធ្វើបាបផ្ទាល់ដៃហ្នឹង ខ្ញុំស្គាល់ច្បាស់ណាស់ឈ្មោះ មាស ដែលនៅជាប់ជាមួយ តាឌុច ហ្នឹង ។ តែ តាឌុច អត់ដែលចេញទេ គាត់នៅតែក្នុងមន្ទីរទេ ។

**ស៖** ថាតើលោកធ្លាប់ឃើញ ឌុច ចូលរួមឬក៏មានវត្តមានដែរឬទេ នៅពេលដែលមានអំពើកំរោល? តើលោកធ្លាប់ឃើញ ឌុច វាយមនុស្ស ឬក៏ទាត់មនុស្សអីដែរឬទេ?

**ឆ៖** បាទ ឃើញ ។ ខ្ញុំមានឃើញ ថ្ងៃមួយខ្ញុំឃើញវាយមនុស្សស្រីម្នាក់ វាយនឹងរំពាត់ប៉ុនៗមេដៃទេ តែវាយមួយសន្ទុះ បានអាកងកុមារដែលតូចៗដែលនៅក្នុងមន្ទីរហ្នឹង វាមកវាយជំនួសវិញ ។ ពេលវាយមនុស្សប្រកាច់ទៅ ខ្ញុំឃើញតា ឌុច ទះកំប៉េះគូទគាត់ហើយៗ គាត់ស្រែកប៉ោ ហើយគាត់សើចក្អាកក្អាយ ហើយគាត់ទះកំប៉េះគូទគាត់ ដែលឃើញមនុស្សកំពុងប្រកាច់ៗនៅដី ។

**ស៖** ដូច្នេះ ឌុច គឺគាត់សើចសប្បាយនៅពេលដែលគាត់ឃើញស្ត្រីនោះកំពុងតែដួលប្រកាច់នៅលើដី។ លោកយល់សំណួរដែរឬទេ? ថា ឌុច ហ្នឹង គាត់សើចនៅពេលដែលគាត់ហ្នឹងឃើញស្ត្រីនោះកំពុងតែរងនូវការឈឺចាប់ ។ តើ ឌុច សើចដែរឬទេ? នៅពេលដែលស្ត្រីនោះគាត់ទទួលការឈឺចាប់នោះ តើ ឌុច មានសើចដែរឬទេ? (អនុញ្ញាតលោកចៅក្រមប្រហែលជាគាត់ស្តាប់អត់ឮ ឧបករណ៍គាត់អស់ថ្មឬក៏យ៉ាងម៉េច? ស្នើសុំអនុញ្ញាតពីលោកចៅក្រម ។)

**ឆ៖** ឌុច គាត់ៗសើចពិតប្រាកដ ។

**ស៖** លោកបាននិយាយមកយើងខ្ញុំអំពីអ្នកខ្លះគាត់ស្លាប់ ហើយលោកនិយាយអំពីសាកសព ។ ថាតើលោកបានចូលរួមក្នុងការកប់សាកសពដែរឬទេ? នៅកន្លែងដែលសាកសពនោះ វានៅក្នុងរណ្តៅ

ផ្សេងៗនោះ?

**ឆ៖** បាទ ខ្ញុំដែលចូលរួមហ្នឹង ដែលខ្មោចងាប់ក្នុងមួយថ្ងៃៗ ដូចខ្ញុំនិយាយខាងដើមអ៊ីចឹង ។ តែពេលណាគេប្រើខ្ញុំហ្នឹងបានខ្ញុំទៅ ប៉ុន្តែខ្ញុំទៅកាប់ហ្នឹងខ្ញុំខ្សោយណាស់កម្លាំងមានតែស្បែកហើយ និងឆ្អឹង ហើយជីរណ្តៅក៏មិនបានជ្រៅដែរ ជីកបានរាក់ៗគ្រាន់តែលិបៗ ដូចខ្ញុំមានប្រសាសន៍ខាងដើម អ៊ីចឹង ចាកប់យូរៗទៅឲ្យអ្នកទោសដូចគ្នាទៅកប់អ៊ីចឹង វាអត់មានកម្លាំង ខ្មោចហ្នឹងវាស្អុយពេញហ្នឹង ហើយឆ្កែវាពាំឆ្អឹងពាំអីទៅដល់កន្លែងមន្ទីរហ្នឹង ឃើញពិតប្រាកដណាស់ គឺអត់មាននិយាយ ដោយមុសា ឬក៏មិនបានឃើញហើយចេះតែនិយាយទេ គឺនិយាយការពិតដោយយុត្តិធម៌ ។

[១៤:១៣:៤២]

**ស៖** តើលោកបានឃើញផ្ទាល់ភ្នែកដែរឬទេ ថាមានគេសម្លាប់មនុស្ស? មនុស្សត្រូវបានគេសម្លាប់មនុស្ស? តើលោកបានឃើញផ្ទាល់ភ្នែកដែរឬទេ?

**ឆ៖** បាន បានឃើញ ។ បានឃើញថ្ងៃមួយហ្នឹង ចងមនុស្សស្រីមួយ មនុស្សប្រុសមួយចងខ្សែច្រវាក់កជាមួយគ្នាហ្នឹង ហើយដែលខ្ញុំនិយាយប្រាប់ថា រណ្តៅដែលប្រើខ្ញុំបាទឲ្យទៅជីក ។ ដល់ពេលជីកហើយ គេយកទៅដាក់រណ្តៅនោះគេវាយអាប្រុសមុន វាយអាប្រុសមុនវាយមួយត្បូងចបផ្ទង ធ្លាក់ប្រុសទៅនៅ សល់ស្រីម្នាក់រាងខ្មៅស្រអែមធាត់វាយនោះវាយៗមិនងាយងាប់គ្រាន់តែសន្លប់គេរុញទម្លាក់ក្នុងរណ្តៅគេកប់បាត់ទៅ តែគ្នានៅដកដង្ហើមតឹកៗនៅឡើយមិនទាន់ដាច់ខ្យល់ទេ ។ ហើយគេអ្នកដែលសន្លប់-- អ្នកដៃដល់លុបខ្លួនគេបាត់ទៅ ។

**ស៖** ថាតើលោកដឹងហើយស្គាល់ស្ត្រីនោះ តើស្ត្រីនោះជានរណា?

**ឆ៖** ស្ត្រីៗនោះនៅភូមិគោក ឈ្មោះ សយៗ ស្ត្រីហ្នឹងនៅភូមិគោក ដែលគេធ្វើបាបហ្នឹង ។ ហើយដែលស្ត្រីដែលគេវាយសន្លប់នោះ ខ្ញុំអត់ស្គាល់ដែរមិនដឹងគេនៅស្រុកណាទេ ។ តែគ្រាន់តែឮថ្ងៃមួយខ្ញុំឮ តាឌុច គាត់និយាយ គាត់សួរស្ត្រីហ្នឹងជិតខ្ញុំ ខ្ញុំនៅក្បែរហ្នឹង ។ គាត់សួរថា ហាងឯងកូននរណាគេ? សួរមីហ្នឹង មីហ្នឹងថា ឪពុកខ្ញុំឈ្មោះ វង្ស ។ តាឌុច គាត់ថា អើអញស្គាល់ហើយអ្វែងនោះ ។ កូនមុនីវង្សអី? អញអត់សម្លាប់ស្តេចទេវើយ អញសម្លាប់តែខ្មាំងទេ ។ ខ្ញុំឮគាត់និយាយច្បាស់ ។

**ស៖** តើនរណាគេទទួលខុសត្រូវក្នុងការសម្លាប់? ថាតើវាជាតួនាទីរបស់អ្នកយាម ហើយអ្នកយាមហ្នឹង គាត់មានអាយុប៉ុន្មាន ដែលអ្នកយាមការទទួលខុសត្រូវការសម្លាប់នោះមានអាយុប៉ុន្មានដែរ?

**ឆ៖** អ្នកយាមដែលទៅសម្លាប់មនុស្សដែលធ្វើទារុណកម្មហ្នឹងក្មេងៗអាយុប្រហែល ខ្ទង់២០ ឬ

១៧, ១៨ឆ្នាំប៉ុណ្ណោះទេ ក្មេង ។

**ស៖** ១៧ ទៅ ២០ឆ្នាំ ហើយអ្នកទាំងអស់នោះជាក្មេងៗនៅពេលដែលនិយាយអាយុ១៧ ទៅ ២០ឆ្នាំ ឬក៏គាត់ជាមនុស្សជំទង់ហើយ?

**ឆ៖** បាទ ជាមនុស្សជំទង់ហើយ ។ មនុស្សវាពេញប្រើហើយអាយុ១៨ ទៅ២០ ហ្នឹងវាធំហើយ មនុស្សពេញវ័យហើយ ។

[១៤:១៧:៣៣]

**ស៖** ក្នុងចំណោមអ្នកយាមថា តើលោកមានឃើញអ្នកយាមជាក្មេងដែរឬទេ?

**ឆ៖** មានក្មេងៗតូចៗប្រហែលអាយុ១១ឆ្នាំ មានត្រឹមប្អូនទៅដប់នាក់ដែរនៅក្នុងហ្នឹង នៅក្នុងមន្ទីរហ្នឹង ។ ខ្ញុំគ្រាន់តែវាអត់ចាំឈ្មោះអស់ទេ មិនដឹងកូនចៅអ្នកណាផង ។

**ស៖** ថាតើកូនក្មេងទាំងអស់នោះចូលរួមក្នុងការសួរចម្លើយដែរឬទេ? ហើយគេរំពឹងថាកូនក្មេងទាំងអស់នោះប្រព្រឹត្តអំពើកំរោលដែរឬទេ? ហើយកូនក្មេងទាំងអស់នោះ បានចូលរួមក្នុងការសម្លាប់ដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលឃើញវាសម្លាប់ទេ ដែលឃើញតែវាវាយ វាតប់អ្នកទោសហ្នឹងឃើញវាធ្វើតាមចិត្តវា វាវាយ វាតប់ វាធាក់ វាជេរ វាប្រមាថ គ្រប់បែបយ៉ាងគ្រាន់តែឃើញតែប៉ុណ្ណឹងទេ គ្រាន់តែថាឲ្យឃើញ វាទៅសម្លាប់ ខ្ញុំអត់ដែលឃើញទេ ។

**ស៖** ហើយទាក់ទងទៅនឹងអំពើកំរោល លោកចាំដែរឬទេ? លោកចាំថា លោក បានឃើញមានដង្កាប់ និងម្ជុលដែរ ឬទេដែលគេប្រើ?

**ឆ៖** បាទ, ឃើញៗមានដង្កាប់ចាប់ក្រចកៗ ហើយម្ជុលចាក់ដើម-- គល់ក្រចក ។ ខ្ញុំក្រឡេកឃើញតែអ្នកដែលរងគ្រោះនោះស្រែកអាយោអាយ៉ា ដែលគេចាប់អ៊ីចឹង ធ្វើបាបអ៊ីចឹង ហើយខ្ញុំក៏អត់ប៉ានឈរមើលទេ ខ្ញុំគេចបាត់ទៅៗ ។

[១៤:២០:០០]

**ស៖** ដូច្នេះ លោកឃើញដង្កាប់ លោកឃើញគេដកក្រចកអ្នកទោសចេញដែរឬទេ?

**ឆ៖** ខ្ញុំគ្រាន់តែឃើញចាប់ ហើយស្រែក ហើយម្ជុលចាក់ តែត្រង់ដកមិនដក ខ្ញុំអត់បាននៅមើល អត់ប៉ាននៅមើល ខ្ញុំគេចបាត់ទៅ ខ្ញុំមិនប៉ាននៅឈរមើល ខ្លាចខ្លួនឯងគេថាឯងយកការណ៍យកអីចេះតែខ្លាចគេហើយជំនាន់ហ្នឹង ខ្លាចណាស់ ខ្លាចមែនទែន ។

**ស៖** ថាតើលោកមានទំនាក់ទំនងជាមួយនឹង ឌុច យ៉ាងម៉េច ដែលគាត់ជាប្រធាន ម-១៣ ហ្នឹង?

**ឆ៖** បាទ, ខ្ញុំបាទហ្នឹង អត់មានប៉ានទាក់ទងអីអ្វី ជាមួយគាត់ទេ ព្រោះខ្ញុំខ្លាចគាត់ណាស់ ។ មិននឹងប៉ានមើលមុខចំផង ខ្លាច តែបើគាត់ហៅប្រើអីទៅទៅៗធ្វើ ។ ហៅអីតែថ្ងៃមួយគាត់ថា អ៊ីចេះ ឲ្យខ្ញុំ ដែលពេលខ្ញុំរួចពីគាត់ឈប់ដាក់គុកហើយ គាត់ឈបដាក់ខ្នោះជើងហើយ ហើយគាត់ហៅខ្ញុំទៅថា ន៎ែ បើបង ស៊ន ឯង ធ្វើកងការពារគុកជាមួយខ្ញុំហើយមិនបាច់ទៅផ្ទះទេ ។ រួចក៏ដល់ពេលព្រឹកឡើង ក៏គាត់ប្រាប់ថា ឥឡូវបងឯងមិនបាច់នៅហ្នឹងទេ កុំជិតអាពួកនរកពួកប្រេតអស់ហ្នឹង ឥឡូវបងឯងទៅ ធ្វើស្រែទៅ ។ ហើយក៏គាត់បញ្ជូនខ្ញុំទៅស្រែបាត់ទៅ ។ ហើយខ្ញុំក៏លែងបានដឹងដំណឹងអីដែរ ដល់រួច ធ្វើស្រែហើយអីហើយ បានចូលដល់ខែកត្តិក បានគាត់ហៅខ្ញុំមកខ្ញុំ ឲ្យខ្ញុំទៅពោធិសាត់ ខ្ញុំឡើងឡានពីវត្ត កន្សែងសំទៅ ទៅពោធិសាត់បាត់ទៅ រហូតទល់១៩៧៩ បានខ្ញុំបានមកស្រុកវិញ ។ កូនប្រពន្ធខ្ញុំហ្នឹងថា ខ្ញុំហ្នឹងស្លាប់បាត់ហើយ អត់នរណាមួយដឹងថាខ្ញុំនៅរស់ទេ ទល់តែដល់ខ្ញុំ១៩៧៩ បានខ្ញុំមកដល់ផ្ទះ បានគេដឹងថា ខ្ញុំនៅរស់ ។

**ស៖** លោកខ្លាចខ្លាំងណាស់ លោកខ្លាច ឌុច ខ្លាំងណាស់ ថាតើលោកនៅថ្ងៃនេះ លោកនៅខ្លាច ឌុច ទៀតដែរឬទេ?

**ឆ៖** បាទ, ខ្ញុំបាទមកថ្ងៃនេះ ខ្ញុំលែងខ្លាចហើយ ព្រោះខ្លាអស់ចង្កូមហើយ ។

[១៤:២៣:១៦]

**ស៖** ថា ឌុច ហ្នឹងធ្លាប់លោកប្រាប់លោកនៅថ្ងៃណាមួយដែរឬទេ ថាតើមានអ្វីកើតឡើងក្រោយ ពេលបញ្ចប់ម-១៣ តើគាត់មានដែលធ្លាប់ប្រាប់លោកដែរឬទេ?

**ឆ៖** គាត់ដែលនិយាយថា អ៊ីចេះ ម្តង គាត់ថា ពីដំបូង គាត់និយាយថា បងឯង ដល់ពេលចប់ ទៅ ទៅភ្នំពេញជាមួយខ្ញុំ តែគាត់គ្រាន់តែនិយាយទេ គាត់មិនអនុវត្តទេ តែដល់ពេលរួចទៅ ដល់ឆ្នាំ ១៩៧៤ ហ្នឹងក៏គាត់បញ្ជូនខ្ញុំទៅពោធិសាត់ហើយ អាហ្នឹង ដូចថា ខ្ញុំនិយាយដដែលៗ ព្រោះវារឿងរ៉ាវ វាមានតែប៉ុណ្ណឹង វាអត់មានអីតទៅទៀត ។

**ស៖** ថាតើលោកចាំច្បាស់នូវអ្វី ដែលគាត់និយាយជាមួយលោកដែរ នៅពេលដែលគាត់និយាយ ថា យកលោកទៅភ្នំពេញ តើលោកចាំដែរឬទេ ថាគាត់និយាយអីខ្លះ?

**ឆ៖** គាត់បាននិយាយតែប៉ុណ្ណឹងឯង និយាយតែប៉ុណ្ណឹងម៉ាត់ និយាយថា ពេលវាយខ្មាំងចប់ បង ឯងទៅភ្នំពេញជាមួយខ្ញុំ ។ គាត់និយាយបានតែប៉ុណ្ណឹងៗ ក៏ហើយបាត់ទៅទេ អត់មាននិយាយអីតវែង

ឆ្ងាយទៅទៀត អត់ ។

**ស៖** នៅពេលលោកឮ នៅពេលដែលលោកត្រូវបានសួរយកចម្លើយ ដោយចៅក្រមរបស់តុលាការ គឺឯកសារ D-៧៨ គឺលេខ ERN ដូចដែល គឺនៅទំព័រទី៣ លោក បាននិយាយដូចខាងក្រោមនេះ៖

នៅពេលមួយនោះ ឌុច បាននិយាយថា បង ស៊ន នៅពេលដែលយើងគ្រប់គ្រងភ្នំពេញ បងនឹងយកមកធ្វើជាមេគុកជាមួយខ្ញុំនៅភ្នំពេញ តើលោកនៅចាំអ្វីដែលគាត់និយាយដែរឬទេ?

**ឆ៖** គាត់និយាយ គ្រាន់តែថា បបួលខ្ញុំមកភ្នំពេញជាមួយខ្ញុំ ទាល់តែថាឲ្យយកខ្ញុំហ្នឹងទៅធ្វើមេគុកវាអត់ទេ គាត់គ្រាន់តែនិយាយថា បងឯង ដល់ពេលវាយភ្នំពេញបែកចប់ហើយ បងឯងទៅជាមួយខ្ញុំទៅភ្នំពេញ គាត់គ្រាន់តែនិយាយតែប៉ុណ្ណឹង ក៏អត់មានឮអីតទៅទៀត ។

[១៤:២៦:២៣]

**ស៖** តើ ឌុច មានកាន់កាំភ្លើងដែរឬទេ?

**ឆ៖** តាឌុច កាំភ្លើងគាត់មាន មានអាកាំភ្លើងខ្លីមួយដើម ។ តែពេលគាត់ចេញទៅក្រៅបានឃើញគាត់ដាក់ បើថា គាត់នៅក្នុងមន្ទីរ ដូចមិនដែលឃើញគាត់កាន់កន្ទីសកន្ទាសទេ គាត់ទុកនៅកន្លែងគាត់ ។ តែដល់ខ្ញុំបានឃើញ បើគាត់ចេញដើរទៅក្រៅ ទៅអី ក្រៅពីមន្ទីរអីហ្នឹង គាត់កាន់ គាត់ទៅភូមិ ទៅអីហ្នឹងអាហ្នឹង គាត់កាន់កាំភ្លើង ។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ នរណាគេជាអនុប្រធានឬក៏ជាអ្នកជួយ ឬក៏ជាជំនួយរបស់ ឌុច?

**ឆ៖** ជាជំនួយរបស់ ឌុច ហ្នឹងមាន តា ចាន់ ហើយ មាស ហើយ ប៊ុន ហ្នឹង ដែលខ្ញុំបានស្គាល់ ហើយខុសពីហ្នឹង ខ្ញុំអត់ស្គាល់ទេ ទាល់តែជាប់ៗ ជាមួយគ្នាដើរនៅធ្វើជាមួយតា ឌុច ដែលជាប់នោះមានមិត្ត មាស តា ចាន់ តាប៊ុន ។ អាហ្នឹងឃើញ ដែលខ្ញុំបានឃើញ តែប៉ុណ្ណឹងនាក់ទេ ដល់ខុសពីហ្នឹងទៅមានតែកងការពារគុក ខ្ញុំស្គាល់មិនអស់ ដែរ ។

**ស៖** ថាតើលោកបានឮនរណាម្នាក់និយាយអំពី បុគ្គលឈ្មោះ ផល ដែរទេ?

**ឆ៖** ខ្ញុំបាទអត់ដឹងដែរ ។ អត់ដែលឮនរណានិយាយពី ផល ហ្នឹងផង ។

**ស៖** ថាតើមានចំណុចផ្សេងដែលសំខាន់ លោកចង់ជម្រាបជូនតុលាការដែរឬទេ ដែលលោកចង់និយាយអំពីបញ្ហា ដែលលោកបានរស់រានឆ្លងកាត់កន្លែងហ្នឹង?

**ឆ៖** ខ្ញុំបាទ គឺបានតុលាការរកខុសត្រូវ រកយុត្តិធម៌ឲ្យប្រជារាស្ត្រកម្ពុជា ដើម្បីវែកមុខអំពើឃាតកម្មអស់រយៈបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃនេះ ឃើញថា ខ្ញុំមានចិត្តត្រេកអរជាទីគាប់ចិត្ត ជាទីពេញចិត្ត រកអ្វីមកប្រៀបស្មើមិនបានទេ ដើម្បីរកយុត្តិធម៌ឲ្យប្រជារាស្ត្រខ្មែរ ដែលបានរួចពីគ្រោះកាចមហន្តរាយនេះ ដែលនៅក្នុងសង្គមប៉ុលពតនេះ គឺថាគ្មានមនុស្ស ជាតិណា ដែលលំបាកស្មើនឹងសម័យសង្គមប៉ុលពតកាន់កាប់នោះទេ ។ សូមអស់ សូមបញ្ចប់ ។

[១៤:៣០:១៨]

**សួរដោយចៅក្រម ហ្សង់ម៉ាកឡាវែន៍៖**

លោកប្រធាន ខ្ញុំអត់មានសំណួរ សួរសាក្សីបន្ថែមទៀតទេ ប៉ុន្តែខ្ញុំចង់ធ្វើការសួរចម្លើយជនជាប់ចោទ តើលោកប្រធានអនុញ្ញាតដែរឬទេ?

**ស៖** ឌុច លោកបានឮអំពីចម្លើយរបស់សាក្សី ដូច្នេះ ជាបឋមខ្ញុំសូមស្តាប់ការសង្កេតរបស់លោកទាក់ទងនឹងអ្វីដែលលោកបានឮ ។

**ជនជាប់ចោទ៖**

**ឆ៖** ការសង្កេតរបស់ខ្ញុំជាបឋម ពីលើសាក្សីរូបនេះ ខ្ញុំសូមបញ្ជាក់ថា ថ្វីត្បិតតែខ្ញុំមិនស្គាល់ពីមុនមកឥឡូវនេះ ទើបតែនឹងឃើញមុខ ស្តាប់ឮ សក្ខីកម្មរបស់គេ គេពិតជាមានទុក្ខវេទនា គេមានទុក្ខវេទនានៅម-១៣ នេះយូរពិតមែន នេះខ្ញុំសូមទទួលស្គាល់មុនទៅពោធិសាត់ ។

ការសង្កេតរបស់ខ្ញុំទីពីរ គឺសក្ខីភាពរបស់គេជាមូលដ្ឋាននោះ គឺត្រឹមត្រូវជាមូលដ្ឋាន មានរឿងខ្វះចន្លោះតែបន្តិចបន្តួចទេ ។

**ស៖** ឌុច ដូច្នេះ ជាបញ្ហាចម្បង លោកមិនធ្វើការតវ៉ាទៅលើខ្លឹមសារនៃសក្ខីកម្ម របស់សាក្សីនោះទេ ហើយលោកបានលើកឡើងថា ប្រហែលមានចំណុចមួយចំនួននៅ មានចន្លោះថាតើចន្លោះដែលនៅខ្វះនោះវាមានអ្វីខ្លះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ការបកប្រែនោះមិនសូវត្រូវទេ ។ ពាក្យខ្មែរដែលគេថា មានការខ្វះចន្លោះនោះបានន័យថា មិនត្រឹមត្រូវ នេះពាក្យដែលខ្ញុំប្រើ ។ បានន័យថា មិនត្រឹមត្រូវ ពាក្យដែលខ្ញុំនិយាយថាខ្វះចន្លោះបានន័យថា មិនត្រឹមត្រូវ ។

**ស៖** ថាតើភាពខុស និងចន្លោះនោះ នៅកន្លែងណាខ្លះ?

**ឆ៖** ជាក់ស្តែងពីរឿងចំនួននោះ ដែលគាត់និយាយទៅវាលើស ។

[១៤:៣៥:០០]

**ស៖** សាក្សី បាននិយាយជាក់លាក់ លោកបានវ៉ៃស្ត្រីម្នាក់ ហើយលោកវ៉ៃគាត់ ពីក្រោយ ហើយលោកបានសើចនៅពេលដែលស្ត្រីនោះគាត់ដួលនៅលើដី ។

**ឆ៖** ខ្ញុំសួរចម្លើយស្រី មិនដែលសួរឲ្យអ្នកទោសណាឃើញទេ ។ ហើយទីពីរ ខ្ញុំមិនដែលវ៉ៃស្រីទេ ដូច-- ។ ហើយទីបី ខ្ញុំវ៉ៃហើយមិនដែលអ្នកណាមកជួយវ៉ៃខ្ញុំទៀតទេ ។ ហើយទីបី និយាយពីថាខ្ញុំទះគូទហ្នឹង សូមបញ្ជាក់តាមពាក្យខ្មែរដែល បងស៊ន គាត់និយាយនេះ ទះគូទខ្ញុំ ។ ខ្ញុំអស់ហើយខ្ញុំទះគូទខ្លួនឯង មិនមែនទះគូទស្រីហ្នឹងទេ ។

**សួរដោយចៅក្រម ហ្សង់ម៉ាកឡាវែន៖**

ថាតើសាក្សីអាចបញ្ជាក់លើកមុន-- អម្បាញ់មិញដែលលោកបានលើកឡើងថា គាត់វ៉ៃស្ត្រីហើយជាពិសេសនោះ គឺ ឌុច សើច នៅពេលដែលគាត់ឃើញស្ត្រីនោះដេកនៅលើដី ហើយឈឺចាប់ ។

**សាក្សី KW-30 ៖**

បាទ, ឃើញពិត។ ដល់គាត់ស្រវារំពាត់វ៉ៃ បានប្រហែលតែពីរ-បីរំពាត់ ក្មេងហ្នឹង-- អ្នកដែលនៅក្នុងមន្ទីរហ្នឹង វ៉ៃៗហ្នឹង វ៉ៃហ្នឹង វ៉ៃនៅក្រោមដើមចំបក់ កណ្តាលវាលហ្នឹង មុននៅក្នុងមន្ទីរហ្នឹង ។ វ៉ៃហើយគាត់មិនមែន-- ខ្ញុំមិនមែនថា ឲ្យគាត់ទៅទះកំប៉េះគូទអ្នករងគ្រោះ គាត់ទះកំប៉េះគូទខ្លួនគាត់ហ្នឹង គាត់កំប៉េះគូទខ្លួនគាត់ហើយគាត់សើច ។ អស់យោបល់ ។

**ស៖** តើលោកនិយាយយ៉ាងម៉េច ទាក់ទងទៅនឹងសាក្សីដែលបាននិយាយអំពីនៅពេលដែលការងើបមកវិញរបស់អ្នកទោស ពេលដែលគេបោះចូលទឹក អ្នកទោសចូលទឹក?

**ជនជាប់ចោទ៖**

**ឆ៖** ស្អុយទឹកនែ៎ រមាស់ តែនេះទៅវមាស់ ។ ទីពីរ អាត្រពាំងច្រាបហ្នឹង យើងខ្ញុំប្រើសម្រាប់ស្រោចត្រប់ ដាំត្រប់ ស្រីៗ នៅដាំត្រប់នៅកន្លែងហ្នឹង ។

ដូច្នេះ គ្មានអ្នកណាយកអ្នកទោសទៅជ្រមុជទឹកត្រពាំងច្រាប ឲ្យអ្នកផ្សេងទៀតឃើញនោះទេ ។ ទារុណកម្មមិនដែលឲ្យអ្នកទោសគ្នាឯងឃើញទេ ។

**ស៖** ខ្ញុំសួរសាក្សីម្តងទៀត តើលោកបញ្ជាក់បានដែរឬទេ ថាលោកឃើញអ្នកទោសហើយដំបូងគេជ្រមុជអ្នកទោសចូលទៅក្នុងទឹកត្រពាំងហ្នឹង?

**សាក្សី KW-30 ៖**

ខ្ញុំបាទឃើញពិត មិនមែននិយាយភរទេ ។ តែមិនមែនតា ឌុច ទេដែលទៅជ្រមុជនោះ ។ មិនស្រួលតាឌុច ហ្នឹង គាត់មិនដឹងផងទេមិនដឹង ។ គាត់នៅក្នុងមន្ទីរឯណោះ អាអ្នកធ្វើបាបនៅខាងក្រៅឯនេះ ។ អាពួកអ្នកន៎ែ អ្នកដែលជ្រមុជទឹកហ្នឹងឈ្មោះ មាស ខ្ញុំស្គាល់ទាំងឈ្មោះមនុស្សហ្នឹងទៀត ។

[១៤:៤០:១០]

**ស៖** ថាតើគឺលោកតាមដានទៅលើការសួរចម្លើយ ថាដឹងថាគេប្រើរបៀបណាខ្លះក្នុងការសួរចម្លើយ?

**ជនជាប់ចោទ៖**

**ឆ៖** ការសួរចម្លើយបែកខ្វែកគ្នាទៅតាមគុម្ពោតព្រៃ ម្នាក់មើលម្នាក់មិនឃើញទេ។

**ស៖** លោកជឿទេថា បុគ្គលិកក្រោមបង្គាប់របស់លោកអាចសម្រេចចិត្តដោយខ្លួនឯងក្នុងការប្រើប្រាស់វិធីធ្វើទារុណកម្ម ដែលរៀបរាប់ដោយសាក្សី ដើម្បីសួរចម្លើយអ្នកទោសដែលលោកមិនបានដឹងទៅលើបញ្ហាហ្នឹង ។

**ឆ៖** ខ្ញុំមិន-- ខ្ញុំមិនជឿថា មាស ធ្វើដល់ប៉ុណ្ណឹង ព្រោះអាកន្លែងត្រពាំងច្រាបនេះមានមនុស្សនៅម្ខាងនេះពេញ ធ្វើអីក៏គេមើលឃើញដែរ អ្នកទោសមើលឃើញ ។

**ស៖** សំណួរមួយទៀត លោកឮសាក្សីរៀបរាប់អំពីការប្រើប្រាស់ដង្កាប់ដើម្បីដកក្រចក ហើយនិងម្ជុលដែលត្រូវបានគេចាក់នៅលើក្រចក តើលោកនិយាយយ៉ាងម៉េចចំពោះបញ្ហានេះ?

**ឆ៖** ខ្ញុំនៅតែប្រកាន់នៅតែប្រកាន់សេចក្តីប្រកាសរបស់ខ្ញុំពីមុន គ្មាន*ប៉ុង* គ្មានដង្កាប់ គ្មានម្ជុលដកក្រចកទេ ។

[១៤:៤២:២២]

**ស៖** សំណួរមួយទៀត លោកឮសាក្សីរៀបរាប់អំពីកន្លែង ឬក៏ព្រឹត្តិការណ៍-- កន្លែង ដែលគេត្រូវគេសម្លាប់ កន្លែងសម្លាប់ដែលមានអ្នកទោសបួន ប្រាំនាក់ត្រូវបានគេចងទៅនឹងបង្គោល ។ ហើយអ្នកយាមបាញ់អ្នកទោសម្នាក់ ដែលចងនៅបង្គោល ។ ហើយអ្នកទោសផ្សេងទៀតនៅឈរក្បែរ ចងក្បែរហ្នឹង ។ តើលោកនិយាយយ៉ាងម៉េច?

**ឆ៖** ពីរឿងនេះច្បាស់លាស់ហើយ ដូចដែលបង ស៊ិន រាយការណ៍ជូនជាសាក្សី-- សក្ខកម្មអ៊ីចឹង ។ ហើយខ្ញុំក៏បានជម្រាបលោកចៅក្រមពីរឿងហ្នឹងដែរ ពីរឿងខ្ញុំចាត់តាំងមិត្តម្នាក់ឲ្យបាញ់ ។

**ស៖** លោកឮទេ លោកត្រូវតែរងចាំពេលដែលលោកឆ្លើយតបទៅនឹងសំណួរ ។

**ឆ៖** រឿងបាញ់អ្នកទោសម្នាក់ឱ្យអ្នកទោសផ្សេងទៀតឃើញ ដែល បងស៊ិន ធ្វើសក្ខីកម្មជារឿងពិត ខ្ញុំក៏បានរាយការណ៍ជូនលោកចៅក្រមពីម្សិលមិញហើយ ពីម្សិលមិញ ឬម្សិលថ្ងៃហើយ ។

**ស៖** លោកបានឃើញកន្លែងដែលសាក្សី គាត់បានលើកឡើង គឺមានឆ្កែបានពាំឆ្អឹងរបស់មនុស្សតើមានមែនដែរឬទេ?

**ឆ៖** គាត់សក្ខីកម្មថា មានឆ្កែៗពាំឆ្អឹងយកទៅពង្រាយនៅហ្នឹង-- យកទៅដាក់ក្នុងមន្ទីរម-១៣ ហ្នឹងមិនពិតទេ បើថាវាយកទៅខាងក្រៅឯណាអាហ្នឹងខ្ញុំមិនដឹងទេ ហើយតាមពិតតាមខ្ញុំសង្កេតនៅភូមិត្រពាំងត្រោកក៏ដោយ នៅភូមិរមាតថ្មគប់ក៏ដោយ ដូចជាមិនសូវមានឆ្កែ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំ-- សម្រាក ម៉ោងបីប្រាំនាទីចូលវិញ ។ មន្ត្រីតុលាការនាំសាក្សីរូបនេះទៅបន្ទប់សម្រាក ហើយនាំគាត់ត្រឡប់មកវិញនៅវេលាម៉ោងបី ប្រាំ *មីនុត* ។

*[សវនាការសម្រាកពីម៉ោង ១៤:៤៦នាទី ដល់ម៉ោង ១៥:០៥នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តដំណើរការសវនាការតទៅទៀត ។

ជាដំបូងនេះសូមប្រគល់វេទិកាទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីបន្តសំណួរបញ្ចប់ មុនពេលផ្ទេរវេទិកានេះទៅឱ្យភាគី ។ សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោក ឌុច លោកបានឮសាក្សីលើកឡើងអំពីចំនួនអ្នកទោស ដែលគាត់ធ្វើការសន្និដ្ឋានដែលអ្នកទោសទាំងអស់នោះនៅម-១៣ នៅព្រឹកមិញនេះ ។ ហើយនៅព្រឹកមិញនេះ គឺមានការយោង-- ខ្ញុំថាមានចំនួនពីពាន់ ទៅបីពាន់ ចំនួនអ្នកទោស ។ ហើយតើលោកអាចបញ្ជាក់អំពីចំនួនអ្នកទោសនោះដែរឬទេ?

សូមសាក្សីធ្វើការបញ្ជាក់លើចំនួនអ្នកទោស ។

**សាក្សី KW-30៖**

**ឆ៖** បាទ, ខ្ញុំបាទនិយាយនេះ គឺថាមិនបានទៅរាប់អ្នកទោសហ្នឹងទេ តែកាលដែល និយាយនេះ គឺស្មាន វាយស្មានប្រហែលតែប៉ុណ្ណឹង បើយ៉ាងច្រើនណាស់មិនហួសពីហ្នឹង ទេនៅក្នុងម-១៣ ហ្នឹង ។ ដែលខ្ញុំនិយាយនេះ គឺនិយាយស្មាន មិនបានរាប់ឲ្យទៀងទាត់ ថាអ្នកទោសនោះមានប៉ុណ្ណាៗ ទេ តែតាមការស្មានទៅ ។ សូមអស់យោបល់ ។

**ស៖** ខ្ញុំឮចំនួនថាបីម៉ឺននាក់ ឬក៏យ៉ាងម៉េច? មុនហ្នឹងលោកនិយាយថាមានរណ្តៅ ប្រាំមួយ ទៅប្រាំពីរ ហើយរណ្តៅនីមួយៗ គឺប្រហែលជាមានអ្នកទោសម្ភៃ ទៅសាមសិបនាក់ ។ ដូច្នេះ នៅពេលដែលយើងពិចារណាទៅលើចំណុចនេះ ចំណុចអប្បរមា ហើយគឺរណ្តៅប្រាំមួយ ហើយមានអ្នកទោសម្ភៃ គឺទាំងអស់មានមួយរយម្ភៃ បើយើងសរុប ។ ហើយថាតើមានរណ្តៅនៅកន្លែងផ្សេងៗទៀត ដែលគេសម្រាប់ទុកអ្នកទោស ដែរឬទេ?

**ឆ៖** បាទ, ដូចអត់មានឃើញ អត់ឃើញមានទេ ។ តែគ្រាន់តែថាវានៅលើខ្លះ នៅឯលើខ្លះ អ្នកដែលខ្លាំងៗ អ្នកដែលខ្លាំងៗ អាហ្នឹងវាទន់ខ្លាំង គេយកមកលើខ្លះ ។ មិនមែននៅតែក្នុងគុក អាក្នុងរណ្តៅហ្នឹងទាំងអស់ទេ វាមាននៅខាងក្រៅខ្លះ នៅខាង លើហ្នឹង តែនៅក្នុងមួយបរិវេណមន្ទីរគុកហ្នឹង ។ វាមានខ្លះអ៊ីចឹងទៅ បានជាខ្ញុំស្មានថា វាមានប៉ុណ្ណឹង វាមិនច្រើនជាងហ្នឹង ហើយក៏មិនតិចជាងហ្នឹង ។

[១៥:១១:២៥]

**ស៖** លោកបាននិយាយថាអ្នកទាំងអស់នោះ គឺគាត់ទន់ខ្សោយ គឺគេដាក់នៅក្នុង បរិវេណជំរំហ្នឹង ។ ថាតើមានចំនួនប៉ុន្មាន ដែលអ្នកដែលទន់ខ្សោយ ដែលគេដាក់នៅមន្ទីរហ្នឹង?

**ឆ៖** អ្នកដែលទន់ខ្សោយឡើងដាក់មកលើហ្នឹងដូចជាមិនបានយូរប៉ុន្មានទេ ឡើងជួនកាលបានតែមួយកំណាត់ថ្ងៃហ្នឹង ងាប់បាត់ទៅ ។ ខ្លះស្រែករកៗកូន អាខ្លះស្រែករកប្រពន្ធ អាខ្លះស្រែកម៉ែឪឲ្យជួយ អ៊ីចឹងទៅ ស្លាប់បាត់ទៅអស់ទៅ ។ អ៊ីចឹងទេបានថាអ្នកហ្នឹងវាមិនទៀតទាត់ វាចេញចូលៗ ស្លាប់ក៏ស្លាប់ ហើយចាប់បន្តបន្ទាប់រហូតបាទ ។ អ៊ីចឹងទេអ្នកស្លាប់ហ្នឹងវាច្រើនជាងការស្មានហ្នឹង ព្រោះវាស្លាប់រាល់ថ្ងៃ ។ ហើយស្លាប់ ដោយគេធ្វើទារុណកម្ម ដែលខ្ញុំមិនអាចមើលឃើញ ទៅនឹងគេធ្វើដោយស្វាត់កំបាំង ដូចតា ឌុច គាត់និយាយអ៊ីចឹង ។ អាអ្នកដែលៗ វាបានឃើញនោះក៏បានឃើញទៅ អ្នកដែលធ្វើដោយស្វាត់កំបាំងៗ ។ ជួនកាលអ្នកទៅយកទៅធ្វើទារុណកម្មខ្លាំងធ្ងន់ធ្ងរទៅ ដល់ពេលយកមកដល់មន្ទីរហត់

ដល់ដួលខ្ពោកស្លាប់ទៅ ។ អាហ្នឹងគឺសុទ្ធខ្ញុំបានឃើញហើយ ឃើញច្បាស់ណាស់មិនមែនចេះ តែនិយាយទេ ។

**ស៖** អ្នកទោសខ្សោយៗ នោះគឺមិននៅក្នុងរណ្តៅទេ គេដាក់មកខាងក្រៅនៅខាងលើ ។ ថាតើសរុបចំនួនទៅប៉ុន្មាន ដប់ជាង តិចជាងហ្នឹង ឬច្រើនជាងហ្នឹង? ជាការពិតណាស់ គឺថាវាមិនដែលមានចំនួនជាក់លាក់ទេ ថាតើចំនួនខ្ពស់បំផុតប៉ុន្មាន? ហើយចំនួនទាបបំផុតប៉ុន្មាន តាមការសន្និដ្ឋាន? តើលោកយល់សំណួរខ្ញុំដែរឬទេ?

**ឆ៖** បាទយល់ ។ កាលដែលលើកយកមកលើហ្នឹង ជួនកាលបើវាទន់ខ្លាំងហ្នឹង គេយកមកបួនដប់នាក់ទៅ បើវាតិចទៅ វាទន់តិចទៅនៅក្នុងគុកបាន ជំងឺហ្នឹងវាមិនទន់ខ្លាំងពេក ក៏បួនប្រាំនាក់ទៅ គេយកមក ។ ប៉ុន្តែ ដល់យកមកលើហ្នឹង វាមិនដែលបានឃើញយកទៅដាក់ក្នុងរណ្តៅវិញ ឃើញតែយកទៅកប់តែម្តង អត់មានងាយរស់បានយូរទេ ដោយសារហ្នឹងអត់អាហារហ្នឹង ងាប់នឹងអត់អាហារហ្នឹង ។

[១៥:១៤:១៥]

**ស៖** ដូច្នេះខ្ញុំប្រើចំនួនដែលលោកបានបញ្ជាក់ គឺមានចំនួនមួយរយម្ភៃ ទៅដល់ពីររយដប់នាក់ ។ ហើយគឺមានមនុស្សប្រាំ ទៅដប់នាក់ដែលគេដាក់នៅខាងក្រៅ ។ ដូច្នេះចំនួនដែលយើងមាន ដែលថាយើងសរុបហ្នឹង គឺមានចំនួនមួយរយម្ភៃប្រាំ ទៅពីររយម្ភៃប្រាំ ។

ដូច្នេះខ្ញុំសូមសួរជនជាប់ចោទ ថាតើការសន្និដ្ឋានលើចំនួននេះ គឺវាត្រូវគ្នាហ្នឹងភាពជាក់ស្តែងដែរឬទេ តាមអ្វីដែលជនជាប់ចោទដឹង?

**ជនជាប់ចោទ៖**

**ឆ៖** ខាងចំនួននេះ វាជាបញ្ហាមួយដែលបង ស៊ិន គាត់មានប្រសាសន៍ច្រើនតែលើស ។ សូម្បីតែនិយាយ-- ខ្ញុំសូមបញ្ជាក់អំពីរណ្តៅ រណ្តៅជម្រៅតែពីរម៉ែត្រទេ ទទឹងប្រហែលជាពីរម៉ែត្រកន្លះ បណ្តោយប្រហែលជាបីម៉ែត្រប៉ុណ្ណឹងឯង ។ ហើយតាមខ្ញុំចាំពីររណ្តៅ យ៉ាងច្រើនបី ។ ក្នុងមួយរណ្តៅយ៉ាងច្រើន គ្នាដប់នាក់មិនលើសទេ ។ ហើយខ្ញុំសូមជម្រាបថា ខ្ញុំមិនដែលបានទុកជនរងគ្រោះឲ្យស្លាប់នៅក្នុងកន្លែងហ្នឹង ដោយមិនបានយកទៅកម្ទេចទេ ។ ការកម្ទេចវាមានជាប្រចាំ បួនដប់ថ្ងៃ កន្លះខែមួយខែម្តង នៅពេលណាដែលយើងខ្ញុំយកសេចក្តីសារភាពទៅឲ្យគេ គេថាវាប៉ុណ្ណឹងបានហើយ កម្ទេចទៅ ខ្ញុំមកចាត់ចែងឲ្យកម្ទេច ។

ដូច្នេះជំនាន់ហ្នឹងគឺច្បាស់លាស់ណាស់ មិនដែលបានអ្នកទោសណាហៀរដល់មួយរយ-ពីររយ ។ មានតែករណីពិសេសបីលើក ដែលខ្ញុំបានរាយការណ៍ជូនលោកចៅក្រមម្សិលមិញហើយ នៅពេលឈ្នះឧដុង្គមួយលើក អ៎តែពីរលើកទេ-- បីលើក នៅពេលឈ្នះឧដុង្គមួយលើកអាហ្នឹង គេដាក់ជាបណ្តោះអាសន្នសម្រាប់បញ្ជូនទៅខាងពាយ័ព្យ ។ បង ស៊នហ្នឹង ខ្ញុំសង្ស័យគាត់អញ្ជើញទៅ ខ្ញុំបញ្ជូនទៅជាមួយនឹងគេជាមួយពេទ្យសុន អីហ្នឹង ទៅខាងពាយ័ព្យដែរហ្នឹងមួយលើក ពេលឈ្នះឧដុង្គ ។ ហើយមួយលើកទៀតពេលដែលគេបោសសម្អាតភូមិពោធិ៍ ជម្លៀសភូមិពោធិចេញទៅឱ្យអស់យកទៅពាយ័ព្យ ។ មួយលើកទៀតពេលដែលបង ស៊ី គាត់ឱ្យខ្ញុំចាប់ បងស៊ី ឈ្មោះដើម ជូ ជេត នេះអនុលេខាភូមិភាគនិរតី គាត់ឱ្យចាប់ខ្ញុំ គាត់ៗឱ្យគេចាប់មនុស្សនៅអមលាំង ប្រគល់មកឱ្យខ្ញុំសួរចម្លើយដើម្បីរកកាំភ្លើង ។ អាហ្នឹងមានច្រើន ដល់ទៅហុកសិបនាក់ ក្នុងរយៈពេលបីបួនខែហ្នឹង ។

[១៥:១៧:១៧]

**ស៖** *(មិនមានការបកប្រែ ហើយត្រូវបាន ឌុច និយាយកាត់)*

**ឆ៖** ដូច្នេះ សរុបមកសេចក្តីរាយការណ៍របស់បង ស៊នប្រហែលជាគាត់សន្និដ្ឋានអាថ្ងៃដែលច្រើនមកជាមួយនឹងគាត់ ជំនាន់គាត់ហ្នឹង ជាទូទៅក៏សឹងតែថាបាន ។

ដូច្នេះចំនួននេះដែលបង ស៊ន មានប្រសាសន៍ច្រើនតែលើស ។ ខ្ញុំសូមបញ្ជាក់មកចំនួនដែលខ្ញុំជម្រាប គឺខ្ញុំនៅតែប្រកាន់ប៉ុណ្ណឹង ។

**ស៖** ដូច្នេះខ្ញុំជាថ្មីម្តងទៀត ខ្ញុំសូមសួរសាក្សីឱ្យបញ្ជាក់ជូនតុលាការអំពីចំនួនដែលតាមលោកនោះថាតើមានចំនួនអ្នកទោសស្លាប់ប៉ុន្មានមួយថ្ងៃៗ? ថានៅម-១៣ មួយថ្ងៃៗហ្នឹង តើមានអ្នកទោសស្លាប់ប៉ុន្មាននាក់?

**សាក្សី KW-30៖**

មួយថ្ងៃៗ អ្នកទោសជួនកាលស្លាប់ប្រាំនាក់ ទៅប្រាំមួយនាក់ទៅ ប្រាំពីរនាក់ទៅ អត់ទៀងទេ ។ តែប្រចាំអចិន្ត្រៃយ៍ ជួនតិចណាស់ក៏បីនាក់ដែរក្នុងមួយថ្ងៃ បើអន់ណាស់ ។ តែថាឱ្យមួយថ្ងៃហ្នឹងអត់ អត់ទេ មានស្លាប់ ។ ខ្ញុំជាប់នៅក្នុងខ្នោះហ្នឹង នៅក្នុងគុកហ្នឹង ជួនកាលមួយអានងហ្នឹងប្រាំនាក់ មួយអានងហ្នឹង មួយអានងនឹងប្រាំនាក់ ជួនកាលងាប់ពីរ-បីនាក់ដែលវាជាប់នឹងខ្ញុំហ្នឹង ។ ខ្ញុំដេកតែជាមួយខ្មោចហ្នឹង ដែលកាលខ្ញុំនៅក្នុងគុកនៅឡើយ ហើយគេដោះយកខ្មោចយកទៅលើបាត់ទៅ ។ បានថាវាស្លាប់ជាប់ជាអចិន្ត្រៃយ៍អ៊ីចឹង ។

**ស៖** សំណួរចុងក្រោយសម្រាប់ជនជាប់ចោទ ។ សាក្សីបាននិយាយថា ប្រជាជនខ្មែរធ្វើអំពើនេះលើខ្មែរ តើលោកមានអ្វីចង់លើកឡើងទាក់ទងទៅនឹងចំណុចនេះដែរឬទេ?

**ជនជាប់ចោទ៖**

**ឆ៖** ក្នុងមួយរយៈដែលយើងខ្ញុំផ្ទាល់ទៅកាន់កាប់ប្រធានមន្ទីរ-១៣ រហូតដល់ថ្ងៃ១៧ មេសា មិនដែលឃើញជនជាតិអីក្រៅពីខ្មែរទេ អ៎!បារាំងម្នាក់ៗ ដែលខ្ញុំនិយាយបារាំងនេះមិនមែននិយាយ ប៊ីហ្សូ *មីស្សី* ប៊ីហ្សូទេ ខ្ញុំនិយាយបារាំងម្នាក់ ដែល តាម៉ុក គាត់ចាប់បាននៅពេលវាយផ្លូវលេខប្រាំ ។ ឈ្មោះហ្សាកឡ័រហ្សឺល័រ ហ្នឹង ។ តែក្រៅពីឈ្មោះ ហ្សាក់ ឡ័រហ្សឺល័រ គ្មានបារាំងណាក្រៅពី ប៊ីហ្សូ មួយទៀតទេចប់ ។ ក្រៅពីនោះគ្មានយួន គ្មានអាមេរិក ពិតជាខ្មែរសម្លាប់ខ្មែរ ។

[១៥:២០:៣១]

**ស៖** ខ្ញុំគិតថាសាក្សី បាននិយាយអំពីចំណុចហ្នឹងជ្រៅជាងហ្នឹង គឺគាត់ថា ហេតុអ្វីបានជាអាចប្រជាជនខ្មែរហ្នឹង គាត់សម្តែងអប្បកិរិយាយ៉ាងដូច្នេះលើប្រជាជនខ្មែរដទៃៗទៀត?

**ឆ៖** សូមអរគុណលោកចៅក្រម ដែលបានបញ្ជាក់សំណួរនេះថែមមក នេះវាជាបញ្ហានយោបាយដំបូងដូចខ្ញុំបានជម្រាបលោកចៅក្រមអ៊ីចឹង គេថាកំចាត់ចារបុរសខ្លាំង គិញខ្លាំងរហូតដល់ឆ្នាំមួយពាន់ប្រាំបួនរយ-- ប្រែតស៊ូវណ្ណៈៗនៅក្នុងដីរំដោះ ដែលជាមូលដ្ឋានបង្អែក គេយកមាគ៌ាវណ្ណៈ គេយកផ្តាច់ការវណ្ណៈអធន យកមកអនុវត្តហើយ ។ ដូច្នេះ ខ្មែរសម្លាប់ខ្មែរ ដោយងងឹតមុខនឹងរឿងវណ្ណៈអធនបែកការវណ្ណៈអធនហ្នឹងឯង សូមចប់ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អ៊ំ ស៊ន ខ្ញុំមានមួយសំណួរ ។ អ៊ំទៅដល់ទីនោះប្រហែលជា១ឆ្នាំ ហើយអ៊ំមានឱកាសច្រើននៅក្នុងការដែលអ៊ំធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងកម្មាភិបាល បុគ្គលិក កងការពារនៅទីនោះ ពីព្រោះអ៊ំមួយរយៈចុងក្រោយគេបានដោះលែងអ៊ំ ។ តើអ៊ំកត់សម្គាល់ឃើញថា សរុបទាំងកម្មាភិបាល ទាំងបុគ្គលិក ទាំងកងការពារនៅម-១៣ ក្នុងអំឡុងពេលដែលអ៊ំទៅជាប់នៅទីនោះ មានសរុបប្រហែលប៉ុន្មានទៅ គិតទាំង ឌុច ផង?

**សាក្សី KW-30៖**

**ឆ៖** ខ្ញុំស្មានទៅថា ច្រើនដែលមិនតិចទេ ប្រហែលខ្ទង់ ម៉ែចក៏៥០នាក់ដែរ អ្នកដែលកាន់ការពារគុកហ្នឹង តាំងទាំង ឌុច ផង បុគ្គលនៅក្នុងមន្ទីរហ្នឹង ក្រៅពីអ្នកទោស គឺមានប្រហែលប៉ុណ្ណឹង ប្រហែល

៥0នាក់ហ្នឹង ប៉ុណ្ណឹង ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកានេះ ទៅដល់សហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការសួរសំណួរទៅដល់សាក្សីរូបនេះ ។ សូមអញ្ជើញសហព្រះរាជអាជ្ញា ។

**សួរដោយលោក យ៉េត ចរិយា៖**

**ស៖** អរគុណតុលាការ ។ លោក អ៊ុច ស៊ន ទីកន្លែងរស់នៅរបស់លោកមក ម-១៣ មានចម្ងាយប៉ុន្មានគីឡូ?

**សាក្សី KW-30៖**

**ឆ៖** ប្រហែលតែ១០គីឡូទេ ប្រហែលប៉ុណ្ណឹង ប្រហែល១០គីឡូប៉ុណ្ណឹង ពីផ្ទះខ្ញុំមកម-១៣ហ្នឹង ។

**ស៖** លោកស្គាល់មន្ទីរសន្តិសុខ ម-១៣ ហ្នឹងតាំងពីពេលណាមក?

**ឆ៖** ខ្ញុំអត់ដែលស្គាល់ទេ ស្គាល់ពេលដែលគេចាប់ខ្ញុំយកមកដាក់គុកហ្នឹងតែម្តង បានខ្ញុំដឹង ។ ពីដើមខ្ញុំអត់ដឹងថាហ្នឹងមានមន្ទីរនៅកន្លែងហ្នឹងផង អត់ដឹងរលីង ។ ព្រោះខ្ញុំជាប្រជាជននៅតែក្នុងព្រៃជំនាន់ហ្នឹង អត់មានបានទៅតាមឃុំ តាមភូមិ តាមស្រុកទេ គឺរត់ពួនខ្លាចកាប៉ាល់ហោះទម្លាក់ នៅក្នុងព្រៃគ្រប់គ្នាៗ ។

**ស៖** ពេលចាប់រូបលោក តើមានចាប់អ្នកផ្សេងក្រៅពីរូបលោកទេ?

**ឆ៖** បានពេលចាប់រូបខ្ញុំបាទហ្នឹង មានគ្នា៣នាក់ ឈ្មោះតាគុល មួយ ឈ្មោះ តាទឹម មួយ ដោយចាប់ នៅខ្ទារអំបឹស ។ ពេលទៅចាប់ហ្នឹង ឈ្មោះ សួង ហើយ តាគ្រឹង មន្ទីរតាគ្រឹង ។ ពួកគាត់ ប៉ុល ពត ហ្នឹង មកចាប់ខ្ញុំ ខ្ញុំបាយហើយពេលម៉ោង៦ល្ងាច ។

**ស៖** ពីរនាក់ ដែលចាប់ជាមួយរូបលោកហ្នឹង គេយកទៅណាដែរ?

**ឆ៖** យកមក ម-១៣ ទាំងអស់ តែស្លាប់អស់ហើយ ស្លាប់នៅក្នុងមន្ទីរហ្នឹងអស់ហើយ ។

**ស៖** ឌុច ដោះរូបលោកពីខ្នោះឲ្យមកធ្វើការនៅខាងក្រៅ គឺធ្វើការនៅក្នុងមន្ទីរសន្តិសុខហ្នឹងដដែល តើជាឆន្ទៈរបស់ ឌុច ឬមួយមានការស្នើសុំពីអ្នកណា?

[១៥:២៥:៣៦]

**ឆ៖** កាលដែលចាប់៣ថ្ងៃដំបូង អាហ្នឹងខ្ញុំនិយាយពីដំបូង។ ចាប់ខ្ញុំមក៣ថ្ងៃហ្នឹង ដែលខ្ញុំឃើញមានគណៈឃុំ ឈ្មោះតាមលឹម ឈ្មោះតាគង់ ហើយតាគួន មកចូលក្នុងមន្ទីរហ្នឹង តែដឹងតែមកសុំឲ្យដោះ

លែងខ្ញុំក៏មិនដឹង អីមិនដឹងទៅ ។ គ្រាន់តែគាត់មានពេលវិចារប្រាប់ខ្ញុំថា ឈ្មោះតាលឹម ហ្នឹងៗ គាត់ថាក្មួយ ស៊ន អើយ ខ្ញុំចាំស្ទាក់ក្មួយឯងតាមផ្លូវ ហើយខ្ញុំស្ទាក់ទៅវាមិនជួបក្មួយឯង គេយកមកដល់មន្ទីរហើយ ។ ហើយគាត់ប្រាប់ថា "ក្មួយអើយធ្វើម៉េចទេ? មាមកជួយក្មួយឯងអត់បាន ឥឡូវគេយកមកដល់មន្ទីរហួសហើយក្មួយហើយ ។ ឥឡូវក្មួយឯងខំទ្រាំទៅ លត់ដំទៅ គេប្រើអី គេឲ្យធ្វើអីធ្វើទៅ" ។ ហើយកាលខ្ញុំ ដែលគេចាប់ខ្ញុំមកហ្នឹង គឺខ្ញុំនៅក្នុងសង្គមណា ខ្ញុំបម្រើសង្គមហ្នឹង ខ្ញុំអត់មានក្បត់ ខ្ញុំអត់មានគិញហើយខ្ញុំមិនដឹងឈ្មោះថា គិញយ៉ាងម៉េចផងដំបូង ។ ដល់អត់ដឹងផង ទើបតែមកដល់មន្ទីរហ្នឹង ទើបភ្ញាក់កំណើត ។ មិនដឹងថាម៉េចគិញផង? ព្រោះឯងវាងងឹតងងុលប្រជារាស្ត្រមានដឹងអី ។ ត្រង់ ហើយអង្គុយផ្លូវណា មិនដែលដើរដោះអ្នកហ្នឹង ប៉ុន្តែមិនដឹងធ្វើម៉េច? បើគេចោទអ៊ីចឹង គេប្រកាន់អ៊ីចឹងដោយសារខ្ញុំហ្នឹងទៅទិញជ្រូកហ្នឹងយកមកធ្វើបុណ្យ ព្រោះខ្ញុំនឹកឃើញថា សង្គមហ្នឹងគឺអត់មានព្រះពុទ្ធសាសនាទៀតហើយ ។ អ៊ីចឹងធ្វើបុណ្យឲ្យហើយទៅនៅឆ្នាំ១៩៧៣ហ្នឹង គឺថាធ្វើបុណ្យឲ្យហើយទៅគឺហៅចាស់ៗនិមន្តព្រះសង្ឃមកដើម្បីធ្វើបុណ្យនក្ខត្តនុប្បទាន រំឭកនឹកដល់ម៉ែឪ ព្រោះសង្គមខ្មែរក្រហមខ្ញុំដឹងថាសង្គមនេះ វាអស់មានព្រះពុទ្ធសាសនាទៀតហើយ ។ អ៊ីចឹងក៏ធ្វើឲ្យហៅទៅ អាពេលហ្នឹងខ្ញុំទៅទិញម្ហូបគ្រាប់គ្រាន់អស់ហើយ មានអត់ទាន់ពេលហើយចង់ធ្វើសង្ឃទានដល់ចាស់ៗទៀតនោះក៏ទៅទិញហើយពេលនោះគេចាប់ខ្ញុំហ្នឹង នៅខ្ពារអំបឹស ក្តាំងរោលនេះ គេថាខ្ញុំគិញ គេអ្នកស្រុកហ្នឹង អ្នកស្រុកដែលធ្វើប្រធានភូមិ ប្រធានភូមិហ្នឹងឈ្មោះ សឿង ។

(ចៅក្រមសូមអនុញ្ញាតឲ្យសាក្សីគាត់បន្តយនូវការ ដើម្បីឲ្យបានកត់ត្រាឲ្យបានត្រឹមត្រូវទៅលើកំណត់ហេតុតុលាការ ។)

**ប្រធានអង្គជំនុំ៖**

អ៊ំស៊ន និយាយយឺតៗអ៊ំ និយាយលឿនពេក អ្នកបកប្រែបកអត់ទាន់ទេ ហើយការកត់ត្រានៅក្នុងកំណត់ហេតុនៅសម្តីរបស់អ៊ំនិយាយហ្នឹង គឺអត់ទាន់ណា អ៊ំណា ។

[១៥:២៨:០៣]

**ស៖** រយៈពេលលោកជាប់ឃុំនៅ ម-១៣ តើមានឃើញអ្នកទោសណាប៉ុនប៉ងរត់ទេ?

**ឆ៖** មាន ឈ្មោះ លនៗហ្នឹង ចាប់ថ្ងៃហ្នឹងៗ ចាប់ទៅដាក់ខ្នោះជាមួយខ្ញុំនៅនឹងគុកហ្នឹង ។ ដាក់ទៅដល់ពេលម៉ោង៦យប់ គេហៅឡើងគាត់យកដោះខ្នោះហ្នឹង ឡើងទៅសួរចម្លើយ ឡើងទៅសួរចម្លើយខ្ញុំនៅក្នុងគុកនោះទេ ខ្ញុំនៅក្នុងគុកក្នុងដី តែដល់ពេលគេទៅយូរណាស់ ដល់យកមកវិញលែង

នៅស្គាល់ លន ហើយ បែកអស់ហើយមុខ បែកអស់ហើយ ។ ដល់គេដាក់ខ្នោះ ពួកកងការពារហ្នឹង គេដើរចេញឃ្លាតពីក្នុងរណ្តៅហ្នឹងហើយ ក៏ លន ហ្នឹងប្រាប់ខ្ញុំថា “ពូ ខ្ញុំពីថ្ងៃនេះអស់ស្លាប់ហើយ អស់រស់ហើយ ខ្ញុំស្លាប់ហើយពូ ហើយស្អែកហ្នឹងខ្ញុំរត់ហើយ ខ្ញុំថាអ៊ីចឹង ស្អែកហ្នឹង ខ្ញុំរត់ឲ្យគេបាញ់ ឲ្យងាប់ឲ្យហើយទៅ” ។ ព្រឹកឡើង ក៏វាសុំគេទៅជុះបត់ជើង ដល់ពេលទៅ គេដឹក គេដោះខ្នោះជើងទៅ វានៅជាប់ចំណងដៃ ហើយឈ្លប អាកងការពារហ្នឹងគេបណ្តើរ គ្រាន់តែបណ្តើរទៅដល់ហ្នឹង វារត់ៗទាំងចំណង រត់បានចម្ងាយប្រហែលជា១គីឡូ បានបាញ់ត្រូវ បាញ់ងាប់រត់នឹងចំណង ។ បាញ់ងាប់មែនចាប់បានតែមួយថ្ងៃមួយ ស្អែកឡើងងាប់ វារត់ទៅឲ្យគេបាញ់ងាប់មែន អាហ្នឹងឈ្មោះ លន នៅភូមិស្នួលជាមួយខ្ញុំហ្នឹង ប្រពន្ធវាសព្វថ្ងៃនៅរស់នៅអន្លង់ជ្រៃ ឈ្មោះ អេង ។

**ស៖** លោកបញ្ជាក់មកមើលអ្នកទោស ដែលគនាំចូលទៅម-១៣ មានក្មេងទេ មានកូនអ្នកទោសទៅជាមួយទេ?

**ឆ៖** បាទ, មាន។ ក្មេងច្រើនណាស់ប្រហែលតែប្អូន ដប់នាក់ដែរទៅជាប់ដេកជាមួយម៉ែឪហ្នឹង ។

**ស៖** ក្មេងៗទាំងហ្នឹង គេយកទៅណា?

**ឆ៖** ទេ បើយកទៅហ្នឹង ដូចវាបាត់អស់ទាំងឪពុក ទាំងម្តាយទៅ ទាំងកូនទៅ មិនដឹងគេយកទៅណាទេ ខ្ញុំក៏អត់បានដឹងផង តែបាត់អត់ទៅ រហូតសព្វថ្ងៃនេះមក លវាស្លាប់អស់ហើយ ។

[១៥:៣០:៣០]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាមានសំណួរអីទេ?

សូមអញ្ជើញសហព្រះរាជអាជ្ញា ។

**លោក រ៉ូប៊ឺត ពើទីត៖**

អរគុណលោប្រធាន ខ្ញុំអត់មានសំណួរទៅសាក្សីនោះទេ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកានេះ ជូនទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅឱកាសក្នុងការតាំងសំណួរដល់សាក្សីរូបនេះ ហើយអង្គជំនុំជម្រះសូមរំឭកថា សូមជៀសវាងនូវការតាំងសំណួរច្រំដែល ទីមួយ ។ ហើយទីពីរ សូមតាំងសំណួរខ្លីៗ ហើយឲ្យបានច្បាស់ ដើម្បីឲ្យសាក្សីដែលលោកមានការរៀនសូត្របានតិចផង ហើយគាត់ស្តាប់បានច្បាប់ ហើយគាត់នឹងត្រូវឆ្លើយទៅនឹង

សំណួរ ហ្នឹងឲ្យបានច្បាស់លាស់ ។

បាទ សូមអញ្ជើញពីតាមលំដាប់ ពីក្រុមមួយមុន ។

**សួរដោយកញ្ញា ទី ស្រ៊ីនណា៖**

**ស៖** សូមអរគុណលោកប្រធាន ។ នាងខ្ញុំឈ្មោះ ទី ស្រ៊ីនណា ជាមេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមមួយ ។ ជាបឋមនាងខ្ញុំសូមគោរពលោកប្រធាន លោកចៅក្រមជាតិ ចៅក្រមអន្តរជាតិ និងអង្គសវនាការទាំងមូល ។ នាងខ្ញុំមានសំណួរមួយចំនួនដើម្បីសួរទៅកាន់សាក្សី ដែលមានឈ្មោះ អ៊ុច ស៊ន ។

មុននឹងនាងខ្ញុំសួរ នាងខ្ញុំសូមរំឭកលោកសាក្សី សូមរំឭកដល់លោកសាក្សីបន្តិច ទាក់ទងបញ្ហានៃការឆ្លើយ បើសិនថា សំណួរណាដែលនាងខ្ញុំសួរទៅមានលក្ខណៈមិនច្បាស់លាស់ សូមឲ្យលោកសួរខ្ញុំម្តងទៀត ហើយនិងសំណួរណា ដែលខ្ញុំសួរទៅ លោកអត់ចាំ ឬក៏លោកចាំដែរ សូមឲ្យឆ្លើយតាមថាចាំ ឬក៏លោកពុំចាំទេ សូមលោកជួយឆ្លើយតាមស្ថានភាពជាក់ស្តែង សូមអរគុណ ។

ឥឡូវនេះ នាងខ្ញុំសូមចាប់ផ្តើមសំណួររបស់ខ្ញុំ នៅអំឡុងឆ្នាំដែលលោកចូលទៅ ជាប់ពន្ធនាគារនៅមន្ទីរ១៣ ចាប់តាំងពីពេលដែលលោកទៅដល់មន្ទីរ១៣ តើលោកមានដែលធ្លាប់ឃើញអ្នកយាម គេធ្វើការកប់អ្នកទោសទាំងរស់ ឬមួយក៏បានន័យថា អ្នកទោសទាំងរស់ដែរឬទេ?

[១៥:៣៣:២១]

**សាក្សី KW-30៖**

**ឆ៖** មានដូចខ្ញុំថា មនុស្សប្រុសម្នាក់ ស្រីម្នាក់វ៉ៃទម្លាក់រណ្តៅហ្នឹងមាន ។ វ៉ៃទៅមនុស្សស្រីហ្នឹងមិនទាន់ងាប់ទេ តែនៅងើ្លមផ្ទឹកៗដែរ គេអូសទម្លាក់រណ្តៅកប់ អាហ្នឹងខ្ញុំឃើញតែម្តងហ្នឹងទេ ។ ឃើញមានមួយហ្នឹង ។

**ស៖** ខ្ញុំសូមបន្តសំណួរទៀត សំណួរទីពីរ ខ្ញុំសូមសួរថា ក្នុងអំឡុងពេលដែលលោកនៅមន្ទីរ១៣ កន្លងមកដែលលោកមានតួនាទីជាអ្នកបោសសំអាតនៅទីនោះ ក៏ដូចជាតួនាទីនៅក្នុងការកប់សាកសព ។ តើលោកមានដែលប្រទះឃើញខាងអ្នកយាម គេមានការប្រជុំគ្នា ដើម្បីរៀនវិធីសាស្ត្រក្នុងការសួរចម្លើយអ្នកទោស ក៏ដូចជាវិធីសាស្ត្រនៅក្នុងការធ្វើទារុណកម្មទៅលើអ្នកទោសដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលឃើញៗគេប្រជុំទេ ដែលដឹងគេប្រជុំកន្លែងណា ខ្ញុំមិនដែលបានជួយប្រទះផង អត់ឃើញ ។

**សៈ** ខ្ញុំសូមបន្តសំណួរមួយទៀតទាក់ទងនឹងចម្លើយលោកពូដែលបាននិយាយអម្បាញ់មិញ ពាក់ព័ន្ធជាមួយនឹងការសម្លាប់មនុស្សដែលមានដូចថា លោកពូបានឆ្លើយថា មានអ្នកទោសចំនួន៥នាក់ ដែលត្រូវបានចងភ្ជាប់ជាមួយនឹងបង្គោល ហើយនៅក្នុង៥នាក់ហ្នឹង មានតម្រាបជា៤ ហើយបន្ទាប់មកមានអ្នកកណ្តាលមួយផ្សេងទៀត ។ ហើយអ្នកទោសដែលនៅកណ្តាលនោះ ត្រូវបានគេបាញ់ចំកណ្តាលក្បាល ដើម្បីសម្លាប់ ខ្ញុំចង់សួរថា តើអ្នកទោសដែល៤នាក់ផ្សេងទៀត តើគេយកទៅណា?

**ឆៈ** អ្នកទោសផ្សេងទៀតនោះ មិនដឹងគេយកទៅណាទេ ស្រាយយកទៅអស់បាត់ទៅ ។ ខ្ញុំក៏អត់បានឃើញអី ដឹងគេយកទៅណាទៅណីទៀតមិនដឹងទេ មុខជាយកទៅបញ្ចូលក្នុងគុកទៀតហើយមើលទៅនោះ តែដល់យូរៗមកបានពួកអ្នកអស់ហ្នឹងស្លាប់អស់ទៅ ដែលបាននៅមិនយកខ្ញុំទៅពោធិសាត់ហ្នឹង ។ ខ្ញុំឃើញពួកអស់ហ្នឹង អ្នកដែលនៅៗហ្នឹងស្លាប់អស់ទៅ ហើយចាប់បន្តបន្ទាប់ក្រោយទៀតមកខ្ញុំក៏អត់បានដឹងដែរ ។

**សៈ** ចុះលោកពូអំឡុងពេលហ្នឹង នៅពេលដែលគេធ្វើទារុណកម្មរូបភាពបែបហ្នឹង តើលោកពូមានដែលប៉ាន់ប្រមាណថា តើពួកគាត់ស្ថិតនៅក្នុងតួនាទីអ្វី? អ្នកដែល មានន័យថា អ្នកដែលត្រូវបានគេចាប់យកទៅដាក់ ដែលគេចាប់ចងដើម្បីបាញ់ ដើម្បីគំរាមដល់អ្នកដទៃហ្នឹង សួរថាតើលោកពូមានដឹងថាពួកគាត់ជាមនុស្សប្រភេទណា? ជាប្រជាជនសាមញ្ញ ឬក៏ជាបុគ្គលដែលមានឋានៈជាមន្ត្រីរាជការមកពីរបប លន់ នល់ ឬមួយក៏គាត់ជាទាហានរបស់ខ្មែរក្រហមខ្លួនឯង ដែលគាត់មានកំហុសអ្វីមួយផ្សេងទៀតដែលត្រូវបានគេយកមកចង់ដើម្បីបាញ់គំរាមអ្នកដទៃ ។

តាមទស្សនៈលោករបស់លោកពូផ្ទាល់ តើលោកពូយល់ថាគាត់ជាមនុស្សប្រភេទណាដែរ?

[១៥:៣៦:៤២]

**ឆៈ** អ្នកដែលសល់ពីគេៗអត់បាញ់ហ្នឹង គឺអ្នកស្រុកសាមញ្ញធម្មតា អ្នកភូមិស្លូលជាមួយយើងខ្ញុំហ្នឹង ។ អត់មានអ្នកទេ គឺប្រជាជនធម្មតា អ្នកស្រុកធម្មតាមិនមែនមានអ្នកបណ្តាស័ក្តិ អ្នកទាហានប៉ូលិសអីអត់ទេ ។

**សៈ** តើលោកពូប្រាកដជាអ្នកស្រុកធម្មតា?

ខ្ញុំសូមសួរម្តងទៀត តើលោកពូប្រាកដហើយដែលថា អ្នកទោសទាំង៤នាក់ដែលត្រូវបាន-- ទាំង៥នាក់ដែលគេសម្លាប់នុ៎ង ដែលចងបង្គោលសម្លាប់ហ្នឹង គឺជាប្រជាជនសាមញ្ញធម្មតា? លោកពូប្រាកដដែរឬទេ?

[១៥:៣៧:៣១]

**ឆ៖** បាទប្រាកដ! ប្រាកដណាស់ខ្ញុំស្គាល់ទាំងឈ្មោះទៀត ។

**ស៖** សូមអរគុណលោកពូ ។ ពាក់ព័ន្ធនឹងចំណុចមួយទៀត ពាក់ព័ន្ធទៅនឹងស្ថានភាពលោកពូ លោកពូបានមានប្រសាសន៍ថា លោកពូនៅពេលដែលមកដល់តាមផ្លូវមានមនុស្សម្នាក់ដែលបានព្យាយាមជួយដល់លោកពូ ដែលឈ្មោះ-- ខ្ញុំអត់ចាំទេ ដែលគាត់ថា លោកពូហៅថា ក្មួយអើយមាជួយមិននោះ ។ បានជាក្មួយមកដល់ទីនេះហើយ តើលោកក្មួយត្រូវតែទ្រាំធ្វើការឲ្យគេទៅ ដើម្បីៗឲ្យបានស្ថានសម្រាលទាក់ទងនឹងទោសនឹងកុំឲ្យមានការផ្តន្ទាទោសអ៊ីចឹង លោកពូ ។ អ៊ីចឹងខ្ញុំចង់សួរលោកពូថា នៅក្នុងស្ថានភាពបែបហ្នឹង តើលោកពូមានឱកាសធ្លាប់ថាៗ ពេលដែលគេចាប់លោកមកនេះ លោកពូគឺជាមនុស្សម្នាក់ដែលជាប្រជាពលរដ្ឋសាមញ្ញមិនមែនជាគិញទេ ដែលគេចោទលោកពូថាជាគិញ ប៉ុន្តែ លោកមិនមែនជាគិញទេ ។

តើលោពូដែលមានឱកាសដើម្បីសួរទៅពួកគាត់ សួរទៅអ្នកយាម ក៏ដូចជាអ្នកដឹកនាំខាងហ្នឹងថាតើលោកពូមានឱកាសក្នុងការនិយាយជាមួយពួកគាត់ថា លោកពូមិនមែនជាគិញទេ លោកពូគឺជាប្រជាជនសាមញ្ញ ។ តើលោកពូធ្លាប់មានឱកាសនិយាយដែរ ទៅកាន់អ្នកយាមទាំងនោះដែរឬទេ?

**ឆ៖** បាទ, ខ្ញុំបាននិយាយទៅ មាស លោក មាស ដែលខ្ញុំនិយាយ ។ ខ្ញុំថាៗមាសម៉េចមិនហៅខ្ញុំទៅសួរផង ។ ខ្ញុំដែលវាអត់ដឹងអី! នៅជាប់ទោសហ្នឹង ហើយខ្ញុំឃើញថាជាប់គុកយូរៗគង់ស្លាប់ទេអញ្ញបើមុននឹងស្លាប់ឲ្យគេហៅទៅសួរដឹងហេតុដឹងផល ដឹងខុសដឹងត្រូវ ហើយដល់ខ្ញុំប្រាប់ហើយ ប្រាប់គេអ៊ីចឹង “ម៉េចមិនហៅខ្ញុំយកទៅសួរផង” មាស ថាហ៊ឺ!សួរអី!គ្រាន់អាម៉ាទៅចាប់ជ្រូកហ្នឹង ។ មាស ថាអ៊ីចឹង មាស ហ្នឹងថាឲ្យខ្ញុំអ៊ីចឹង ។ បងឯងគ្រាន់តែទៅចាប់ជ្រូកហ្នឹង ហើយដល់អ៊ីចឹងខ្ញុំអត់ហាននិយាយអីទៀតទៅ គេថាអ៊ីចឹងហើយ ។

តាំងពីចាប់ខ្ញុំយកទៅមិនដែលសួរចម្លើយខ្ញុំអីម្តងអត់ទេ រហូតដល់ពេលថ្ងៃលែងខ្ញុំម្តងបានឲ្យខ្ញុំទៅពោធិសាត់ ។ គាត់លែងឲ្យខ្ញុំទៅពោធិសាត់ តែប៉ុណ្ណឹងអត់ដែលមាននរណាសួរនាំខ្ញុំពីរឿងអីៗទេ ។ បាទ អត់រលីងមួយមន្ទីរគុកហ្នឹង ។

[១៥:៣៩:៥៥]

**ប្រធានអង្គជំនុំ៖**

មេធាវីពេលដែលនិយាយហ្នឹង សូមឃ្លាតឆ្ងាយពីក្បាលមេក្រូប្រហែលជាពីរតឹក នេះតាមការ

ណែនាំកន្លងមក ដោយសារវាក្រលំរពេក ប្រហែលជាពីរតិកអាចនិយាយទៅស្តាប់សំឡេងបានល្អ ។

**កញ្ញា ទី ស្រ៊ីនណា៖**

នាងខ្ញុំសូមអស់សំណួរចំពោះសាក្សី។ ក៏ប៉ុន្តែ នាងខ្ញុំសូមស្នើសុំលោកប្រធាន មេត្តាបង្វែរសំណួរខ្ញុំមួយសំណួរ ដើម្បីឲ្យទៅខាងជនជាប់ចោទ មេត្តាជួយបំភ្លឺពាក់ព័ន្ធទៅនឹងតួនាទីរបស់អ្នកទោសចំនួន៥នាក់ដែលគាត់ៗត្រូវបានគេចងដៃភ្ជាប់ទៅនឹងបង្គោល ហើយត្រូវបានគេបាញ់អ្នកកណ្តាល ដើម្បីគំរាមអ្នកដទៃ ។

ខ្ញុំចង់ដឹងថា តើបុគ្គលទាំងនោះ គឺជាបុគ្គលប្រភេទណា? គាត់មានទោសអ្វី ដែលៗឈានដល់ដំណាក់កាលមួយចងភ្ជាប់ទៅនឹងបង្គោល ដើម្បីធ្វើការបាញ់គំរាមដល់អ្នកទោសដទៃ ។ នាងខ្ញុំសូមបង្វែរសំណួរនេះទៅជនជាប់ចោទ ។ សូមលោកមេត្តាអនុញ្ញាតពីលោកប្រធាន ប្រសិនជាលោកប្រធានយល់ថា អាចសមគួរថានឹងអាចបង្វែរបាន ។ សូមអរគុណ ។

[១៥:៤១:២០]

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទអាច យល់សំណួរនេះទេ? ហើយអាចឆ្លើយនៅសំណួរបានទេ? បើអាចឆ្លើយបានសូមអញ្ជើញ!

**ជនជាប់ចោទ៖**

បញ្ហានេះ ខ្ញុំបានរាយការណ៍ជូនលោកចៅក្រម ឡាវែន៍ ច្បាស់លាស់ហើយ ។ បើលោកប្រធានអនុញ្ញាតឲ្យខ្ញុំរាយការណ៍ជូនមេធាវីទៀត ខ្ញុំរាយការណ៍ទៀត ។

**ប្រធានអង្គជំនុំ៖**

មេធាវីបញ្ជាក់សំណួរម្តងទៀតមើល ចៀសវាងសំណួរច្រំដែល ពីព្រោះយើងឃើញដំណើរការប្រព្រឹត្តទៅប៉ុន្មានថ្ងៃនេះ មានសំណួរច្រំដែលច្រើនលើកច្រើនសា ។ ក៏ប៉ុន្តែការកត់សម្គាល់ ដោយសារហេតុផលមានការពាក់ព័ន្ធមួយផ្នែកធំទៅលើការស្តាប់នៃការបកប្រែភាសា ដែលជាឥទ្ធិពលនាំឲ្យមានការស្តាប់មិនអស់ ហើយមានការច្រំដែល ។

ឥឡូវនេះ នាងមេធាវីតាំងសំណួរឲ្យបានច្បាស់លាស់មើលថា បំណងនៃការសួរហ្នឹង សួរយ៉ាងម៉េច? សួរឲ្យច្បាស់តែម្តងនូវបញ្ហាដែលចង់ដឹងតែម្តង ចៀសវាងការបន្លាយនូវអង្គហេតុហ្នឹងវង់ចុះវង់ឡើងចុងក្រោយសួរតែបញ្ហាបន្តិចនោះ ព្រោះអង្គហេតុដែលយើងបានដេញដោលនេះ ដឹងគ្រប់គ្នាហើយ

ព្រោះតាមដានច្រើនថ្ងៃមកហើយ ។

[១៥:៤២:៤១]

**កញ្ញា ទី ស្រ៊ីនណា៖**

នាងខ្ញុំសូមអរគុណលោកប្រធាន។ នាងខ្ញុំទាក់ទងទៅនឹងគោលបំណងនាងខ្ញុំ ដែលនាងខ្ញុំសួរនេះ គឺមានលក្ខណៈមួយដែលនាងខ្ញុំឆ្ងល់បន្តិច ពីព្រោះថា នៅក្នុងដំណាក់កាលមួយដែលលោកជនជាប់ចោទគាត់លើកឡើងហ្នឹង ។ គឺនាងខ្ញុំមានលក្ខណៈរៀងមួយស្រពេចស្រពិលទាក់ទងទៅនឹងអំឡុងពេល ។ ជនជាប់ចោទគាត់បានលើកឡើងថា ពាក់ព័ន្ធនឹងសកម្មភាពនឹងគឺមានហើយ តែខ្ញុំមិនដឹងថា នៅក្នុងឆ្នាំណាទេ? ប៉ុន្តែជនសាក្សីដែលគាត់មានវត្តមាននៅទីនេះ គឺជនជាប់ចោទហ្នឹង គឺវត្តមានរបស់គាត់នៅក្នុង ម-១៣ហ្នឹង គឺស្ថិតនៅក្នុងឆ្នាំ១៩៧៣ អ៊ីចឹងនាងខ្ញុំអត់ដឹងថា សកម្មភាពនៃការសួរដល់សកម្មភាពដែលយើងធ្វើទៅលើជនជាប់-- អ្នកទោសនៅក្នុងសម័យនោះ ទាក់ទងនឹងការការចងបង្គោលនោះ ។

សួរថាតើមានការចងបង្គោលហ្នឹងរយៈពេលប៉ុន្មានដង?ព្រោះដើម្បីសាក្សីគាត់បានឆ្លើយថា“គាត់គិតថា អ្នកដែលជាប់ ដែលត្រូវគេចងជាប់នឹងបង្គោលដើម្បីបាញ់ទុំង គឺជាជនស៊ីវិលសាមញ្ញធម្មតា” ។

អ៊ីចឹងនាងខ្ញុំគ្រាន់ចង់ដឹងអំពីចំណុចហ្នឹង ហើយនិងសុំឲ្យខាងជនជាប់ចោទជួយបំភ្លឺទៅលើបញ្ហាហ្នឹង ពាក់ព័ន្ធទៅនឹងស្ថានភាពនៅក្នុងការដែលគាត់មានការចងបាញ់អ្នកទោសចំនួនប៉ុន្មានដង? នាងខ្ញុំក៏ចង់ដឹងពីបញ្ហាហ្នឹងឲ្យច្បាស់ដែរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ឃើញថា សំណួរនេះជនជាប់ចោទបានឆ្លើយច្រើនលើកច្រើនសាហើយ ។ អ៊ីចឹងយើងប្រាប់ថា ជនជាប់ចោទមិនបាច់ឆ្លើយនឹងសំណួរនេះទេ។

សូមអញ្ជើញមេធាវីក្រុមពីរ បើសិនជាមានសំណួរសូមអញ្ជើញ ។

**លោកស្រី ស៊ីលឃីស្នួត ហ្សីនស្គី៖**

អរគុណលោកប្រធាន ។ ខ្ញុំ ស៊ីលឃីស្នួត ហ្សីនស្គី ខ្ញុំជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ខ្ញុំមានសំណួរមួយចំនួយតិចប៉ុណ្ណោះ ។ ខ្ញុំចង់ដឹង...*(បញ្ហាបច្ចេកទេស)*

[១៥:៤៥:០០]

**ប្រធានអង្គជំនុំ៖**

ស្តាប់អត់ឮទេ មន្ត្រីតុលាការរៀបសម្រាបសម្រួលបញ្ហានេះមើល ដូចជាអត់មានការបកប្រែទេ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

**ស៖** អរគុណលោកប្រធាន ឈ្មោះរបស់ខ្ញុំគឺ ស៊ីលឃី ស្ទួតហ្សីនស្គី ខ្ញុំជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី តំណាងឲ្យជនរងគ្រោះ ។ ខ្ញុំមានសំណួរមួយចំនួនតិចប៉ុណ្ណោះ ។ នៅពេលដែលលោកនិយាយថា នៅក្នុងរណ្តៅ នៅពេលដែលលោកនៅពេលយប់នៅក្នុងរណ្តៅ ថាតើអ្នកទោសគាត់នៅកៀកគ្នាឬយ៉ាងម៉េច?

**សាក្សី KW-30៖**

**ឆ៖** នៅជាប់កៀកៗគ្នា ជិតៗគ្នាអ៊ីចឹង ដាក់ក្នុងមួយរនងដែកៗហ្នឹង ៥ ទៅ ៦ នាក់ ។ រនងដែកនោះ វែងណាទទឹងប្រហែល៣ម៉ែត្រដែរ ប៉ុណ្ណឹង ហើយដាក់កៀកៗគ្នាអ៊ីចឹង ដាក់ខ្នោះជើងទាំងអស់ជាប់គ្នា នៅកៀកៗគ្នា នៅជិតៗគ្នា ។

**ស៖** លោកលើកឡើងថា លោកឮសម្រែករបស់អ្នកទោសដែលរងទារុណកម្ម ថាតើលោកឮសម្រែកនោះ ញឹកញយប៉ុនណា? តើលោកឮសម្រែកនោះរាល់ថ្ងៃ?

**ឆ៖** អត់ទេ ឮតែម្តងទេ រួចពីហ្នឹងអត់ដែលឮទៀតទេ ។ ឮតែម្តងហ្នឹង ជួនតែខ្ញុំដើរបោសវាលទៅជិតឮគេធ្វើបាបហ្នឹង ដល់ក្រឡេកទៅមើលឃើញក៏ខ្ញុំគេចបាត់ទៅ ខ្ញុំមិនប៊ាននៅមើលទេ ឮតែម្តងទេ រួចពីហ្នឹងទៅមិនដឹង គេទៅធ្វើកន្លែងណាទៀត ខ្ញុំអត់ដឹង ។

**ស៖** ថាតើលោកនៅឆ្ងាយចម្ងាយប៉ុន្មាន ពីកន្លែងដែលគេសួរចម្លើយនិងធ្វើទារុណកម្ម?

**ឆ៖** ឃ្លាតឆ្ងាយប្រហែលតែ ២០ម៉ែត្រ ៣០ម៉ែត្រពីគ្នា ប៉ុណ្ណឹងចុះ ។

[១៥:៤៨:០៨]

**ស៖** លោកដឹងដែរឬទេ នរណាគេជាអ្នកសួរចម្លើយ? នរណាគេជាអ្នកធ្វើទារុណកម្មនៅពេលនោះ?

**ឆ៖** អត់ស្គាល់ឈ្មោះគេផង ខ្ញុំ ហើយក៏មិនបានឈរមើលឲ្យដិតដល់សម្គាល់មើលអត់ទេ គ្រាន់តែក្រឡេកឃើញអ៊ីចឹង ឮស្ងូរស្រែក អាយោងអាយ៉ាយ អ៊ីចឹងខ្ញុំគេចបាត់ទៅ ដល់គេចបាត់ហើយក៏មិនបានមើលមុខ មិនបានចាប់អារម្មណ៍អី គិតតែពីភ័យតែខ្លួនឯងហ្នឹង ខ្លាចគេរករឿងថាខ្លួនឯងហ្នឹងទៅមើលគេអី ប៉ុន្តែ ខ្ញុំមិនមែន បំណងខ្ញុំហ្នឹង ដើរទៅមើលគេទេ គ្រាន់តែទៅជួនតែជួបគេទៅក៏គេចបាត់ទៅមិនបានសម្គាល់មើលមនុស្សហ្នឹងថា ឈ្មោះអីទេ អត់ចាំដែរ ព្រោះភ្លេចអស់ហើយ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ ការសម្លាប់កន្លែងដែលលោកសម្លាប់ ឃើញថាមានការសម្លាប់

អ្នកទោស៥ នាក់ ហើយមួយនាក់នៅកណ្តាលត្រូវបានគេបាញ់សម្លាប់ ថាតើអ្នកទោសទាំងអស់នោះជាអ្នកទោសប្រុស ឬក៏អ្នកទោសស្រី?

**ឆ៖** អ្នកទោសនោះសុទ្ធតែប្រុសទាំងអស់ អត់មានស្រីទេយកមកចងបាញ់អ៊ីចឹង អត់ទេ សុទ្ធតែប្រុស ។

**លោកស្រី ស៊ីលឃី ស្នួតហ្សីនស្គី៖**

អរគុណច្រើន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ មេធាវី ។

[១៥:៥០:០០]

**សួរដោយលោក គង់ ពិសី៖**

**ស៖** សូមអរគុណ លោកប្រធាន ។ ខ្ញុំបាទឈ្មោះ គង់ ពិសី ។ សុំសួរសំណួរពីរ-បីសំណួរទៅខាងសាក្សី ។ ខ្ញុំបាទសួរទាក់ទងនៅនឹងឈ្មោះ លន ។ លន ហ្នឹងត្រូវបានចាប់ខ្លួនមកជាមួយនឹងលោកអ៊ំ ហើយជាមួយនឹងឈ្មោះម្នាក់ទៀត ។ ហើយនៅពេលនោះ លន ត្រូវបានគេសួរចម្លើយ ។ ហើយក្រោយពីសួរចម្លើយមក អ៊ំ ក៏ឃើញថា លន ហ្នឹងបែកមុខបែកមាត់អស់ ។ អ៊ីចឹង អ៊ំ មានបានសួរឈ្មោះ លន ហ្នឹងទេថា តើគេធ្វើអ្វី ចំពោះគាត់បានជាបែកមុខបែកមាត់?

**សាក្សី KW-30៖**

**ឆ៖** ខ្ញុំសួរថាគេធាក់នឹងស្បែកជើងកង់ឡាន ជំនាន់ហ្នឹងពួកខ្មែរក្រហមច្រើនតែពាក់ស្បែកកង់ឡានគេឈ្លូសនឹងស្បែកជើងកង់ឡាន បែកអស់ហើយមុខ ។

**ស៖** សំណួរមួយទៀត ។ ម្នាក់មួយទៀតដែលមកជាមួយអ៊ំដែរ ខ្ញុំដូចជាមិនចាំឈ្មោះ អ៊ីចឹងម្នាក់ទៀត ត្រូវបានគេសួរចម្លើយទេ នៅពេលនោះ?

**ឆ៖** ដែរអាម៉េច ស្តាប់មិនបាន? ស្តាប់មិនយល់?

**ស៖** គេចាប់មកជាមួយអ៊ំ បីនាក់ ។ ឈ្មោះ លន ហើយនិង អ៊ំ ហើយនៅម្នាក់ទៀត វ៉ុន ?

**ឆ៖** ឈ្មោះ គល់ ។

**ស៖** បាទ, ឈ្មោះ គល់ អ៊ីចឹង ។

**ឆ៖** បាទ ។

**ស៖** អ៊ីចឹង ឈ្មោះ គល់ នោះត្រូវបានគេយកទៅសួរចម្លើយទេ?

**ឆ៖** ហ៊ឹ! ពេលដែលចាប់មកហ្នឹង ដំបូងហ្នឹងដាក់ជាមួយគ្នា រួចពីហ្នឹងគេបំបែកគ្នាបាត់ទៅហើយ ។ តែដឹងគេយកទៅសួរចម្លើយដឹងអត់ បើខ្ញុំក៏អត់ដឹងដែរពេលហ្នឹង វាភ័យរៀងខ្លួនសម្បើមណាស់ ដំបូងហ្នឹងមិនដឹងថា ស្លាប់ ឬរស់ ទេ ។ គេយកទៅដាក់គុកបាត់ទៅ តែដល់យូរៗមក បានប្រហែលរំលងតែកន្លះខែហ្នឹងគាត់ស្លាប់បាត់ទៅ គាត់ស្លាប់ហ្នឹងអត់អាហារហ្នឹងបាយហ្នឹង ហើយម្នាក់ទៀតឈ្មោះ ទិន ហ្នឹងក៏គាត់ស្លាប់បាត់ដែរ ។ តែឪពុកគាត់មុននឹងចាប់ ទិន ហ្នឹងមកហ្នឹង ឪពុកនឹងមកសួរចូលមកក្នុង ម-១៣ ហ្នឹង បែបជាគាត់មិនដឹង ភូមិគាត់នៅស្វាយមួយដើម ហើយដល់ពេលគាត់ចូលមកសួររកកូនគាត់ ថាមូលហេតុអីបានជាចាប់កូនខ្ញុំមក? មានទោសអី? រួចក៏គេចាប់គាត់ហ្នឹងបាត់ទៅទៀត ចាប់ឪពុក ទិន ហ្នឹងបាត់ទៅ ចាប់ទៀតទៅ ឪពុកហ្នឹងស្លាប់មុនកូនទៅទៀត ឪពុកហ្នឹងស្លាប់ដោយអត់បាយស្លាប់មុន អាកូនហ្នឹងស្លាប់ក្រោយ ។ ហ្នឹងដែលខ្ញុំបាន-- ដែលគេកាលមិនទាន់បញ្ជូនខ្ញុំទៅពោធិ៍សាត់ហ្នឹង ខ្ញុំបានឃើញតែប៉ុណ្ណឹងទេ ។

[១៥:៥២:៣៤]

**ស៖** ខ្ញុំសូមសួរសំណួរផ្សេងវិញ ទាក់ទងទៅនឹងការឃុំខ្លួន ។ ពេលដែលគេឃុំខ្លួនលោកអ៊ំ ឬក៏ដូចជាអ្នកដទៃទៀត នៅក្នុងរណ្តៅ ។ ពេលដាក់ក្នុងរនង តើគេមានឲ្យស្លៀកពាក់ខោអាវទេ?

**ឆ៖** ខោអាវ ដែលយើងយកជាប់នឹងខ្លួនប៉ុន្មាន មានតែខោប៉ុន្មានហ្នឹង អត់មានខោអីទេ ទទឹកលិចស្ងួតហ្នឹង ដូចដែលខ្ញុំអ៊ីចឹង ។ វាភ្លៀងមក ជោគអ៊ីចឹងទៅ រួចទទឹកស្ងួតៗហ្នឹង អត់មាន មានខោអាវពីណាយកមកផ្លាស់ទេ អត់មានតែខោដដែលៗហ្នឹង អាវដដែលៗហ្នឹង មានអ្នកណាឲ្យយើង ។ កូនប្រពន្ធយើងណាហ៊ានចូលមកយកស្អីអ្វីមកឲ្យដល់ក្នុងមន្ទីរហ្នឹង អត់ទេ អត់បានទេ ចូលមកចាប់ខ្លួនចាប់ទៀតឥឡូវ ។

**ស៖** សូមអរគុណ ។ សំណួរមួយទៀត ទាក់ទងទៅនឹងការសម្រាកនៅពេលយប់ ។ នៅពេលយប់គេមានឲ្យមុង ឲ្យអី ឬមួយក៏ភ្លើងភ្លក់អីឲ្យទេដល់ពេលសម្រាកពេលយប់?

**ឆ៖** អត់ អត់មានទេ ។ អត់មានមុងអត់មានអីទេ នៅក្នុងគុកហ្នឹងដេកអត់មានកន្ទេលផងទេ ។ ដេកផ្ទាល់ដីគ្រាន់តែសង្កើចក្រហមច្រាល ។

**ស៖** ទាក់ទងនឹងសំណួរមួយទៀត ។ នៅពេលដែលអ៊ំ ឬក៏អ្នកទោស នៅពេលហ្នឹងទាំងយប់ ឬក៏ថ្ងៃហ្នឹង ពេលយើងត្រូវការបត់ជើបតូច ឬបត់ជើងធំអីហ្នឹង អាចត្រូវការទៅបត់ជើងទៅតាមបំណង

ទេ? ហើយមានអ្នកខ្លះអាច ឧទាហរណ៍ថា គាត់ទៅមិនទាន់ សុំមិនទាន់អ៊ីចឹង អាចបត់ជើងអី ដាក់លាមកនៅក្នុងទីហ្នឹង អីនាំឲ្យ?

**ឆ៖** អត់ទេៗ ។ ពេលយើងបត់ជើងតូចជើងធំ យើងហៅគេអ្នកយាម គេអ្នកយាមគេនៅលើមាត់ផ្លូវហ្នឹងចាំស្តាប់យើង ដល់ពេលយើងឈឺពោះយប់ គេហុចបំពង់ឫស្សីៗឲ្យយើងឈឺដាក់នៅក្នុងបំពង់ហ្នឹង ព្រឹកឡើងបានយកឡើងទៅចោល ។ ទឹកនោមក៏ដោយ ទឹកលាមកក៏ដោយ គេហុចបំពង់ឫស្សីឲ្យអាហ្នឹងពេលយប់ ។ បើពេលថ្ងៃ បានគេដោះខ្នោះជើងយើង គេឲ្យយើងទៅឈឺដល់បង្គន់ ។

[១៥:៥៤:៤៥]

**ស៖** អ៊ីចឹង នៅពេលដែលសម្រាកពេលយប់ គឺដាក់ខ្នោះដៃទេ?

**ឆ៖** នៅក្នុងរណ្តៅគុកហ្នុង គេលែងៗស្រាយចំណងដៃហើយ តែអ្នកខ្លះដែលរួចពីហ្នឹងទៅ អ្នកខ្លះគេអត់ស្រាយទេចំណងហ្នឹង គេចងហើយខ្សែអង្រឹងហ្នឹង ចងរហូតដល់រលួយសាច់រហូតដល់ឃើញឆ្អឹង បានគេស្រាយ ។

**ស៖** អ៊ីចឹង នៅពេលដែលបត់ជើងធំ គេអាចឲ្យអ្នកទោសហ្នឹងឡើងទៅក្រៅពេលយប់?

**ឆ៖** ពេលថ្ងៃទេ ពេលយប់គេអត់ឲ្យឡើងទេ ។ គេដាក់បំពង់ឫស្សីទម្លាក់មកឲ្យយើងជុះនៅក្នុងគុកហ្នឹង ។

**អ្នកបកប្រែ៖**

លោកប្រធាន សូមអនុញ្ញាតឲ្យសាក្សី លើកឡើងវិញ ចំពោះចំណុចហ្នឹង ។

**លោក គង់ ពិសី៖**

អ៊ីចឹង នៅពេលយប់--

**ប្រធានអង្គជំនុំ៖**

ក៏ប៉ុន្តែសាក្សីសូមឆ្លើយនឹងសណ្ឋរមុននេះម្តងទៀត ពីព្រោះការបកប្រែនិងការកត់ត្រាធ្វើមិនអាចធ្វើបានទេ ។

អ៊ំ ស៊ន និយាយម្តងទៀត សំណួរមិញនេះហ្នឹង អ៊ំឆ្លើយៗម្តងទៀត ពីព្រោះខាងបកប្រែហើយនិងការធ្វើកំណត់ហេតុអត់អាចកត់ត្រាបាន ។

**សាក្សី KW-30៖**

អ្នកទោសដែលត្រូវឈឺបត់ជើងតូចបត់ជើងធំ ហៅកងការពារគេថា ខ្ញុំឈឺបត់ជើង ហើយគេ

ទម្លាក់បំពង់ឫស្សី ឲ្យយើងជុះដាក់នៅក្នុងហ្នឹង តែទុកចោលហ្នឹង ព្រឹកឡើងបានលើកយកទៅចោល ។

គេគ្រាន់តែហុចឲ្យ គេមិនទទួលអារបស់យើងហ្នឹងយកទៅចាក់ចោលឲ្យយើងទេ ។ តែព្រឹកឡើងបានគេដោះមាន ហុចឲ្យអ្នកដែលនៅខាងលើហ្នឹងទទួលយកទៅចាក់ចោលទៅ។ ហ្នឹងពេលយប់ ។ តែបើពេលថ្ងៃ អាហ្នឹងយើងប្រាប់គេថាខ្ញុំឈឺបត់ជើងធំ គេទៅដោះរនងគុកហ្នឹង ដោះខ្នោះជើងហ្នឹងមកគេឲ្យយើងឡើងមកឈឺបត់ជើង តែចំណងដៃគេចង គេអត់លែងយើងទេ គេខ្លាចក្រែងលោយើងរត់ ។

**ស៖** សូមអរគុណ, អ៊ីចឹង នៅពេលដែលបត់ជើងហើយ បត់ជើងធំៗហើយ នៅពេលយកទឹកបំពង់បត់ជើងហ្នឹង គេអត់យកចេញទៅក្រៅទេ នៅក្នុងរណ្តៅហ្នឹង ។ អ៊ំបញ្ជាក់អ៊ីចឹងបានទេ?

**ឆ៖** បាន, បញ្ជាក់បាន ។ នែ៎ បំពង់ដែលឈឺបត់ជើងយប់ហ្នឹង នៅទុកហ្នឹងទល់វាស់ព្រឹក ។ នៅក្នុងរណ្តៅគុកហ្នឹង ។

**ស៖** អ៊ីចឹង នៅពេលដែលទុកបំពង់នៅក្នុងហ្នឹង ។ អ៊ីចឹង វាមានធុំក្លិនអីដាក់អ្នកដទៃទេ?

**ឆ៖** ធុំនោះចៀសមិនផុតទេគឺធុំដែរ តែដឹងធ្វើម៉េច។ តែបំពង់ហ្នឹងមិនមែនម៉ាឫស្សីម៉ាសាច់ទេ បំពង់ឫស្សីវែងយកដាក់ពីរសាច់អ៊ីចឹងទៅ គេចោះអ៊ីចឹងទៅគេធ្វើដូចយើងតយអ៊ីចឹងទៅ គេដាក់អ៊ីចឹងទៅ យើងជុះដាក់ទៅ គេផ្អែកនឹងជញ្ជាំងរណ្តៅគុកហ្នឹងទៅ ផ្អែកចោលហ្នឹងទៅ ។ ហើយយើងក៏អត់មានទៅវាសអីប៉ះពាល់អីទេ ព្រោះវាជើងសុទ្ធតែជាប់ខ្នោះអស់ហើយ អ្នកខ្លះដែលទោសធ្ងន់ៗអស់ហ្នឹងយើងខ្ញុំមើលទៅដូចថា យើងប្រៀបធៀបអ៊ីចឹងចុះ បើគេអត់ស្រាយចំណងដៃ យើងសន្និដ្ឋានថាធ្ងន់ ខ្លះក៏ជាប់ជើងក៏ជាប់ដៃក៏ជាប់អ៊ីចឹងទៅ ។

[១៥:៥៨:៣០]

**ស៖** ទាក់ទងទៅនឹងការបត់ជើងនោះដែរ បត់ជើងធំ ។ អ៊ីចឹង អ្នកដែលជាប់ខ្នោះជើងជាប់ក្នុងរនងហ្នឹងជាមួយគ្នាអ៊ីចឹង តើគាត់បត់ជើងធំរបៀបម៉េចទៅ? បត់ជើងធំ?

**ឆ៖** អាហ្នឹង គ្រាន់តែងើបឈរ ងើបឈរទៅយើងសម្រុតទៅ យកបំពង់ដាក់ទ្រាប់នឹងគ្ដិតទៅជុះទៅ ។ រួចហើយអ្នកដែលនៅអមៗគ្នានេះ ជួយគ្នាទៅ អ្នកទោសដូចគ្នាហ្នឹង ។

**ស៖** ខ្ញុំសុំសួរសំណួរបន្តទៀត បើសិនជាសំណួរហ្នឹងមានការដូចថា-- ដូចថាពិបាកស្តាប់អី សូមអធ្យាស្រ័យ ។ ចុះ! នៅពេលដែលបត់ជើងធំអ៊ីចឹង ចុះ! ទឹកនោមនៅខាងណាវិញ?

**ឆ៖** ទឹកនោម បំពង់ហ្នឹងវាធំអ៊ីចឹង ដែលយើងឧបមាថា វាមានរណ្តៅគុកហ្នឹងគ្នាបួនដប់នាក់ ម្ភៃនាក់ ប្រៀបធៀបថាវាមិនមែនជុះទាំងអស់ទេ ។ ទាញឧទាហរណ៍ថា វាឈឺតែមួយម្នាក់ពីរម្នាក់ វាមិន

អាចទៅបំពង់ទេ យើងឈឺនោមដាក់នៅក្នុងទៀតទៅ ជាមួយគ្នាហ្នឹងលីម្ហូកនិងទឹកនោមនោះ ។ ព្រោះបំពង់ហ្នឹងមិនមែនតូចទេ បំពង់ឫស្សីធំៗ គេធ្វើសម្រាប់តែអ៊ីចឹង ។

**ស៖** សំណួរមួយទៀត ខ្ញុំដឹងថាពេលយប់គឺមិនឲ្យអីហូបទេ។ ប៉ុន្តែមានអ្នកខ្លះអាចស្រេកទឹកនៅខែក្តៅខែអីអ៊ីចឹង ។ សួរថា តើយើងអាចសុំទឹកគេហូបបានទេ?

**ឆ៖** អឺ! ដូចជាអត់ដែរ ឃើញមានសុំផង អត់ ។ អត់ដែរឃើញសុំទេ ទាល់តែព្រឹកឡើង ដល់ពេលបាយ ពេលអីហ្នឹងទៅ វាដូចជាថាកាលបើនៅជាប់ដំបូង បានស្រេកមែនទឹក ។ ខ្ញុំដឹងពីខ្លួនខ្ញុំ កាលដែលជាប់ដំបូងហ្នឹង ដែលដៃគឺជាប់ចំណង ហើយដៃហ្នឹងមិនមែនចងតែចំណងតែមួយទេ ចំណងពីរ។ កដៃមួយ កែងមួយ ជង្គង់ដៃមួយ ហើយនិងកដៃមួយ ហើយជើងនេះជាប់ខ្នោះទៀត ។ អាហ្នឹងស្រេកណាស់ ស្រេកនោះៗ ស្រេកលែងនិយាយ មហាឱស្រេក ។

[១៦:០០:៣៨]

**ស៖** អ៊ីចឹង នៅពេលដែលអ៊ំស្រេកទឹក ។ អ៊ំ មានបានសុំគេហូបទេ?

**ឆ៖** បាទសុំ គេឲ្យបាន គេឲ្យម្តងមួយកែវ ។ មួយកែវបី ដូចយើងពីដើម គេហៅកែវគេលក់ស្រាគេហៅថាមួយកែវបីរៀលហ្នឹង ប៉ុនៗនែ៎សៗ ។ គេឲ្យប៉ុនហ្នឹង ហើយស្រេកចង់ងាប់ហើយ គេឲ្យប៉ុនហ្នឹង ។

**ស៖** ប៉ុនកែវនៅមុខ អ៊ំ នោះទេ?

**ឆ៖** អត់ ។ កែវបីរៀលពីដើម អាកែវគេលក់ស្រាបីរៀលពីដើម អាកែវខ្លីៗរាងកាពុលៗហ្នឹងតិចអាមាត់ក្រាស់ៗ ធ្លាក់ដីអត់បែកនុ៎ងណ៎ា ។

**ស៖** អ៊ីចឹង អ៊ំមានអ្នកផ្សេងទៀតដែលអាចសុំ ដែលប៉ានសុំផឹកទឹកអ៊ីចឹងទេ? ក្រោយមក?

**ឆ៖** បាទ, មានសុំ ។

**ស៖** ដែរបានទេ?

**ឆ៖** បាន កងការពារគេយកឲ្យ ។

**ស៖** បាទ, សូមអរគុណលោកប្រធាន ។

[១៦:០១:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ មេធាវីតំណាងឲ្យក្រុមបី ។ សូមអញ្ជើញ បានសិនជាមានសំណួរ ។

**សួរដោយលោក ហ្វីលីព កាណុន៖**

លោកចៅក្រម ខ្ញុំមានសំណួរតែមួយហើយខ្ញុំសួរដោយសង្ខេប ។ រសៀលនេះ ខ្ញុំជាមេធាវីរបស់ក្រុមបី គឺ កាណុន ។

**ស៖** លោកនិយាយអំពីរណ្តៅ ។ ហើយខ្ញុំចង់សួរសំណួរ ថាតើអ្នកទោសត្រូវបានគេនាំមករណ្តៅដើម្បីការពារអ្នកទោសឲ្យមានប្រសិទ្ធភាពពីការទម្លាក់គ្រាប់បែកឬយ៉ាងម៉េច? ថាតើរណ្តៅត្រូវបានគេប្រើប្រាប់ក្នុងការការពារចំពោះការទម្លាក់គ្រាប់បែកដែរឬទេ?

**សាក្សី KW-30៖**

រណ្តៅ ដែលគេដាក់អ្នកទោសហ្នឹង គោលបំណងគេថាការពារគ្រាប់បែកក៏មិនដឹង តែខ្ញុំបើយល់ទស្សនៈរបស់ខ្ញុំវិញ ខ្ញុំថាមិនមែនអាររណ្តៅហ្នឹង គឺសម្រាប់ដាក់អ្នកទោស ។ ហើយរណ្តៅដែលគេធ្វើសម្រាប់ជ្រកពួកខាង ដូច តាឌុច អីអ៊ីចឹង គេធ្វើផ្សេងរបស់គេ គេមិនមែននេះអី ។ សូម្បីតែគ្រាប់បែកធ្លាក់ចំមិនមែន តាឌុច រត់ទៅលើកទម្លាក់ក្នុងហ្នឹងទេ គឺសម្រាប់អ្នកទោស ។ តែបើសិនណាជា កប៉ាល់ហោះចល័តវិញ មិនបាច់ថាត្រូវចំទេ គ្រាន់តែធ្លាក់ឃ្លាតតែ៥ម៉ែត្រ ហ្នឹងក៏វាបាក់រណ្តៅគ្រាប់បែក ពីដើមវាគ្រាន់តែរណ្តៅមួយៗសឹងតែប៉ុនស្រះ អាប៉ុនហ្នឹង វាបាក់ងាប់ៗអស់រលីងអស់បាត់ទៅហើយ បើត្រូវចំនោះ ។

**លោក ហ្វីលីព កាណុន៖**

លោកប្រធាន, ខ្ញុំសូមអរគុណ លោក លោកស្រីចៅក្រម ។

[១៦:០៣:៤៩]

**ប្រធានអង្គជំនុំ៖**

ជាបន្ត សូមអញ្ជើញ មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន ។ បើសិនជាសំណួរសូមអញ្ជើញ ។

**សួរដោយលោក ហុង គឹមសួន៖**

សូមគោរព លោកប្រធាននិងសូមគោរព លោកចៅក្រមជាតិ និងអន្តរជាតិ និងអង្គសវនាការជាទីគោរព ។ ខ្ញុំសូមសួរសំណួរត្រង់ទៅលោកអ៊ំ អ៊ុច ស៊ន មានបួនសំណួរ ។

**ស៖** សូមអ៊ំមេត្តាបញ្ជាក់ឡើងវិញ អ៊ំថាបានឃើញពេលមួយនោះ លោក ឌុច បានវាយស្រីម្នាក់ហើយ អ៊ំថាអ៊ំឮ គាត់ថែមទាំងនិយាយថា ឈ្មោះនេះជាកូនមុនីវង្ស កូនស្តេច ប៉ុន្តែ លោក ឌុច ថាគាត់

មិនសម្លាប់ឬក៏មិនវាយកន្លែងហ្នឹង ខ្ញុំស្ដាប់មិនទាន់ ។ តែនិយាយពាក្យថា "សម្លាប់ខ្មាំង" មិនមែនសម្លាប់កូនស្ដេច ឬក៏មិនវាយខ្មាំង ឬក៏មិនវាយកូនស្ដេច ។ សូមអ៊ំបញ្ជាក់បន្តិច?

[១៦:០៥:០០]

**សាក្សី KW-30៖**

**ឆ៖** កន្លែងហ្នឹង ខ្ញុំឮៗគាត់និយាយ។ តែគាត់សួរថា ហងឯងឈ្មោះអី? ហើយក៏ខ្ញុំមិនចាំ អ្វែងកូនអ្នកណាគេ ថាអ៊ីចេះ ។ អ្វែងកូនអ្នកណាគេ? ឪពុកអ្វែងឈ្មោះអី? គាត់ហ្នឹងគាត់ឆ្លើយថា មនុស្សស្រីទេណាៗ រាងខ្មៅស្រអែមធាត់ ហើយគាត់ថាឪពុកគាត់ឈ្មោះ វង្ស ។

ហើយក៏ តាឌុច ហ៊ឺ! អ្វែងមិនបាច់លាក់ហ្នឹងអញទេ អ្វែងកូនមុនីវង្សអី ។ គាត់ថាអ៊ីចឹង តែគាត់ថាលេងក៏មិនថា មែនក៏មិនដឹងទេ ។ ព្រោះខ្ញុំគ្រាន់តែស្ដាប់ឮទេ ។ គាត់ថាលេងជាមួយនាងហ្នឹងក៏មិនដឹង គាត់ថាមែនក៏មិនដឹង ។ ហើយគាត់ថា អញនែ៎ អញមិនមែនសម្លាប់ស្ដេចទេវើយ អញសម្លាប់តែខ្មាំងទេ គាត់និយាយតែប៉ុណ្ណឹង ។ ហើយខ្ញុំក៏អត់បាននៅអីស្ថិតស្ថេរនុំងទេ ខ្ញុំដើរគេច ដើរចេញបាត់ទេ ព្រោះភារកិច្ចខ្ញុំអត់មាននៅចាំស្ដាប់អីគេនិយាយទេ គ្រាន់ប៉ុនពេលដែលដើរទៅចំឮគេនិយាយអ៊ីចឹង ។

**ស៖** អរគុណ ។ សំណួរទីពីរ កន្លែងនេះវាមានការផ្ទុយគ្នាជាមួយនឹងលោក ឌុច បន្តិច ។ អ៊ីចឹងខ្ញុំសួរបញ្ជាក់ឡើងវិញថា នៅពេលអ៊ំបានឃើញការដែលគេសម្លាប់មនុស្សម្នាក់ដែលមេធាវីមុនៗ គាត់បានលើកឡើងនោះ ដោយចងនឹងបង្គោលបួនមុំហើយកណ្ដាលមានម្នាក់ ។ អ៊ំបានជម្រាប អង្គសវនាការមិញថា ស្គាល់ឈ្មោះអ្នកដែលបាញ់សម្លាប់នោះ គឺឈ្មោះ ចាន់ ។ តើអញ្ចឹងមែនទេ?

**ឆ៖** មែន ។ ឈ្មោះ តាចាន់ ខ្ញុំស្គាល់ច្បាស់ណាស់ ។ តាចាន់ ហ្នឹង គេហៅថា តាចាន់ កំលុង ។

**ស៖** មុនពីថ្ងៃនេះបន្តិចអ៊ំថា ស្គាល់ឈ្មោះ ចាន់, ឈ្មោះ មាស, ឈ្មោះ ប៉ុន ។ អ៊ំស្គាល់ច្បាស់ទេ ឈ្មោះទាំងបីនាក់នោះ?

**ឆ៖** បាទ ស្គាល់ ។

**ស៖** អ៊ីចឹង មិនច្រឡំគ្នាទេ?

**ឆ៖** បាទ អត់ច្រឡំទេ ។

**លោក ហុង គីមសួន៖**

ត្រង់កន្លែងនេះ ខ្ញុំបាទសូមអនុញ្ញាតលោកប្រធានសួរសំណួរទៅលោក ឌុច អំពីគាត់បានជម្រាបថា គាត់បានចាត់តាំងមនុស្សម្នាក់សម្លាប់មែនតែមិនបានប្រាប់ឈ្មោះ ។ តើលោកគ្នានឹងដូចលោកអ៊ំ ស៊ិន

បានជម្រាបដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទអាចឆ្លើយនឹងសំណួរនេះបានទេ? បើអាច-- សូមអញ្ជើញឆ្លើយនូវសំណួរនេះ ។

[១៦:០៧:២៩]

**ជនជាប់ចោទ៖**

ខ្ញុំមិននិយាយរឿងហេតុៗ ខ្ញុំមិននិយាយរឿងហេតុហួរហែពីមុនមកទេ ។ គ្រាន់តែសូមបដិសេធថា អ្នកដែលបាញ់នោះមិនមែន បងចាន់ ទេ គឺមិត្តយើងម្នាក់ផ្សេងទៀត ។

**លោក គង់ ពិសី៖**

បាទ, អរគុណ ។

**ជនជាប់ចោទ៖**

បាទ ។

**សួរដោយលោក គង់ ពិសី៖**

**ស៖** សំណួរទីបី ខ្ញុំសុំសួរថា អ៊ំបានជម្រាបអង្គសវនាការថាមូលហេតុគេចាប់ព្រោះការទៅចាប់ជ្រូក ឬទិញជ្រូក ហើយអ៊ំបានដឹងថា សង្គមនោះគឺអស់មានសាសនា ។ តើអ៊ំបានដឹងដោយវិធីណាថាសង្គមនោះ ឥតមានសាសនា?

**សាក្សី KW-30៖**

**ឆ៖** ខ្ញុំយល់ថាកុម្មុយនីស្ត គេអត់ជំនឿអីទេ អានេះការយល់របស់ខ្ញុំតែម្តង ។ ហើយក៏ខ្ញុំអត់ហ៊ានចេញនិយាយថាប្រាប់គេប្រាប់ឯងថា សង្គមហ្នឹងវាអស់មានជំនឿទេ អត់មានព្រះពុទ្ធសាសនា តែខ្ញុំយល់ថាកុម្មុយនីស្ត គឺអត់មានទេ អត់មានសាសនាទេ អ៊ីចឹងខ្ញុំធ្វើឲ្យហើយទៅ ។ ដល់ចុងក្រោយ វាដូចពាក្យខ្ញុំដូចគំនិតដែលខ្ញុំគិតមែន ។ វាអត់មែន ដល់ពេលបានជ័យជម្នះ គេរើវត្តវាចោលអស់រលីង ឈប់ឲ្យជឿសូម្បីតែមនោសញ្ចេតនាគ្រួសារម៉ែឪកូនឪពុកក៏អត់ផង កុំថាឡើងព្រះពុទ្ធសាសនាម៉េចគេឲ្យមាន ។ អាហ្នឹងការយល់របស់ខ្ញុំទេ តែយល់ទៅវាចំកន្លែងហើអាកន្លែងហ្នឹងពិតប្រាកដ ។

**ស៖** បាទ, អរគុណ ។ សំណួរចុងក្រោយ នៅពេលអ៊ំត្រូវបានដោះលែង អ៊ំថាត្រូវបានបញ្ជូនទៅពោធិ៍សាត់នោះ មានន័យថាទៅតំបន់រំដោះដដែល ឬដោះលែងឲ្យទៅតំបន់សេរីខាងលោក លន់ នល់?

**ឆ៖** ទៅតំបន់រំដោះដដែល ។ អត់មានទៅខាង លន់ នល់ ទេ ទៅកន្លែងរំដោះដដែល ។

[១៦:០៩:១៥]

**លោក គង់ ពិសី៖**

សូមអររគុណ សូមអស់សំណួរលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត សុំប្រគល់វេទិកានេះជូនទៅមេធាវីការពារក្តីនូវឱកាស ដើម្បីអាចតាំងសំណួរដល់សាក្សីរូបនេះ ។ ប្រសិនបើមាន សូមអញ្ជើញ មេធាវីការពារក្តី ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណលោកប្រធាន ។ សូមលោកជាសាក្សីឆ្លើយបញ្ជាក់ម្តងទៀតឲ្យច្បាស់ ពីព្រោះពី ព្រឹកមិញលោកប្រធានអង្គជំនុំជម្រះបានសួរលោកជាសាក្សី គឺថានៅពេលនោះ ដែលលោកជាប់គុកហ្នឹង លោកមានឃើញក្មេង ដែលមានចាស់ មានក្មេង មានប្រុស មានស្រី ហ្នឹង ។ ហើយលោកប្រធានបានសួរបញ្ជាក់ថា ក្មេងមានចំនួនប៉ុន្មាននាក់? លោកជាសាក្សីបានឆ្លើយបញ្ជាក់ជូនលោក ប្រធានថា ៣០នាក់ ។ តែអម្បាញ់មិញនេះ លោកព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាបាន សួរលោកថា ក្មេងមានប៉ុន្មាននាក់ដែលទៅតាមជាមួយម្តាយឪពុកនោះ? លោកឆ្លើយថាមាន១០នាក់ ។ អ៊ីចឹងលោកបញ្ជាក់ឲ្យច្បាស់មើល តើវា១០នាក់ ឬក៏៣០ នាក់?

**សាក្សី អ៊ុច ស៊ន៖**

ក្មេងដែលជាប់ទៅហ្នឹង វាច្រើនតែវាមិនមែនតែជាប់ពួកអ្នកចាប់ហ្នឹងទេ វាកាលដែលគេវ៉ៃឧដុង្គបែកហ្នឹង អូ! អាហ្នឹងបើនិយាយរាប់អាហ្នឹង គឺច្រើនណាស់ យកមកដាក់មន្ទីរហ្នឹង ។ តែខ្ញុំនិយាយពីរាប់ពីអ្នកភូមិៗផងរបងជាមួយគ្នាដែលចាប់យកមកហ្នឹងប្រហែលជាប្អូនដប់នាក់ តែបើខ្ញុំ រាប់រៀបដែលពីគេវាយឧដុង្គបែក គេយកមកដាក់ម-១៣ ហ្នឹង ឃើញខ្ញុំឃើញច្រើនណាស់ក្មេង ។ អស់យោបល់ប៉ុណ្ណឹងហើយ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធានខាងមេធាវីការពារ សហមេធាវីការពារមិនមានសំណួរសួរអ្វីទៀតទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី អញ្ជើញ ។

**លោក ហ្វ្រេង់ស្វ័រ រូ៖**

យើងប្រហែលជាមានសំណួរមួយចំនួន ដោយសារតែសាក្សីនេះ គាត់មានការពិបាកចំពោះចំនួនលេខ ហើយចំពោះបញ្ហាផ្សេងយើងអត់មានសំណួរ ឬក៏បញ្ហាផ្សេងចង់លើកឡើងទេ ។

[១៦:១២:០៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមានសំណួរអីជាក់លាក់ទេ? សូមអញ្ជើញ ។

**លោក ហ្វ្រេង់ស្វ័រ រូ៖**

អ៊ីចឹង គឺអរគុណលោកប្រធានយើងអាចធ្វើការងារហ្នឹងដោយមិនចាំបាច់ចោទសំណួរក៏បានដែរ ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង យើងគិតថាដំណើរការសវនាការថ្ងៃនេះដល់ទីបញ្ចប់ហើយ ហើយបើយើងចាត់ចែងសួរតទៅទៀត វាសាក្សីថ្មីក៏អត់មាន អស់ពេលហើយដែរ ។ អ៊ីចឹង គឺអ៊ំ អ៊ុច ស៊ន អង្គជំនុំជម្រះអស់សំណួរត្រូវការសួរអ៊ំទៀតហើយ អ៊ីចឹងអ៊ំអាចត្រឡប់ទៅលំនៅដ្ឋានរបស់អ៊ំវិញបានហើយ ។

មន្ត្រីតុលាការសូមជួយសម្រួលគាត់ ដើម្បីជូនគាត់ទៅជួបប្រាស្រ័យទាក់ទងជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ដើម្បីរៀបចំគាត់ត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ ។

អង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះនៅត្រឹមនេះ ហើយសវនាការនឹងបន្តនៅព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ចាប់ពីម៉ោងប្រាំបួនព្រឹកទៅ ។ ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់កាំង ហ្គេកអ៊ាវ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនមកកាន់សវនាការនៅថ្ងៃទី២០ ខែមេសា ឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំហិត ។

ដូចគ្នា គឺសូមជម្រាបដល់អ្នកចូលរួមក្នុងកិច្ចនីតិវិធីសវនាការ និងសាធារណជនដែល មានការ--បំណងចូលរួមសវនាការ សូមអញ្ជើញមកចូលរួមនៅក្នុងសវនាការឲ្យបានមុនម៉ោងប្រាំបួន ព្រឹកនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ។

**លោក ហុង គឹមសួន៖**

សូមអនុញ្ញាតលោកប្រធានបន្តិច ។ សូមទោសបាទ តើពីថ្ងៃ២០ មានជារបៀបវារៈលម្អិតទៀតទេ?

**ប្រធានអង្គជំនុំ៖**

របៀបវារៈអង្គជំនុំជម្រះនឹងបញ្ជូននៅថ្ងៃស្អែក ។ ដោយសារការប៉ុនប៉ងថ្ងៃនេះ វាការព្យាករណ៍ប៉ាន់ស្មានទៅ វាជាការមួយវាជួបប្រទះនឹងការគណនាពេលវេលាទៅវាខុស អ៊ីចឹងហើយបានជាយើងអត់ចេញពីម្សិលមិញ ឬក៏ថ្ងៃនេះ ។ អ៊ីចឹងយើង ព្រលឹមឡើង គឺយើងចេញជូនអស់លោកឲ្យបានជ្រាបពីបញ្ហាអស់នេះហើយ ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកនៅម៉ោង ១៦:១៥នាទី]*